ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ជនរងគ្រោះ
- សមមិត្តនារីខ្មែររស់ស្លាប

លេខ១៣ ខែមករា ឆ្នាំ២០០១

# ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ២៣ ខែវិច្ឆិកា ឆ្នាំ២០០១


## មាតិកា


◆ សំបុត្រៈ ជនរងគ្រោះ......១

**ផ្នែកឯកសារ**

◆ ប្រជុំគណៈអចិន្ត្រៃយ៍......៣

◆ វាលពិឃាតនៅស្រុកអូររាំងឪ......៦

◆ ទិន្នន័យទីតាំងរួមនៃអំពើប្រល័យពូជសាសន៍......១៣

◆ អតីតលេខាទី២នៃស្ថានទូតកម្ពុជាប្រចាំនៅគុយបា......១៥

◆ កាលប្បវត្តិរបស់ហាណូយ......២០

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ សមមិត្តនារីខ្មែរអ៊ីស្លាម......២៣

◆ រូបថតដែលនៅមានជីវិត......២៨

◆ សម្លេងពីមន្ទីរស-២១......៣០

◆ មូលហេតុនៃការធ្វើអត្តឃាតរបស់អ្នកទោសឈ្មោះកង......៣៥

**ផ្នែកច្បាប់**

◆ ខ្មែរក្រហមពិតជាបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍មែន......៣៩

◆ តម្លៃនៃភ័ស្តុតាង......៤២

**វេទិកាពិភាក្សាសាធារណៈ**

◆ ប្រយុទ្ធដើម្បីការពិត និងយុត្តិធម៌......៤៧

◆ ការពិភាក្សារវាងរដ្ឋាភិបាលនិងអង្គការសហប្រជាជាតិ......៥៣

◆ ចិនបរិយាយៈ ហេតុអ្វីបានជាអាជ្ញាធរវៀតណាមបង្កជម្លោះ......៥៧

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ រឿងពិត......៥៩

**សិល្បៈខ្មែរក្រហមៈ**

**កំណាព្យៈ** យុវជន យុវនារីបដិវត្តន៍...... ក្របក្រោយ





រូបថតអ្នកទោសនៅមន្ទីរស-២១


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា



អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**វាគ្មិនលេខនេះ:** ដេវីត ឆេនដល័រ, ចន ឆរឆីអារី, រ៉ូប៊ឺត ខាម៉ៃឃើល, គ្រីហ្គោរី ស្ដែនតុន, ថូម៉ាស់ ហាម៉ាប៊ឺក, ជេង ពង្សរ៉ាស៊ី, ចាន់ ស្រីទូច **អ្នកនិពន្ធនិងស្រាវជ្រាវៈ** សាន់ កល្យាណ, លី សុផល, ជួង សុភារិទ្ធ **ជំនួយការនិពន្ធនាយកៈ** អែម សុខឃីម **និពន្ធនាយករងទី១ៈ** ដាត កុសល **និពន្ធនាយករងទី២ៈ** ស៊ឹម សុរិយ៉ា **អ្នកបកប្រែៈ** សួ ប៊ុនស៊ូ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** សុខ វណ្ណៈ

*សំបុត្រៈ*

# ជនរងគ្រោះ

ជារឿយៗ នៅពេលដែលយើងជួបខ្មែរម្នាក់ប្រកបដោយចរិយាសម្បត្តិអធ្យាស្រ័យល្អនិងញញឹមរួសរាយ យើងងាយនឹងភ្លេចគិតថាបុគ្គលរូបនេះ គឺជាអ្នកដែលបានទទួលរងការឈឺចាប់និងគ្រាំគ្រាផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរក្រោមរបបខ្មែរក្រហម ។ មិត្តភក្តិរបស់ខ្ញុំម្នាក់ដែលជាជនបរទេសធ្លាប់បាននិយាយទាក់ទងនឹងបញ្ហានេះ ។ គាត់បានសាកសួរទៅមីង សយ ដែលជាអ្នកបោសសម្អាតផ្ទះរបស់គាត់ថា "តើមីង សយ មានកូនចៅប៉ុន្មាននាក់?" ។ មីងសយ ហូរទឹកភ្នែក ហើយពោលទាំងអួលអាក់ថា "កូននិងប្តីរបស់ខ្ញុំស្លាប់ជំនាន់ ប៉ុល ពត អស់ហើយ" ។

តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលនឹងចេញជារូបរាងក្នុងពេលឆាប់ៗខាងមុខនេះត្រូវតែផ្តល់នូវភាពយុត្តិធម៌និងត្រូវធ្វើឲ្យដំណើរការជំនុំជម្រះក្តីមានភាពសុក្រិតចំពោះជនរងគ្រោះនិងជនដែលរស់ ។

អ្នកបើកភ្នែកចាំតែមើលនិងស្រេកឃ្លានអំណាច ហើយដែលបានដឹកនាំប្រទេសនិងប្រជាជនកម្ពុជាឲ្យធ្លាក់ទៅក្នុងរណ្តៅពិឃាតត្រូវតែនាំយកមកកាត់ទោសនៅចំពោះមុខតុលាការឲ្យខាងតែបាន ។ មេដឹកនាំខ្មែរក្រហមដែលធ្វើការកែប្រែសង្គមនៅលើគំនរសាកសពប្រជាជនកម្ពុជាគឺនៅតែទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ។

ក្នុងពេលដែលសេចក្តីស្លាប់ខិតចូលមកកាន់តែជិតហើយនោះ សេចក្តីប៉ងប្រាថ្នាចង់រស់រានមានជីវិតមុខជានឹងក្លាយទៅជាឧបករណ៍ដ៏សំខាន់សម្រាប់អ្នកដែលអនុវត្តផែនការរបស់មេដឹកនាំ ។ អ្នកទាំងនោះសង្ឃឹមថានឹងបានរស់ដោយខិតខំធ្វើអ្វីគ្រប់បែបយ៉ាងតាមតែបញ្ជា ។ នេះប្រហែលក្លាយទៅជាការទាញហេតុផលសម្រាប់កម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោម ។

ប៉ុន្តែចំពោះអ្នកដែលជាមេគំនិតនិងជំរុញឲ្យអនុវត្តនយោបាយរបស់អង្គការបដិវត្តន៍ខ្មែរក្រហមមិនអាចទទួលការអត់ឱនបានឡើយ ។

ចង់ ឬមិនចង់រឿងខ្មែរក្រហម គឺបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ។ នេះជាប្រវត្តិសាស្ត្រមួយរបស់ប្រទេសកម្ពុជា ហើយក៏ជារឿងរ៉ាវរបស់ឪពុកម្តាយយើងដែរ ។ ហេតុដូចនេះក្នុងខណៈដែលប្រជាជនកម្ពុជាចង់បានយុត្តិធម៌បានដឹងការពិតនិងប្រវត្តិសាស្ត្ររបស់ខ្លួន វាគឺជាការសំខាន់ណាស់ ។ ខ្ញុំជឿជាក់ថាជនដែលរស់ជាច្រើនពិតជាគាំទ្រឲ្យមានតុលាការមួយដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម លុះត្រាណាតុលាការនោះបង្ហាញការពិត និងផ្តល់នូវយុត្តិធម៌មួយពិតប្រាកដ ។

**ឆាំង យុ**







# ប្រជុំគណៈអចិន្ត្រៃយ៍: បញ្ហាការពារប្រទេស

របបកម្ពុជាប្រជាធិបតេយ្យបានបើកកិច្ចប្រជុំគណៈអចិន្ត្រៃយ៍យ៉ាងហោចណាស់ក៏ពីរលើកដែរនៅក្នុងឆ្នាំ១៩៧៦ ដែលផ្តោតជាសំខាន់លើបញ្ហាការពារប្រទេស ។ ឯកសារកំណត់ហេតុនៃកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ស្តីអំពីបញ្ហាការពារប្រទេសនេះ មានកាលបរិច្ឆេទផ្សេងៗពីគ្នា គឺកិច្ចប្រជុំនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ ១៩៧៦ និងកិច្ចប្រជុំនៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ ១៩៧៦ ។

**នៅយប់ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦** សមាសភាពចូលរួមប្រជុំគណៈអចិន្ត្រៃយ៍ រួមមានជាអាទិ៍ គឺសមមិត្តលេខា (ប៉ុល ពត) សមមិត្តអនុលេខា (នួន ជា) សមមិត្តវ៉ាន់ (អៀង សារី) សមមិត្តវន (វន វ៉េត) សមមិត្តធុប (កុយ ធួន) សមមិត្តហែម (ខៀវ សំផន) សមមិត្តឡឿន និងសមមិត្ត ទូច ។ កិច្ចប្រជុំនេះបានពិភាក្សាលើបញ្ហាការពារប្រទេស ដែលមានចំណុចធំៗពីរ គឺ១) សេចក្តីរាយការណ៍អំពីសភាពការណ៍ខាងការពារប្រទេស និង២) មតិណែនាំរបស់អង្គការ ។

១) សេចក្តីរាយការណ៍អំពីសភាពការខាងការពារប្រទេស គឺ ក) សភាពការណ៍នៅព្រំដែនខាងកើត ខ) បញ្ហាជំនួយចិនទាក់ទងខាងអាកាសនិងខាងជើងទឹក គ) បញ្ហាដឹកគ្រាប់រំសេវ និង ឃ) ពេទ្យយោធា ។

សភាពការណ៍នៅព្រំដែនខាងកើត កំណត់ហេតុនៃអង្គប្រជុំបានធ្វើកំណត់ហេតុថា “សមមិត្តខៀវ(សុន សេន) រាយការណ៍ថាចាប់តាំងពីដើមខែកុម្ភៈ វៀតណាមបានធ្វើសកម្មភាពយ៉ាងខ្លាំងនៅតាមព្រំដែនយើងខាងកើត ពិសេស(ខេត្ត)រតនគិរី (ខេត្ត)ស្វាយរៀង និងក្អមសំណរ” ។

បញ្ហាជំនួយចិនទាក់ទងខាងអាកាសនិងខាងជើងទឹកៈ “សមមិត្ត ខៀវ បានលើកបញ្ហាជំនួយចិនទាក់ទងខាងអាកាសនិងជើងទឹក ហើយស្នើមតិអង្គការ ពិសេសបញ្ហាយុទ្ធជនរៀនបើកបរយន្តហោះ យុទ្ធជនរៀនធ្វើរំសេវ សំណង់រោងចក្រធ្វើអាវុធ មូលដ្ឋាននាវា ព្រលានយន្តហោះ កប៉ាល់ចម្បាំង អ្នកបច្ចេកទេស ៦៨នាក់មកដល់ថ្មី” ។

លើបញ្ហាដឹកគ្រាប់រំសេវៈ “វៀតណាមស្នើកម្លាំងថ្មីសម្រាប់ប្រគល់សម្ភារដែលសល់ពីឆ្នាំ១៩៧៥ឲ្យយើងចំនួន២កន្លែងអាចនៅស្វាយរៀង ឬនៅមេមត់ ។ គេ(វៀតណាម) ថាដឹកតាម

កប៉ាល់ចូលមិនចុះទេ» ។

ផ្នែកខាងពេទ្យយោធាៈ «សមមិត្តខៀវ ស្នើអង្គការបង្កើតពេទ្យយោធាមួយសម្រាប់យោធាយើង ហើយស្នើយកមន្ទីរពេទ្យព្រះកេតុមាលាចាស់» ។

(២) មតិណែនាំរបស់អង្គការ គឺក) បញ្ហានៅព្រំដែន ខ) បញ្ហាជំនួយចិនទាក់ទងខាងអាកាសនិងខាងជើងទឹក គ) បញ្ហាដឹកគ្រាប់ពីវៀតណាម និងឃ) បញ្ហាមន្ទីរពេទ្យយោធា ។

បញ្ហានៅព្រំដែន អង្គប្រជុំបានលើកឡើងថា «សកម្មភាពរំកិលព្រំដែនរបស់វៀតណាម មានទិដ្ឋភាព២យ៉ាង ទី១) វា (វៀតណាម) ចង់ប្របេះប្របោចដីយើង ជាទិសរួមរបស់វា ។ ទី២) ឬមួយខាងលើវា (វៀតណាម) ណែនាំ ឬមួយសកម្មភាពផ្ទាល់របស់ប្រជាជនដែលទៅពីកម្ពុជានិងរបស់ពួកកងល្បាតវានៅតាមព្រំដែន» ។

បញ្ហាជំនួយចិនទាក់ទងខាងអាកាស និងខាងជើងទឹកកំណត់ហេតុបានសរសេរអំពីការរៀនបើកយន្តហោះ ការរៀនធ្វើរំសេវ ការសាងសង់រោងចក្រធ្វើអាវុធ ការដាក់កប៉ាល់ការពារ ការកសាងសង់ព្រលានយន្តហោះ និងការរៀបចំឃ្លាំង ។

បញ្ហាដឹកគ្រាប់ពីវៀតណាម កំណត់ហេតុបានសរសេរថា «ត្រូវរៀបចំឲ្យហើយ ស្នើប្រែក៣ ស្នួល ស្នាប់ ឬមេមត់ ។ យើងទទួលនៅព្រំដែនកុំឲ្យចូលក្នុងទឹកដីយើង» ។

បញ្ហាមន្ទីរពេទ្យយោធា អង្គប្រជុំបានអនុម័តថា«អង្គការបានយល់ព្រមឲ្យរៀបចំមន្ទីរពេទ្យយោធាតាមសេចក្តីស្នើរបស់សេនាធិការ» ។

ដើម្បីដោះស្រាយបញ្ហានៅព្រំដែន ប្រជុំគណៈអចិន្ត្រៃយ៍នេះបានកំណត់នូវវិធានការ៣យ៉ាង គឺ «ក) ជាគោលការណ៍ យើងចរចាជាមួយវៀតណាមក៏ចរចា តែសំខាន់ត្រូវរៀបចំកម្លាំងការពារ ។ បើអនុវត្តតែនយោបាយទេ ហើយគ្មានវិធានការយោធា ដល់វា(វៀតណាម) មកច្រើនស្មុកស្មុះ យើងពិបាកដោះស្រាយ ។ ត្រូវពិនិត្យកន្លែងខ្លាំងកន្លែងខ្សោយ ហើយប្រុងប្រៀបប្រយុទ្ធ វាមកជ្រុល ដាក់វាភ្លាម ។ ខ) ត្រូវសហការឲ្យជាប់ជាមូលដ្ឋាន ដូច្នេះយោធារាយការណ៍ទៅមូលដ្ឋាន ហើយរាយការណ៍មកសេនាធិការជាព័ត៌មាន ។ ខាងមណ្ឌលគិរីមានសមមិត្តឡាំង ខាងរតនគិរីមានសមមិត្តយ៉ា ទទួលខុសត្រូវ ។ សំខាន់ គឺកងទ័ពនិងមូលដ្ឋានមានការឯកភាពគ្នា និងជាប់គ្នា ។ គ) ត្រូវប្រុងប្រយ័ត្ន ការពារកម្លាំងយើងកុំឲ្យវា(វៀតណាម) កម្ទេចកម្លាំងយើងបាន ហើយយកចិត្តទុកដាក់លើបញ្ហារក្សាការសម្ងាត់ កុំឲ្យបងប្អូនឆ្លេចឆ្លាច ។ ទាក់ទងគ្នាក៏ត្រូវស្ងាត់ដែរ» ។

បន្ថែមលើបញ្ហាជំនួយចិន ទាក់ទងខាងអាកាសនិងខាងជើងទឹក ការប្រជុំគណៈអចិន្ត្រៃយ៍សម្រេចថា «ក) រៀនបើកយន្តហោះ តថ្លៃគេ(ចិន) ត្រឹម២ឆ្នាំ ។ ស្នើឲ្យរៀបចំចុះ ហើយត្រូវឲ្យមានគណៈកម្មាធិការមួយយ៉ាងរឹងមាំសម្រាប់ដឹកនាំ

យោធាខ្មែរក្រហម



អ្នកដែលត្រូវទៅរៀនសូត្រទាំងនោះផង ។ ខ) រៀនធ្វើរំសេវ ត្រូវរៀនគ្រប់យ៉ាង ។ ឯអ្នករៀនយកមកពីសេនាធិការខ្លះ ពីមូលដ្ឋានខ្លះ ពិសេសមកពីភាគ(ភូមិភាគ) ធំៗ ។ គ) រោងចក្រអាវុធ ក៏ត្រូវត្រៀមលក្ខណៈទាំងអស់ ។ ឃ) កប៉ាល់ការពារយកទីតាំង(សមុទ្រ) រាមធ្វើជាកន្លែងជួសជុលកប៉ាល់ធុន [វីដែត] ។ នៅរាម ទុក(កប៉ាល់) ពីរគ្រឿងយ៉ាងច្រើន កប៉ាល់ឯទៀតទុកនៅកោះរង់សន្ទឹម ។ កប៉ាល់ការពារធុនធំ កប៉ាល់ប្រឆាំងនាវាមុជទឹក យើងកុំអាលយក ។ ចាំឲ្យកម្មាភិបាលនិងយុទ្ធជនយើងទៅរៀននៅឯស្រុកគេ ។ ង) ព្រលានយន្តហោះ ស្នើឲ្យពិនិត្យកន្លែងថ្មី ជ្រោះបន្តិច ដូចជាម្តុំត្នោតពង ឬកំពង់ឆ្នាំង ។ ច) ឃ្លាំងក៏ត្រូវរៀបចំនៅកន្លែងឆ្ងាយដែរ» ។

## ប្រជុំគណៈអចិន្ត្រៃយ៍នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៦

មានសមាសភាពចូលរួមជាអាទិ៍ គឺសមមិត្តលេខា (ប៉ុល ពត) សមមិត្តអនុលេខា (នួន ជា) សមមិត្តខៀវ (សុន សេន) សមមិត្តហែម (ខៀវ សំផន) សមមិត្ត ឌឿន និងសមមិត្ត ទូច (អ្នកធ្វើកំណត់ហេតុ) ។ កិច្ចប្រជុំនេះ ក៏បានពិភាក្សាលើបញ្ហាការពារប្រទេសដែរ ក្នុងនោះមានចំណុចធំៗពីរ គឺ១) ការសាងសង់រោងចក្រធ្វើអាវុធ និង២) ព្រលានយន្តហោះ ។

១) ការសាងសង់រោងចក្រធ្វើអាវុធ កំណត់ហេតុប្រជុំគណៈអចិន្ត្រៃយ៍បានលើកឡើងថា «រោងចក្រ សមមិត្តខៀវ (សុន សេន) រាយការណ៍ៈ សមមិត្ត ខៀវ បានជួបជាមួយចិន ទូត និងអ្នកបច្ចេកទេស ដើម្បីខ្ទេសនាមអំពីមតិរបស់អចិន្ត្រៃយ៍ ស្តីអំពីទិសនៃការសាងសង់រោងចក្រអាវុធ ។ គាត់(សុន សេន) បានយល់ស្របតាមគោលការណ៍នេះ ។ ក្រោយមកគេ(ចិន) បានសុំជួបយើងសុំឲ្យយើងរាយការណ៍ពីបទពិសោធន៍សង់រោងចក្រនៅក្នុងព្រៃ ។ រួចគេ(ចិន) បានប្រាប់ រោងចក្រត្រូវការដី២០០០០ម៉ែត្រក្រឡា ម៉ាស៊ីននាឡិកាពី៥០០-៦០០គ្រឿង កំដៅ២០អង្សាជាប្រចាំ ឡចំហាយមិនអាចធ្វើនៅក្នុងដី និងកម្មករជាង២០០០នាក់ ។ គេ(ចិន) ថា គេធ្លាប់ធ្វើរោងចក្រនៅក្នុងព្រៃដែរ ធ្វើទៅខូចម៉ាស៊ីននាឡិកាមកពីដីសើម ។ ម៉ាស៊ីនគេទំនើប ។ គេលើកឧបសគ្គបច្ចេកទេសជាច្រើន ។ ខាងនយោបាយនិងខាងការទូតយល់ព្រម តែខាងបច្ចេកទេស គេលើកឧបសគ្គ ។ គេលើកថាគេមក៣ខែហើយ តែមិនទាន់បានលទ្ធផលអី ។ សន្និដ្ឋានៈ គេមិនចង់លំបាក ២យ៉ាងធំៈ ១) ដីសើម ២) បញ្ហាឡចំហាយ» ។

២) ចំពោះការធ្វើព្រលានយន្តហោះវិញ ការប្រជុំគណៈអចិន្ត្រៃយ៍បានលើកឡើងថា «វាលយន្តហោះ សមមិត្តខៀវ រាយការណ៍ៈ នៅពង្រត្រូវចាក់គ្រួសច្រើន ។ គាត់(សុន សេន) សួរយើងថាដុះប្រក់អី? ធ្វើម៉េចកុំឲ្យក្តៅ ។ ពួកខែដី ក៏បានមកដល់ហើយដែរ» ។

ក្នុងកិច្ចប្រជុំនេះ មតិចុងក្រោយរបស់គណៈអចិន្ត្រៃយ៍បានសម្រេចថា «លើកគោលការណ៍ ធ្វើនៅជិតភ្នំពេញ ឲ្យហៅថាជារោងជាងជួសជុល ។ ធ្វើការងារសតិអារម្មណ៍ដល់កម្មាភិបាលនិងយុទ្ធជន ។ ផ្លូវចេញចូលតាមសំរោង ។ តែត្រូវស្ងាត់បំផុត» ។

បញ្ហាការពារប្រទេសគឺជាបញ្ហាមួយសំខាន់ជាអាទិភាពទី១ និងលាក់ការណ៍យ៉ាងសម្ងាត់បំផុតសម្រាប់របបកម្ពុជាប្រជា-ធិបតេយ្យ ។ នួន ជា អនុលេខាបក្សកុម្មុយនិស្តកម្ពុជា បានថ្លែងនៅក្នុងសេចក្តីថ្លែងការណ៍របស់បក្សកុម្មុយនិស្តកម្ពុជាចំពោះបក្សពលករដាណឺម៉ាក នាខែកក្កដា ឆ្នាំ១៩៧៨ ដោយលើកឡើងថា «ប្រសិនបើយើងអាចការពារដោយសុវត្ថិភាពនូវផលប្រយោជន៍របស់ប្រទេសនោះ យើងក៏ចូលរួមវិភាគទានក្នុងការតស៊ូនៅក្នុងសកលលោកទាំងមូលដែរ» ។ នួន ជា បានសង្កត់ធ្ងន់ក្នុងសេចក្តីថ្លែងការណ៍នេះដែរថា «នៅក្នុងដំណាក់កាលក្រោយរំដោះនេះ ការងារសម្ងាត់ គឺជាការងារសំខាន់ ។...ការងារសម្ងាត់ដែលយើងធ្វើគឺសំខាន់ទាំងអស់ ។ ឧទាហរណ៍ការជ្រើសរើសកម្មាភិបាលឲ្យមកដឹកនាំការងារ គឺធ្វើទៅដោយសម្ងាត់ ។ កន្លែងដែលថ្នាក់ដឹកនាំយើងរស់នៅ គឺសម្ងាត់ ។ យើងលាក់ការណ៍សម្ងាត់ទាំងការប្រជុំនិងទីកន្លែងនិងកិច្ចការផ្សេងទៀត ។ ទីមួយគឺជាគោលការណ៍ទូទៅ ហើយទីពីរ គឺជាវិធីការពារខ្លួនកុំឲ្យខ្មាំងជ្រៀតចូល ។ ដរាបណានៅមានការតស៊ូវណ្ណៈឬការតស៊ូប្រឆាំងនឹងចក្រពត្តិនិយម ការងារសម្ងាត់នៅតែសំខាន់រហូត ។ មានតែតាមរយៈការសម្ងាត់នេះទេ ដែលយើងអាចធ្វើម្ចាស់លើសភាពការណ៍និងយកជ័យជម្នះលើខ្មាំងសត្រូវដែលមិនដឹងថាអ្នកណាជាអ្នកណា» ។

**ថ្លង សុភារិទ្ធ**

# ទួលពិឃាតនៅស្រុកអូររាំងឪ

ស្រុកអូររាំងឪ ជាស្រុកមួយក្នុងចំណោមស្រុកទាំង១៨ ដែលស្ថិតនៅខាងជើងឆៀងខាងកើតទីរួមខេត្តកំពង់ចាម ។ ស្រុកអូររាំងឪស្ថិតក្នុងភូមិភាគបូព៌ាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ខ្ញុំបានធ្វើដំណើរទៅកាន់ស្រុកអូររាំងឪ ដើម្បីស្រាវជ្រាវនូវទីតាំងប្រល័យពូជសាសន៍និងមន្ទីរសន្តិសុខមួយចំនួន ។ ពត៌មានទីតាំងប្រល័យពូជសាសន៍មានទាំងអស់១២កន្លែងក្នុងឃុំចំនួន៦ ។ ទីតាំងប្រល័យពូជសាសន៍និងមន្ទីរសន្តិសុខទាំង១២កន្លែងនេះត្រូវបានកត់ត្រានិងចងក្រងតាមប្រពន្ធ័ផ្កាយរណបនូវលេខកូដភូមិសាស្រ្ត រយៈកម្ពស់ និងរយៈទទឹងនៃទីតាំងនីមួយៗ ។

ខាងក្រោមនេះជាសេចក្តីបរិយាយលម្អិតស្តីអំពីពត៌មានដែលទទួលបានមកពីការសម្ភាសន៍ជាមួយសាក្សីនូវទីតាំងទាំង១២កន្លែងៈ

## ឃុំព្រះធាតុ

***១) អណ្តូងជន្ទៅស៊ាន លេខកូដភូមិសាស្រ្តៈ០៣១១០៤***

***ចំណុចខ្សែស្របៈ*** (N) ១១° ៥០' ៥៨:១៩"

***រយៈបណ្តោយៈ*** (E) ១០៥° ២៩' ៣៨:៨០"

អណ្តូងជន្ទៅ ស៊ាន គឺជាអណ្តូងរបស់ជន្ទៅម្នាក់ឈ្មោះ ស៊ាន ដែលល្បីឈ្មោះក្នុងទសវត្សរ៍ឆ្នាំ៦០ថាជាអ្នកដែលមានដីធ្លីច្រើនរាប់ហិកតានៅឃុំព្រះធាតុ ។ ជន្ទៅ ស៊ានបានស្លាប់នៅឆ្នាំ១៩៨៣ ដោយសារមានជំងឺប្រចាំកាយដែលបន្សល់ទុកតាំងពីជំនាន់ខ្មែរក្រហមមកម្ល៉េះ ។ ដីស្រែចម្ការមួយភាគធំរបស់ជន្ទៅ ស៊ាន ត្រូវបានរដ្ឋដកហូត និងចែកចាយឲ្យទៅប្រជាជនមួយចំនួនទៀតដែលគ្មានដីធ្លី ។ ជន្ទៅ ស៊ាន នៅសល់ដីមួយឡូតិ៍តែប៉ុណ្ណោះ សម្រាប់ទុកឲ្យកូនពីរនាក់របស់គាត់ដើម្បីប្រកបរបរដាំដំណាំចិញ្ចឹមជីវិត ។ នៅក្នុងជំនាន់ខ្មែរក្រហម ផ្ទះរបស់ជន្ទៅ ស៊ាន ត្រូវបានរឹបអូសយកធ្វើជាមន្ទីរសន្តិសុខ ។ ដីមួយឡូតិ៍ដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីផ្ទះសន្តិសុខនោះ ត្រូវបានជ្រើសរើសយកធ្វើជាកន្លែងសម្លាប់មនុស្ស ព្រោះមានអណ្តូងទឹកចំនួនពីរដែលត្រូវបានប្រើប្រាស់ជារណ្តៅកប់សាកសព ។ លោកតា ស៊ាន សុខា ដែលត្រូវជាកូនប្រុសរបស់ជន្ទៅ ស៊ាន អាយុ៥៤ឆ្នាំ ទីលំនៅសព្វថ្ងៃនៅភូមិថ្នល់កែង ឃុំព្រះធាតុ ស្រុកអូររាំងឪ ខេត្តកំពង់ចាម បានរៀបរាប់ប្រាប់អំពីការសម្លាប់មនុស្សនៅក្នុងអណ្តូងទឹករបស់ឪពុកគាត់ថា“ចម្ងាយពីអណ្តូងមួយទៅអណ្តូងមួយគឺឃ្លាតពីគ្នាប្រហែលជាង៣០ម៉ែត្រប៉ុណ្ណោះ ហើយមានសាកសពពេញៗអណ្តូង” ។ លោកតា ស៊ាន សុខា បានឲ្យដឹងថា វត្តព្រះធាតុក៏ត្រូវបានបំផ្លាញដោយខ្មែរក្រហម ព្រមទាំងយកទីតាំងវត្តទាំងមូលធ្វើជាជម្រកបណ្តោះអាសន្នសម្រាប់ដាក់ប្រជាជនជម្លៀសមកពីភ្នំពេញ ។ កុដិនានាក្នុងវត្តត្រូវបានរុះរើមកធ្វើជារោងបាយសម្រាប់អ្នកជម្លៀស ។ ប្រជាជនមកពីភូមិត្រពាំងនាង និងភូមិថ្នល់កែងត្រូវបានបង្ខំឲ្យទៅរុះរើព្រះវិហារវត្តព្រះធាតុ ។ លោកអ៊ឹ ទុយ ជាប្រជាជនរស់នៅភូមិថ្នល់កែង បាននិយាយថា គាត់ធ្លាប់បានចូលរួមក្នុងការរុះរើកុដិនៅក្នុងវត្តព្រះធាតុនេះដែរ ។ គាត់បន្តថាសៀវភៅធម៌និងសាស្រ្តាស្លឹករិតជាច្រើនត្រូវបានដុតបំផ្លាញចោល ។ មានព្រះសង្ឃជាច្រើនអង្គត្រូវបានផ្សឹកក្រោមការបង្ខិតបង្ខំ ។

ព្រះសង្ឃព្រះនាម រស់ ហេង សព្វថ្ងៃជាគ្រូសូត្រស្តាំនៅវត្តព្រះធាតុ បានមានពុទ្ធដីកាបញ្ជាក់អំពីការផ្សឹកនេះថា “មានព្រះសង្ឃប្រហែលជាង២០អង្គត្រូវបានផ្សឹក គ្រាន់តែសឹកបណ្តោះគ្នាម្តងពីរ ម្តងបី ម្តងមួយអ៊ីចឹងទៅ ។ អាត្មាបានសឹកនៅឆ្នាំ១៩៧៥ ខែអាសាធ ត្រូវនឹងថ្ងៃទី៧” ។ ព្រះតេជគុណ រស់ ហេង បានមានពុទ្ធដីកាបន្តថា “អាត្មាត្រូវតែសឹក ព្រោះបើមិនដូច្នេះទេនឹងអាចត្រូវទណ្ឌកម្ម” ។ មានព្រះសង្ឃ១អង្គទៀតព្រះនាម អ៊ី ត្រូវបានពួកខ្មែរក្រហមចាប់សម្រាតស្បង់ជីពរចេញពីខ្លួនដោយសារព្រះសង្ឃអង្គនោះដាច់ខាតមិនព្រមសឹក ។ ប៉ុន្តែទីបំផុតការផ្សឹកនៅតែបានសម្រេចដោយសារមានបទបញ្ជាគំរាមព្រះសង្ឃគ្រប់អង្គថានឹងយកទៅដាក់គុក“៣-២” ដែលជាគុករបស់ស្រុកអូររាំងឪ ។ ការផ្សឹកព្រះសង្ឃនេះស្ថិតនៅក្រោមការ

ពិនិត្យយ៉ាងច្បាស់លាស់ពីឈ្មោះ ពេជ្រ ឋានៈជាមេបញ្ជាការកងទ័ពនៅភូមិភាគបូព៌ា ។ ពេជ្រ តែងតែដើរជាមួយ សោ ភឹម ដែលលេខាភូមិភាគបូព៌ា ។ វត្តអារាម ត្រូវបិទលែងឲ្យមានការគោរពសាសនា និងការអុជធូបទៀនបន់ស្រន់នានាត្រូវហាមឃាត់ដាច់ខាត ។ ថ្ងៃសីល ឬថ្ងៃបុណ្យទានម្តងៗតាមប្រពៃណី ប្រជាជនខ្លះបានលួចអុជធូបទៀននៅតាមផ្ទះយ៉ាងលួចលាក់ជាទីបំផុត ។ ការប្រជុំជីវភាពកើតមានឡើងនៅរៀងរាល់មួយសប្តាហ៍ម្តង ដែលមានគណៈឃុំ ឬគណៈសហករណ៍ជាអ្នកបើកអង្គប្រជុំ ។ ទិសដៅក្នុងអង្គប្រជុំ គឺពង្រឹងសមត្ថភាពការងារ និងធ្វើឲ្យទាល់តែបាននូវផែនការធ្វើស្រែមួយហិកតាទទួលផលស្រូវពី៣ទៅ៤តោន ។ ប្រជាជនម្នាក់ៗប្រឹងគ្មានពេលសម្រាក ពេលយប់មិនហ៊ានដេកគ្នាព្រោះអស់កម្លាំងនិងម៉្យាងទៀតខ្លាចកងឈ្លបដែលតែងតែមកលបស្តាប់ការសន្ទនាផ្សេងៗពីប្រជាជន ។ តួនាទីរបស់កងឈ្លបប្រចាំសហករណ៍នៅឃុំព្រះធាតុត្រូវបានលោកពូ ស៊ាន សុខា និយាយប្រាប់ថា “ពេលថ្ងៃពួកវាដេក និងពេលយប់ដើរស៊ើបការណ៍” ។ វត្តព្រះធាតុ បានក្លាយជាទីលានសម្រាប់ស្តុកប្រជាជនមកពីទីក្រុងភ្នំពេញ និងមកពីកន្លែងផ្សេងៗទៀតចំនួនប្រហែលជា១៥០គ្រួសារ ។ លោកពូ ស៊្រុយ ប៊ុន សៀ អាយុ៥៩ឆ្នាំ សព្វថ្ងៃរស់នៅភូមិទួលព្នៅ ឃុំព្រះធាតុបានអធិប្បាយប្រាប់ថា គាត់ត្រូវបានជម្លៀសចេញទៅនៅខេត្តកំពង់ធំកាលពីចុងឆ្នាំ១៩៧៨ ដោយពួកខ្មែរក្រហមខាងនិរតីចោទគាត់ថា “ក្បាលយួនខ្លួនខ្មែរ” ។ លោកពូបានមានប្រសាសន៍បន្តថា នៅក្នុងវត្តព្រះធាតុមានប្រជាជនមកស្នាក់នៅច្រើនណាស់ មានទាំងកូន ទាំងចៅដែលជម្លៀសមកពីភ្នំពេញ ។ ការងាររបស់អ្នកជម្លៀស គ្មានថ្ងៃណាទំនេរឡើយ ប្រឹងដើម្បីប្តូរមកវិញនូវរបបអាហារមិនគ្រប់គ្រាន់ ។ ការហូបចុកនិងដើរហើររបស់ប្រជាជនមកពីទីក្រុងភ្នំពេញសុទ្ធតែមានការពិនិត្យពិច័យនិងយាមកាមយ៉ាងត្រឹមត្រូវបំផុតពីប្រធានកង មិនដូចប្រជាជនមូលដ្ឋានទេ ។ ប៉ុន្តែទោះបីជាយ៉ាងនេះ ការសម្លាប់នៅតែកើតឡើងដោយមិនរើសមុខ ។ ប្រជាជនមកពីទីក្រុងភ្នំពេញទាំងអស់ត្រូវបានបណ្តើរយកមកសម្លាប់ទាំងខ្សែៗនៅក្នុងអណ្តូងដង្កោសាន ។ ហេតុការណ៍សម្លាប់មនុស្សនេះត្រូវបានលោកពូ ស៊ាន សុខា រៀបរាប់ថា គាត់បានឃើញស្ទើររាល់ថ្ងៃនូវការបណ្តើរមនុស្សមកសម្លាប់ម្តងបួន ម្តងប្រាំនាក់នៅក្នុងអណ្តូងរបស់ឪពុកគាត់ នៅក្នុងពេលដែលគាត់កំពុងបំពេញការងារជាមួយបងប្អូន៦ទៀតនៅលើដីចម្ការមួយដែលឃ្លាតតែប្រមាណជិត១០០ម៉ែត្រប៉ុណ្ណោះពីកន្លែងសម្លាប់ ។ អ្នកទោសទាំងនោះមិនត្រូវបានសម្លាប់ភ្លាមៗទេ គឺត្រូវរង់ចាំការប្រមូលឲ្យបានច្រើនសិន ទើបធ្វើការសម្លាប់តែម្តង ។ រាល់ការសម្លាប់ម្តងៗតែងតែមានចាក់ចម្រៀងបដិវត្តន៍តាមមីក្រូឮរំពងព្រៃធ្វើឲ្យអារម្មណ៍ប្រជាជនដែលកំពុងធ្វើការងារ ជាពិសេសលោកពូ ស៊ាន សុខា នឹកគិតដល់ជីវិតរបស់ខ្លួនទៅថ្ងៃក្រោយ តើអាចថែរក្សាបាន ឬទៅជាយ៉ាងណា ។ ការសម្លាប់ច្រើនប្រព្រឹត្តទៅនៅម៉ោង៣រសៀល ។ សំឡេងមីក្រូបានបញ្ចប់នៅពេលដែល


ស៊ាន សុខា (កូនដង្កោសាន)

ការសម្លាប់នោះបានចប់សព្វគ្រប់ ។ អាវុធមិនត្រូវយកមកធ្វើជាឧបករណ៍សម្លាប់ទេ ។ ប្រជាជនដែលខ្មែរក្រហមបានយកមកសម្លាប់នៅក្នុងអណ្តូងនេះត្រូវបាននាំមកពីកន្លែងផ្សេងៗទៀតក្នុងឃុំព្រះធាតុ បូករួមទាំងប្រជាជនថ្មីដែលមានទីលំនៅបណ្តោះអាសន្ននៅក្នុងវត្តព្រះធាតុផង ។ ចំណែកប្រជាជនមូលដ្ឋានក៏មានការសម្លាប់ដូចគ្នាដែរ ប៉ុន្តែលុះត្រាតែអ្នកនោះមានកំហុស ។ ការសម្លាប់ប្រជាជនមូលដ្ឋានគឺតម្រូវឲ្យជីករណ្តៅដោយខ្លួនឯងរួចទើបវាយទម្លាក់ក្នុងរណ្តៅនោះ ។ ប្រជាជនមូលដ្ឋានដែលបានមកស្លាប់នៅទីតាំងចម្ការចេកជិតអណ្តូងតាស៊ាននេះ សុទ្ធតែមិនដឹងថាខ្លួនមានកំហុសអ្វីឡើយ ។ លោកអ៊ឹំ ធុច ទុយ អាយុ៦៤ឆ្នាំដែលត្រូវជាឪពុកបង្កើតរបស់នារីពេទ្យខ្មែរក្រហមម្នាក់ដែលត្រូវបានខ្មែរក្រហមយកទៅសម្លាប់បានរៀបរាប់ថា «កូនស្រីរបស់ខ្ញុំគ្មានកំហុសអ្វីទេ សូម្បីតែនិយាយស្តីអ្វីឲ្យប៉ះពាល់ដល់បដិវត្តន៍បន្តិចក៏គ្មានដែរ ។ ខំតែធ្វើការក្នុងមន្ទីរពេទ្យគ្មានពេលទំនេរឡើយ» ។ ចំណែកក្មួយស្រីរបស់លោកពូ ស៊ាន សុខា ម្នាក់អាយុ១៨ឆ្នាំ ត្រូវបានសម្លាប់ដោយមិនដឹងមូលហេតុអ្វីទាល់តែសោះ ។ គាត់និយាយបន្តថា ក្មួយស្រីគាត់បានទទួលបញ្ជាឲ្យទៅរៀនសូត្របន្ថែមពីមុខជំនាញពេទ្យ ប៉ុន្តែតាមពិតជាការបោកបញ្ឆោត ។ នាងត្រូវបានបង្ខំឲ្យជីករណ្តៅដោយខ្លួនឯងនៅក្នុងព្រៃចេកមួយក្នុងដីឡូតិ៍ តា ស៊ាន ហើយបន្ទាប់ត្រូវបានសម្លាប់ដោយដំបងរបស់ខ្មែរក្រហម ។ តាមប្រសាសន៍របស់លោកពូ ស្រ៊ុយ ប៊ុន សៀ ថាមានព្រះញាតិវង្សមួយព្រះអង្គព្រះនាម «ទ្រង់កន្តុល» បានមកស្លាប់នៅក្នុងបរិវេណវត្តព្រះធាតុនេះដោយជំងឺ ។ អ្នកទោសដែលត្រូវបានយកមកដាក់នៅវត្តព្រះធាតុនេះ ភាគច្រើនជាស្ត្រីដែលជាប្រពន្ធទាហាននិងអ្នកជាប់និន្នាការជាមួយនឹងរបបសាធារណរដ្ឋខ្មែរ ។ បុរសជាប្តីត្រូវបញ្ជូនទៅកាន់វតដំរិល ដើម្បីធ្វើការសារ ។ លោកអ៊ឹំ ធុច ទុយ បានប្រាប់ថាក្រោយពីបានប្រមូលប្រជាជនមកដាក់នៅវត្តព្រះធាតុនៅចុងឆ្នាំ១៩៧៦ ខ្មែរក្រហមបានចាប់ផ្តើមបំបែកបុរសៗដែលជាប្តីចេញពីប្រពន្ធ ។ នៅចុងឆ្នាំ១៩៧៨ស្ត្រីទាំងនោះត្រូវមកបញ្ចប់ជីវិតនៅអណ្តូងតាស៊ាន ទាំងអស់ ។ លោកពូ ស្រ៊ុយ ប៊ុន សៀ បាននិយាយបន្តថា អ្នកដែលបណ្តើរនិងសម្លាប់ប្រជាជនចោលនៅអណ្តូងតាស៊ាន គឺជាខ្មែរក្រហមមកពីភូមិភាគនិរតី ។ លោកពូ សៀ បន្ថែមថា ការសម្លាប់មនុស្សប្រើរយៈពេលតែជាងកន្លះ


វត្តដំរិល អតីតមន្ទីរសន្តិសុខរបស់ខ្មែរក្រហម

ខែប៉ុណ្ណោះ ហើយមានចាក់ទឹកអាស៊ីតពីលើសាកសពដើម្បីកុំឲ្យស្អុយនិងកុំឲ្យហើមទៀតផង ។ ចំពោះការប៉ាន់ស្មានចំនួនជនរងគ្រោះនៅពាសពេញដីធ្លីរបស់អតីតដង្កោស៊ាន លោកតា ធុច ទុយ លោកអ៊ំ ស្រ៊ុយ ប៊ុន សៀ និងលោកតា ស៊ាន សុខា បាននិយាយប្រហាក់ប្រហែលគ្នាថា មានចំនួនពី៧០០ទៅ៨០០នាក់ ។

## ឃុំដំរិល

### ២) ទីតាំងសន្តិសុខ និងកន្លែងសម្លាប់វត្តដំរិល លេខកូដភូមិសាស្ត្រ: ០៣១១០៥

**ចំណុចខ្សែស្រប:** (N) ១១° ៤៩' ១៥:២៩"

**រយៈបណ្តោយ:** (E) ១០៥° ៣៧' ៤០:៨៨"

**មន្ទីរសន្តិសុខ**

កុដិធំនៃវត្តដំរិលមួយដែលសង់ពីបេតុងប្រក់ក្បឿងស្ថិតនៅចំហៀងខាងជើងព្រះវិហារ ត្រូវបានខ្មែរក្រហមជ្រើសរើសយកធ្វើជាមន្ទីរសន្តិសុខ ។ ជនរងគ្រោះភាគច្រើន មុននឹងត្រូវសម្លាប់សុទ្ធតែបានឆ្លងកាត់ការឃុំខ្លួននៅមន្ទីរសន្តិសុខ រួចហើយទើបយកទៅសម្លាប់ជាក្រោយ ។

លោកតា សួស ស៊ីម អាយុ៦៧ឆ្នាំ មានទីលំនៅនៅភូមិដំរិលទី១ ឃុំដំរិល ស្រុកអូររាំងឪ បាននិយាយប្រាប់ថា នៅក្នុងរបបខ្មែរក្រហម គាត់គឺជាជាងដែកធ្វើកាំបិត ពូថៅ ចប ខ្វែវ នៅក្នុងទីតាំងវត្តដំរិល ។ គាត់បានឃើញនិងដឹងច្បាស់ថា ខ្មែរក្រហមបានយកកុដិធំនេះមកធ្វើជាទីតាំងសម្រាប់ស្តុកមនុស្សដែលបម្រុងនឹងសម្លាប់ចោល ។ ចំណែកលោកតា ឃួន ស៊ីម បានបញ្ជាក់ថា ទីតាំងវត្តដំរិលនេះត្រូវបានខ្មែរក្រហមយកធ្វើជាមូលដ្ឋានឃុំឃាំងអ្នកទោសនិងជាកន្លែងហូបចុកប្រចាំឃុំទាំងមូលផង ។ លោកតាបន្តថា កន្លែងឃុំឃាំងអ្នកទោសមានពីរកន្លែងក្នុងវត្តដំរិល គឺមួយនៅក្នុងកុដិធំ និងមួយទៀតនៅក្នុងសាលាបាលី ។ ប្រភេទជនរងគ្រោះដែលយកមកដាក់ស្តុកនៅវត្តនេះគឺជាប្រភេទប្រជាជនទូទៅ និងអ្នកដែលជាប់និន្នាការជាមួយរបបសាធារណរដ្ឋខ្មែរ ។ លោកតា ឃួន ស៊ីម បានមានប្រសាសន៍ថា គ្មានការធ្វើទារុណកម្មទៅលើអ្នកទោសទេ ។ អ្នកទោសទាំងអស់ត្រូវបញ្ជូនយកទៅសម្លាប់នៅកន្លែងមួយចំនួនជុំវិញបរិវេណវត្តដូចជា ១) នៅជាប់របងវត្តប៉ែកខាងលិចឆៀងខាងត្បូង ២) នៅទួលតាក្រៃដែលមានចម្ងាយប្រហែលជា១៥០ម៉ែត្រពីវត្ត ៣) ប៉ែកខាងត្បូងនៅទួលគ្រពាំងឈូកដែលមានចម្ងាយប្រហែល ១០០ម៉ែត្រ ៤) ប៉ែកខាងជើងវត្តដំរិល និង៥) នៅកន្លែងផ្សេងៗទៀត ។ មន្ទីរសន្តិសុខនេះបានបង្កើតឡើងតាំងពីឆ្នាំ ១៩៧៣ ហើយការសម្លាប់ក៏ចាប់ផ្តើមនៅឆ្នាំនេះដែរ ។

**ទីតាំងសម្លាប់ជាប់របងវត្តដំរិល**

ទីតាំងសម្លាប់នេះ ខ្មែរក្រហមបានសម្លាប់តែប្រភេទជនរងគ្រោះជាចៅសង្កាត់និងអ្នកដែលពាក់ព័ន្ធជាមួយសង្កាត់ ។ លោកតា ឃួន ស៊ីម បានបញ្ជាក់ថា ចៅសង្កាត់ដែលត្រូវសម្លាប់គឺជាចៅសង្កាត់របស់ខ្មែរក្រហមដូចគ្នា ប៉ុន្តែមានកំហុសរឿងអ្វីនោះ លោកតាមិនបានដឹងឡើយ ។ តាមការប៉ាន់ស្មានពីសាក្សីបានឲ្យដឹងថា នៅជាប់របងវត្តដំរិលនេះមានសម្លាប់ជនរងគ្រោះអស់១៥នាក់ ហើយកប់នៅក្នុងតែមួយរណ្តៅទេ ។

### ៣) ទីតាំងសម្លាប់ទួលតាក្រៃ លេខកូដភូមិសាស្ត្រ: ០៣១១០៦

**ចំណុចខ្សែស្រប:** (N) ១១° ៤៩'១៥៨:២៩"

**រយៈបណ្តោយ:** (E) ១០៥° ៣៧' ៣៦:៩៩"

ទួលតាក្រៃ គឺជាទួលមួយស្ថិតនៅចំកណ្តាលវាលស្រែដែលមានចម្ងាយប្រហែលពី១០០-១៥០ម៉ែត្រពីរបងវត្តដំរិលប៉ែកខាងត្បូង ។ ទួលតាក្រៃមានរណ្តៅចំនួន៤ ។ សាក្សីពីរនាក់បាននិយាយថា រណ្តៅនៅលើទួលតាក្រៃ តាមពិតជាលេណដ្ឋានរបស់ទាហានក្នុងពេលសង្គ្រាម ប៉ុន្តែលុះដល់តំបន់នេះធ្លាក់ក្នុងការកាន់កាប់របស់ខ្មែរក្រហម លេណដ្ឋាននេះបានក្លាយជាកន្លែងដាក់សាកសពមនុស្សទៅវិញ ។ លោកតា ស៊ីម បាននិយាយថា ការសម្លាប់មនុស្សនៅលើទីតាំងនេះមានចាប់តាំងពីឆ្នាំ១៩៧៣មកម្ល៉េះ ។ ប្រភេទជនរងគ្រោះភាគច្រើនជាទាហាន លន់ ណុល ដែលបាក់ទ័ព ហើយត្រូវចាប់ខ្លួនបាន ។ លោកតាបានបន្ថែមថា ចំពោះទាហានណាម្នាក់ដែលរបួស ហើយរត់មកលាក់ខ្លួននៅតាមផ្ទះរបស់បងប្អូន ឬសាច់ញាតិ ត្រូវខ្មែរក្រហមតាមមកចាប់យកទៅសម្លាប់ចោលភ្លាមៗដោយមិនចាំបាច់ឃុំឃាំងឡើយ ។ ការសម្លាប់ គឺប្រើដំបងជាឧបករណ៍ ។

លោកតា ឃួន ស៊ីម អាយុ៧៤ឆ្នាំ បានរៀបរាប់អំពីការសម្លាប់មនុស្សថា «ខ្ញុំគ្រាន់តែបានលបមើលឃើញពីចម្ងាយនូវ

ការសម្លាប់មនុស្សប៉ុណ្ណោះ» ។ ជារឿយៗ ខ្មែរក្រហមចាប់ផ្តើមសម្លាប់មនុស្សនៅម៉ោង៧-៨យប់ គឺជាពេលដែលស្ងាត់គ្មានមនុស្សឆ្លងកាត់ ។ មានព្រះរាជវង្សានុវង្សមួយព្រះអង្គក៏បានមកបញ្ចប់ជីវិតនៅក្នុងបរិវេណវត្តនេះដែរ គឺព្រះអង្គឫទ្ធិវង្ស ។ លោកតា ឃួន ស៊ឹម បានបញ្ជាក់ថា ព្រះអង្គឫទ្ធិវង្សនេះជាសាច់ញាតិផ្ទាល់ជាមួយទ្រង់កន្ទុល(ទ្រង់កន្ទុល ស្លាប់នៅឆ្នាំ១៩៧៥ នៅវត្តព្រះធាតុ ដោយជំងឺ) ។ លោកតាបន្តថា ពេលដែលខ្មែរក្រហមធ្វើទារុណកម្មមុនពេលសម្លាប់ព្រះអង្គឫទ្ធិវង្សបានស្រែកឮរហូតដល់ភូមិប្រជាជនរស់នៅ ។

**៤) ទីតាំងសម្លាប់ត្រពាំងឈូក និងត្រពាំងក្តាម លេខកូដភូមិសាស្ត្រៈ ០៣១១០៧**

**ចំណុចខ្សែស្របៈ** (N) ១១° ៤៩' ២០:៨០"

**រយៈបណ្តោយៈ** (E) ១០៥° ៣៧' ៤២:៥១"

ទីតាំងសម្លាប់ត្រពាំងឈូកស្ថិតនៅខាងខាងកើតឆៀងខាងជើងវត្តដំរិលប្រហែល១០០ម៉ែត្រ ។ បច្ចុប្បន្នទីតាំងនេះហាក់ដូចជាស្រះទឹកមួយដែលពុំមានទឹកទាល់តែសោះ ។ មានរណ្តៅកប់សាកសពចំនួន៥ ។ រណ្តៅទាំងនេះសុទ្ធតែបានដាក់មនុស្សពេញៗមុននឹងលុបដីទៅវិញ ។

ទីតាំងសម្លាប់ត្រពាំងក្តាមមានពីររណ្តៅដែរ ។ ទីតាំងនេះស្ថិតនៅខាងកើតឆៀងខាងជើងទីតាំងត្រពាំងឈូកប្រហែលជាង១០០ម៉ែត្រ ។ លោកតា ស៊ឹម បាននិយាយថា រណ្តៅទាំងពីរនៅត្រពាំងក្តាម គឺមានទំហំធំជាងគេបង្អស់ក្នុងបរិវេណវត្តដំរិលនេះ ។ លោកតាបានបន្តថា ការសម្លាប់មនុស្ស គឺមានតាំងពីក្មេងដែលមិនទាន់ចេះដើររហូតដល់ចាស់ជរា ។ ការសម្លាប់ច្រើនប្រើព្រនង់ជាឧបករណ៍ ។ ចំពោះជនរងគ្រោះដែលបានមកស្លាប់នៅទីនេះ គឺមានប្រជាជនមូលដ្ឋាន និងប្រជាជនថ្មី ។ ក្នុងពេលដែលលោកតាធ្វើការនៅក្នុងវត្តដំរិល លោកតាបានឃើញយោធាខ្មែរក្រហមបំផ្លាញវត្ត ជាពិសេសកុដិជាច្រើនត្រូវបានរុះរើចោលទាំងអស់ ហើយទុកតែកុដិធំមួយសម្រាប់ទុកដាក់អ្នកទោសតែប៉ុណ្ណោះ ។ ចំពោះការគោរពបូជាព្រះពុទ្ធសាសនាវិញ លោកតានិយាយថា គ្មាននរណាម្នាក់ហ៊ានចេញមុខទៅថ្វាយបង្គំព្រះនៅក្នុងព្រះវិហារឡើយ បានត្រឹមតែលួចថ្វាយបង្គំនៅតាមកន្លែងដែលស្ងាត់នៅតែប៉ុណ្ណោះ ។ ព្រះសង្ឃទាំងអស់នៅក្នុងវត្តត្រូវបានផ្សឹកក្រោមបញ្ជាដាច់ខាតមួយ ។

លោកពូ សាំង សៀន អាយុ៥២ឆ្នាំ មានទីលំនៅភូមិចន្ទ័អណ្តែត ឃុំទួលទួលសុភី ស្រុកអូររាំងឪ បានរៀបរាប់ប្រាប់ថា ចំពោះការផ្សឹកព្រះសង្ឃ គឺសុទ្ធតែមានការគំរាមដោយភ្ជង់កាំភ្លើង ។ លោកពូបន្ថែមថាគាត់បានស្តាប់ឮផ្ទាល់នឹងត្រចៀកនូវពាក្យគំរាមយ៉ាងអសីលធម៌ជាច្រើនរបស់ខ្មែរក្រហមមកលើព្រះសង្ឃ ។ ព្រះពុទ្ធបដិមាករមួយចំនួនត្រូវបានខ្មែរក្រហមកប់ចោលក្នុងដី ។ ទីវត្តអារាមត្រូវបិទទ្វារ មានតែមនុស្សធ្វើការតែប៉ុន្មាននាក់ប៉ុណ្ណោះ ។ ក្រៅពីនេះមានតែកងឈ្លប កងសន្តិសុខក្នុងសម្លៀកបំពាក់ខ្មៅដើរចុះដើរឡើងពេញទីធ្លាវត្ត ។ នៅទីតាំងត្រពាំងឈូកមានសាកសពប្រមាណ៥០នាក់ និងនៅត្រពាំងក្តាមមានប្រមាណ៣៥នាក់ ។

## ឃុំចក

**៥) ទីតាំងសម្លាប់ទួលកន្ទួត លេខកូដភូមិសាស្ត្រៈ ០៣១១០៨**

**ចំណុចខ្សែស្របៈ** (N) ១១° ៤៧' ០០:២២"

**រយៈបណ្តោយៈ** (E) ១០៥° ៣៥' ៤២:២៩"

ខ្ញុំបានធ្វើដំណើរបន្តពីវត្តដំរិល ឃុំដំរិល តាមទិសដៅពីជើងទៅត្បូងប្រមាណ៩គីឡូម៉ែត្រតាមបណ្តោយផ្លូវជាតិលេខ៧៣ (ផ្លូវអភិវឌ្ឍន៍ជនបទ) មកដល់ខ្លោងទ្វារវត្តជ្រួល ឃុំចក បត់មកទិសខាងលិចឆ្ពោះមកកាន់វត្តជ្រួល ។ ទិសដៅរបស់ខ្ញុំគឺមិនចូលវត្តជ្រួលទេ ប៉ុន្តែធ្វើដំណើរសរសៀរតាមរបងវត្តឆ្ពោះមកទីតាំងសម្លាប់មួយឈ្មោះទួលកន្ទួត ។ ទីតាំងសម្លាប់ទួលកន្ទួតស្ថិតនៅខាងលិចវត្តជ្រួលប្រហែលជាងមួយគីឡូម៉ែត្រ ដែលស្ថិតនៅក្នុងភូមិជ្រួល ឃុំចក ស្រុកអូររាំងឪ ។ ទីតាំងនេះមានរណ្តៅសាកសពចំនួន២ ។ រណ្តៅទាំង២នេះស្ថិតនៅចម្ងាយពីគ្នាប្រហែល៣០ម៉ែត្រ ។ លោក អ៊ិន អៀន បាននិយាយប្រាប់ថា គាត់បានឃើញការសម្លាប់ស្ត្រីម្នាក់បន្ថែមពីលើមនុស្សដែលបានស្លាប់រួចហើយរាប់សិបនាក់ទៀត ។ ការសម្លាប់នោះ លោក អ៊ិន អៀន និយាយថា«អំពើដែលពួកខ្មែរក្រហមបានធ្វើមកលើជនរងគ្រោះ គឺសាហាវណាស់» ។ ស្ត្រីម្នាក់ត្រូវបានពួកខ្មែរក្រហមយកមែកឈើ(មែកសង្កែ) ទៅបុកលើទ្វារមាសរហូតដល់ស្លាប់ ។ ក្រោយការសម្លាប់

គាត់បានទៅពិនិត្យឃើញដាក់ស្តែងនូវមែកឈើដែលដោតជាប់ចំកណ្តាលថ្កុកឈាមដែលចេញពីរាងកាយស្ត្រីនោះ ។

លោកអ៊ឹ នៃ ហៃ អាយុ៦៥ឆ្នាំ ជាប្រជាជនរស់នៅភូមិព្រីង ឃុំចក បាននិយាយប្រាប់ថា ស្ត្រីដែលស្លាប់នោះត្រូវជាម្តាយមីងរបស់គាត់ ។ មុនដំបូងគាត់បានឃើញកន្ត្រកស្លាមួយដែលនៅលើស្មៅក្បែរសាកសពដែលមើលមិនស្គាល់ ។ លោកអ៊ឹ ហៃ បានសន្និដ្ឋានភ្លាមថា ពិតជាកន្ត្រកស្លារបស់ម្តាយមីងគាត់ ពីព្រោះគាត់ធ្លាប់ឃើញម្តាយមីងគាត់ប្រើវារាល់ថ្ងៃ ។ លោកអ៊ឹ បានបន្តថា ការសម្លាប់មនុស្សនៅទួលកន្ទួតនេះមានសម្លាប់តែប្រពន្ធ កូន សាច់ញាតិ ឬមនុស្សដែលពាក់ព័ន្ធជាមួយនឹងពួកកម្មាភិបាលដែលក្បត់នឹងអង្គការបដិវត្តន៍ដោយបំបែកកម្មាភិបាលរូបនោះចេញពីប្រពន្ធកូន ហើយកុហកថាឲ្យទៅរៀនសូត្រនៅកន្លែងផ្សេង ។ ក្រោយពីបំបែកមិនបានប៉ុន្មានដងប្រពន្ធកូននៅឯផ្ទះក៏ត្រូវដឹកយកមកសម្លាប់ទាំងអស់នៅទួលកន្ទួតនេះ ។ ការសម្លាប់ប្រព្រឹត្តនៅចុងឆ្នាំ១៩៧៨ ។

លោកអ៊ឹ នៃ ហៃ បានប្រាប់ទៀតថា គាត់បានឃើញផ្ទាល់ភ្នែកនូវសាកសពយ៉ាងរដូករណែលគរលើគ្នា ហើមរលួយស្អុយ ចូលទៅជិតមិនបាន ។ លោកអ៊ឹបញ្ជាក់ថា មូលហេតុដែលគាត់អាចចូលមកលបមើលបាន គឺមកពីខ្មែរក្រហមទៅប្រជុំនៅអូររាំងឪ ម្យ៉ាងទៀតគាត់ភ្ជួរនៅជិតទីតាំងនោះផង ។ លោកអ៊ឹមានចិត្តខឹងប្រឡោតយ៉ាងខ្លាំងចំពោះខ្មែរក្រហមដែលបានសម្លាប់បងប្អូនគាត់ ប៉ុន្តែមិនអាចធ្វើអ្វីបានត្រឹមតែលាក់ទុកក្នុងចិត្ត ។ ជនរងគ្រោះដែលបានស្លាប់នៅលើទួលកន្ទួតនេះមានចំនួនប្រមាណ៤៣នាក់ ។

**៦) ទីតាំងសម្លាប់ចំការគាសន លេខកូដភូមិសាស្ត្រៈ ០៣១១០៩**

**ចំណុចខ្សែស្របៈ** (N) ១១° ៤៦' ៥០:១១"

**រយៈបណ្តោយៈ** (E) ១០៥° ៣៥' ៤០:៤៥"

ខ្ញុំបានធ្វើដំណើរចេញពីទីតាំងសម្លាប់ទួលកន្ទួតឆ្ពោះមកទិសខាងត្បូងតាមបណ្តោយផ្លូវលំក្រោយរបងវត្តជ្រួលប្រមាណជាងមួយគីឡូម៉ែត្រ ហើយមកដល់ទីតាំងសម្លាប់មួយទៀតឈ្មោះថា ចំការគាសន ។ បច្ចុប្បន្នទីតាំងនេះស្ថិតនៅវាលស្រែដាច់ឆ្ងាយពីភូមិប្រជាជនរស់នៅ ។ លោកអ៊ឹ សូ ជន់ អាយុ៦៨ឆ្នាំ ជាមន្ត្រីចូលនិវត្តន៍បានឲ្យដឹងថា នៅចំការគាសននេះមានរណ្តៅមួយខ្សែដែលលាតសន្ធឹងពីកើតទៅលិចប្រវែងប្រហែលជាង១០ម៉ែត្រ ត្រូវខ្មែរក្រហមយកធ្វើជាកន្លែងកប់ជនរងគ្រោះ ។ លោកអ៊ឹបញ្ជាក់ថា រណ្តៅសាកសពនេះជាលេណដ្ឋានរបស់កងទ័ព ស-២០៤ សម្រាប់លាក់ខ្លួនកុំឲ្យយន្តហោះទម្លាក់គ្រាប់បែកមកពីលើ ។ លោកអ៊ឹបានបន្តថា មាននារីម្នាក់ ឈ្មោះ សា បានត្រូវសម្លាប់នៅក្នុងរណ្តៅនេះដោយមូលហេតុខ្លួនជានិរសារដែលបានក្បត់នឹងអង្គការ ។ ក្រោយពីសម្លាប់នារីនិរសា ខ្មែរក្រហមបានសម្លាប់មនុស្សជាច្រើនបន្តទៀត ។ អ្នកដែលបានសម្លាប់នៅទីនេះសុទ្ធតែត្រូវចោទប្រកាន់ថាជាសេ.អ៊ី.អា ។ ជនរងគ្រោះមុននឹងយកមកសម្លាប់នៅក្នុងលេណដ្ឋានកងទ័ពនៅចម្ការគាសននេះ គឺបានយកមកឃុំឃាំងនៅក្នុងរោងម៉ាស៊ីនកិនស្រូវមួយកន្លែងដែលស្ថិតមិនឆ្ងាយប៉ុន្មានពីទីតាំងនេះ ។ មានម្នាក់ទៀតឈ្មោះ សៀត បានសម្លាប់នៅក្នុងរណ្តៅនៃចម្ការគាសនដែរ ដោយសារខ្មែរក្រហមចោទថាសេអ៊ីអា ។ លោកអ៊ឹប្រាប់ថា សៀត នេះជាអ្នកដែលមានគុណសម្បត្តិច្រើនក្នុងជួរបដិវត្តន៍របស់ខ្មែរក្រហម ប៉ុន្តែទីបញ្ចប់ត្រូវមកបញ្ចប់ជីវិតនៅលើចម្ការគាសនដដែល ។ ទីតាំងសម្លាប់នៅចម្ការគាសន មានរណ្តៅចំនួន៦ និងសាកសពចំនួនប្រមាណ១៨នាក់ ។ ***(នៅមានត)***

**ផេង ពង្សរ៉ាស៊ី**

# សេចក្តីកែតម្រូវ

នៅក្នុងទស្សនាវដ្តី "ស្វែងរកការពិត" លេខ១០ អត្ថបទមួយដែលមានចំណងជើងថា "សៀវភៅខ្មៅ" ត្រង់ទំព័រទី៤១ កូឡោនទី១ បន្ទាត់ទី២៣-២៤ៈ សូមកែឃ្លាថា "ឲ្យដាក់ឈ្មោះ" ទៅជា "យក" ហើយពី"ឆ្នាំ១៦៤៣" ទៅជា "ឆ្នាំ១៦៥៣" ។ កូឡោនទីពីរ បន្ទាត់ក្រោមបង្អស់ប្តូរពី "ឆ្នាំ១៨៣៧" ទៅ "ឆ្នាំ១៨៤៧" ។ ទំព័រទី៤២ កូឡោនទី២ បន្ទាត់ទី៩ សូមប្តូរពី "កោះគាង" មក "កោះត្រល់" និងបន្ទាត់ទី១៣ "៥០០០" ទៅជា "៦៥.០០០"វិញ ។

*សូមអរគុណ!*



រណ្តៅសាកសពជនរងគ្រោះ

# ទិន្នន័យទីតាំងរួមនៃអំពើប្រល័យពូជសាសន៍

## ការធ្វើផែនទីវាលពិឃាតនៃប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩៥-២០០០

| លរ | លរទីតាំង | ឈ្មោះទីតាំង | ទិន្នន័យរណ្តៅនិងជនរងគ្រោះតាមជាក់ស្តែង | | ទិន្នន័យរណ្តៅនិងជនរងគ្រោះតាមរបាយការណ៍ | | របាយការណ៍ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|
| | | | ចំនួនស្នានរណ្តៅ | ចំនួនស្នានជនរងគ្រោះ | ចំនួនស្នានរណ្តៅ | ចំនួនស្នានជនរងគ្រោះ | |
| ១៥៦ | ០៥០១០១ | ព្រៃធ្នង់ | ៨ | ៣០០ | លើសពី៨ | ៣០០ | ១៩៩៧ |
| ១៥៧ | ០៥០១០២ | ទួលតាលាប់ | ១០០ | ៣០០០ | លើសពី១០០ | ប្រហែល៣០០០ | ១៩៩៧ |
| ១៥៨ | ០៥០១០៣ | ភូមិខ្ទីប | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១៥៩ | ០៥០១០៤ | ភូមិខ្ទីប | ១២០ | ៤០០-៥០០០ | ១០០-១៥០ | ៤០០-៥០០០ | ១៩៩៧ |
| ១៦០ | ០៥០១០៥ | វត្តបសេដ្ឋចាស់ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១៦១ | ០៥០២០១ | អំពែភ្នំ | ១៥០ | ៤០០០ | គ្មាន | ៤០០០ | ១៩៩៧ |
| ១៦២ | ០៥០២០២ | វត្តអំពែភ្នំ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១៦៣ | ០៥០២០៣ | បន្ទាយរោងគោ | ៩ | ៥៤០០ | លើសពី៨០ | ២៤០០-៣០០០ | ១៩៩៧ |
| ១៦៤ | ០៥០២០៤ | អំពែភ្នំ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១៦៥ | ០៥០៣០១ | សាលាខុដ្ឌកមានជ័យ | ៨០-១០០ | ៣៥០០-៤០០០ | ៨០-១៥០ | ៣៥០០-៥០០០ | ១៩៩៧ |
| ១៦៦ | ០៥០៣០២ | វត្តខុដ្ឌកមានជ័យ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១៦៧ | ០៦០១០១ | វត្តបារាយណ៍ដាន់ដែក | ២០០ | ១៥០០០ | ១៥០-២០០ | ១៥០០០-២០០០០ | ១៩៩៧ |
| ១៦៨ | ០៦០១០២ | វត្តបារាយណ៍ដាន់ដែក | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១៦៩ | ០៦០១០៣ | វត្តបារាយណ៍ដាន់ដែក | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១៧០ | ០៦០១០៤ | វត្តទួល | ៤ | ៦០០ | ៤ | ៦០០ | ១៩៩៧ |
| ១៧១ | ០៦០១០៥ | វត្តទួល | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១៧២ | ០៦០១០៦ | វត្តទួល | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១៧៣ | ០៦០២០១ | វត្តស្រង៉ែ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១៧៤ | ០៦០២០២ | ព្រៃឃ្លាំងមឿង | ៥០ | ១៥០០ | ៥០ | ១៥០០ | ១៩៩៧ |
| ១៧៥ | ០៦០២០៣ | ព្រៃដងវែង | ៤០០ | ៣៥០០ | ៤០០-៥០០ | ៣៥០០ | ១៩៩៧ |
| ១៧៦ | ០៦០៣០១ | វត្តក្តីដូង | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១៧៧ | ០៦០៣០២ | វត្តក្តីដូង | ៤ | ៦០៨ | លើសពី៣ | ៦០៨ | ១៩៩៧ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៧៨ | ០៦០៧០១ | អកឆក | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១៧៩ | ០៦០៧០២ | ព្រៃខកញ៉ា | ១០០ | ៤០០-៥០០ | ១០០ | ៤០០-៥០០ | ១៩៩៧ |
| ១៨០ | ០៦០៧០៣ | ឈូកគួយ | ១៥ | ៩០០-១០០០០ | ១០-១៥ | ៩០០០-១០០០០ | ១៩៩៧ |
| ១៨១ | ០៦០៧០៤ | ឈូកគួយ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១៨២ | ០៦០៧០៥ | វត្តតាំងក្រសាំង | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១៨៣ | ០៦០៧០៦ | ព្រៃមុំធ្លក | ១០ | ១៥០ | ១០-១៥ | ប្រហែល១៥០ | ១៩៩៧ |
| ១៨៤ | ០៧០១០២ | មន្ទីរតាម៉ន | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១៨៥ | ០៧០១០៣ | មន្ទីរតាម៉ន | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១៨៦ | ០៧០១០៤ | ព្រៃតាកុយ | ១៣៦ | ៣២០៤៧ | ១៣៦ | ប្រហែល៣២០៤៧ | ១៩៩៧ |
| ១៨៧ | ០៧០១០៥ | ព្រៃដើមវត្ត | ២៥ | ៤០០ | ២៥ | ប្រហែល៤០០០ | ១៩៩៧ |
| ១៨៨ | ០៧០១០៦ | វត្តស្រែជា | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១៨៩ | ០៧០១០៧ | មន្ទីរតាម៉ន | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១៩០ | ០៧០៦០១ | ភ្នំកំពង់ត្រាច | ១ | ២០០-៣០០ | គ្មាន | ៣០០ | ១៩៩៧ |
| ១៩១ | ០៧០៦០២ | ព្រៃកោះលោក | ៣០ | ២១០០ | ២០-៣០ | ប្រហែល២១០០ | ១៩៩៧ |
| ១៩២ | ០៧០៦០៣ | ភូមិចិនមាន | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១៩៣ | ០៨០៦០១ | វត្តស្វាយអណ្តែត | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១៩៤ | ០៨០៦០២ | វត្តស្វាយអណ្តែត | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១៩៥ | ០៨០៦០៣ | ក្បាលកោះ | ១ | ៦០-៧០ | គ្មាន | គ្មាន | ១៩៩៧ |
| ១៩៦ | ០៨០៦០៤ | ភូមិថ្នូវត្រី | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១៩៧ | ០៨០៦០៥ | វត្តសំពៅផ | ១ | ៦០-៧០ | គ្មាន | ៥០ | ១៩៩៧ |
| ១៩៨ | ០៩០៤០១ | ដោតញ្ញាណ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១៩៩ | ១៤០៣០១ | ត្រពាំងត្នោត | ៧៣ | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ២០០ | ១៤០៣០២ | ទួលម្រេញ | គ្មាន | គ្មាន | ប្រហែល៧២ | ប្រហែល៤០០០ | ១៩៩៧ |
| ២០១ | ១៤០៤០១ | សាលាស្វាយរមៀត | ៩៣ | ១៧១៦ | ៩២-៩៣ | ១៧១៦ | ១៩៩៧ |
| ២០២ | ១៤០៤០២ | ព្រៃទួលចាក់ប្រាស | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ២០៣ | ១៤០៤០៣ | ព្រៃទួលចាក់ប្រាស | ៣០ | ៥០០ | ២០-៣០ | ១០០-២០០ | ១៩៩៧ |
| ២០៤ | ១៤០៤០៤ | សាលាស្វាយល្មៀត | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |

**(នៅមានត)**

តួលេខដែលចុះផ្សាយក្នុងលេខនេះសម្រាប់ខេត្តកំពង់ស្ពឺ កំពង់ធំ កំពត កណ្តាល កោះកុង និងព្រៃវែង ។

◆ ចំពោះពត៌មានដែលដាក់ថា "គ្មាន" មានន័យថាពុំមានសាក្សីឬតួលេខ ប៉ុន្តែវត្តមានទីតាំងបានមកពីប្រភពផ្សេង ។

◆ ចំពោះពត៌មានជាក់ស្តែងនិងពត៌មានតាមរបាយការណ៍ មានន័យខុសគ្នាត្រង់ថា ពត៌មានជាក់ស្តែងគឺបានមកពីសាក្សីដែលបញ្ជាក់ប្រាប់នៅទីតាំងកើតហេតុ ។ ពត៌មានតាមរបាយការណ៍មានន័យថា សាក្សីផ្សេងទៀតដែលប្រាប់តួលេខអំពីទីតាំងដដែល ។

# អតីតលេខាទី២នៃស្ថានទូតកម្ពុជាប្រចាំនៅគុយបា

*ហៃ គីមស៊ាង គឺជាអតីតលេខាធិការទី២ ទូតរណសិរ្ស នៃរាជរដ្ឋាភិបាលរួមរួមជាតិកម្ពុជាប្រចាំនៅប្រទេសគុយបាក្នុងឆ្នាំ១៩៧១ ។ គីមស៊ាង មានវាសនាមិនខុសពីអ្នកការទូត និងនិស្សិតមួយចំនួនទៀតដែលបានចេញទៅរៀននៅប្រទេសសូវៀតក្នុងទសវត្សរ៍ឆ្នាំ៦០ប៉ុន្មានឡើយ ។ បន្ទាប់ពីត្រឡប់ចូលក្នុងប្រទេសកំណើតខ្លួនវិញ អ្នកការទូត និងនិស្សិតទាំងអស់នោះ ភាគច្រើនត្រូវបានខ្មែរក្រហមចោទថាជាភ្នាក់ងារសម្ងាត់ កា.ហ្សេ.បេ ហើយត្រូវបានចាប់ខ្លួនយកមកសួរចម្លើយនិងសម្លាប់ចោល ។*

*«កា.ហ្សេ.បេ» គឺជាពាក្យកាត់របស់ភាសារុស្ស៊ីដែលវិវត្តចេញមកពីឆេកា ។ ឆេកា គឺជាកម្លាំងប៉ូលីសសម្ងាត់មួយក្រុមដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩១៧ ។ បន្ទាប់មក អង្គភាពនេះមានឈ្មោះហៅច្រើនផ្សេងៗទៀត ។ នៅក្នុងឆ្នាំ១៩៥៤ ការផ្លាស់ប្តូរឈ្មោះនេះត្រូវបានកំណត់ដោយដាក់លាក់មកដល់សព្វថ្ងៃនេះ គឺកា.ហ្សេ.បេ* Komitet Gosudarstvennoi Bezopasnosti (KGB) *។* KGB *មានន័យជាភាសាអង់គ្លេសថា* Committee for State Security *ប្រែជាភាសាខ្មែរថា«គណៈកម្មាធិការសម្រាប់សន្តិសុខរដ្ឋ» ។ កា.ហ្សេ.បេ ជាភ្នាក់ងារស៊ើបការណ៍សម្ងាត់របស់ប្រទេសសូវៀត ។ ហៃ គីមស៊ាង បានចូលអង្គការ កា.ហ្សេ.បេ នៅឆ្នាំ១៩៦៥នៅទីក្រុងមូស្គូ ប្រទេសសូវៀតតាមរយៈឈ្មោះ ស៊ៀហ្គេ វ៉ាស៊ីលីវិច ដែលជាភ្នាក់ងារកា.ហ្សេ.បេ ។*

*តើ ហៃ គីមស៊ាង មានទំនាក់ទំនងជាមួយកា.ហ្សេ.បេយ៉ាងដូចម្តេច? ហេតុអ្វីបានជា ហៃ គីមស៊ាង ត្រូវបានខ្មែរក្រហមចោទថាជាភ្នាក់ងារម្នាក់របស់កា.ហ្សេ.បេ? ហើយតើនរណាខ្លះដែលត្រូវពាក់ពន្ធ័នឹងចម្លើយរបស់ជនរងគ្រោះរូបនេះ?*

## ប្រវត្តិដើមរបស់ហៃគីមស៊ាង

*ហៃ គីមស៊ាង ភេទប្រុស អាយុ៣២ឆ្នាំ(នៅក្នុងឆ្នាំ១៩៧៧) ជាតិខ្មែរ ។ គីមស៊ាង មានស្រុកកំណើតនៅភូមិទន្លេបិទឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។ នៅឆ្នាំ១៩៦៣ គីមស៊ាង បានចេញទៅសិក្សានៅប្រទេសសូវៀត ។ ចាប់តាំងពីឆ្នាំ១៩៦៨ដល់ឆ្នាំ១៩៧០ គីមស៊ាង បានចូលសិក្សានៅមហាវិទ្យាល័យឋាមពលនៅទីក្រុងមូស្គូ ។ នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧០ គីមស៊ាង បានធ្វើដំណើរទៅទីក្រុងប៉េកាំងប្រទេសចិន ក្រោយពីមានព្រឹត្តិការណ៍រដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ។ ប្រពន្ធរបស់ គីមស៊ាង ឈ្មោះ សម្បត្តិ គីរីវ៉ាត់ ។ អ្នកទាំងពីរបានរៀបការនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៧០ ។ ចាប់តាំងពីខែកុម្ភៈ ឆ្នាំ១៩៧១ដល់ខែឧសភា ឆ្នាំ១៩៧៦ គីមស៊ាង បានទៅធ្វើការនៅស្ថានទូតកម្ពុជាប្រចាំនៅប្រទេសគុយបា ។ នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៧៦ គីមស៊ាង បានធ្វើដំណើរវិលត្រឡប់មកដល់ទីក្រុងប៉េកាំងប្រទេសចិនវិញ ។ គីមស៊ាង បានចូលមកដល់ ទីក្រុងភ្នំពេញនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៧៦ ។ នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៧៦ គីមស៊ាង ត្រូវបានអង្គការចាប់ខ្លួនបញ្ជូនមកមន្ទីរ ស-២១(គុកទួលស្លែង) ។*

### មូស្គូ សហភាពសូវៀតៈ

*នៅខែកញ្ញា ឆ្នាំ១៩៦៣ ហៃ គីមស៊ាង ទទួលបានអាហារូបករណ៍សូវៀតខាងគរុកោសល្យ ហើយបានចេញទៅសិក្សានៅទីក្រុងមូស្គូនៃសហភាពសូវៀតជាមួយនិស្សិតខ្មែរ៥រូបទៀត គឺ តាន់ ឆៃហេង, គ្រិន លាន, ទី យ៉ាវ, ចាន់ បិន និង តិប ឆៃអៀមដួរ ។ នៅខែតុលា ឆ្នាំ១៩៦៣ និស្សិតទាំងអស់នេះបានចូលរៀនភាសារុស្ស៊ីនៅមហាវិទ្យាល័យរៀបចំនិស្សិតបរទេសនៃសាកលវិទ្យាល័យមូស្គូ ។ ដោយមាននិន្នាការនយោបាយនិងអត្តចរិតផ្ទុយគ្នា ក្រុមនិស្សិតទាំងនេះត្រូវបានបែកចេញជាពីរក្រុម ។ ក្រុមទី១ រួមមាន តាន់ ឆៃ ហេង, គ្រិន លាននិង ហៃ គីមស៊ាង ។ ក្រុមទី២ រួមមាន ទី យ៉ាវ, ចាន់ បិន និង តិប ឆៃអៀមដួរ ។ នៅចុងឆ្នាំ១៩៦៣ ហៃ គីមស៊ាង បានចូលជាសមាជិក«សហភាពខេមរនិស្សិត»ដែលជាសមាគមនិស្សិតតែមួយគត់នៅសភាពសូវៀតក្នុងសម័យនោះ ។ ប៉ុន្មានថ្ងៃបន្ទាប់មក តាន់ ឆៃ ហេង បានណែនាំឲ្យ ហៃ គីមស៊ាង ស្គាល់ឈ្មោះ ហាក់*

ស៊ាង ឡាយនី, អៀង សីហា និង ប៉ែន ថៅងអាន ។ អ្នកទាំងបីរូបនេះបានបញ្ចុះបញ្ចូល ហៃ គីមស៊ាង ឲ្យចូលក្នុង"ក្រុមនិស្សិតជឿនលឿន"នៃសហភាពខេមរនិស្សិត ។ ក្រុមនេះមានសមាជិកចំនួន១៥នាក់ ដឹកនាំដោយ ប៉ែន ថៅង អាន ជាប្រធានសហភាពខេមរៈនិស្សិត និង ហាក់ ស៊ាង ឡាយនី ជាអនុប្រធាន ។ និន្នាការនយោបាយទូទៅគឺ"សូវៀតនិយម" ។ ប៉ែន ថៅង អាន មានការប៉ិនប្រសប់ក្នុងការចាត់តាំង ។ ហាក់ ស៊ាងឡាយនី មានការប៉ិនប្រសប់ខាងផ្នែកទ្រឹស្តី ។

### សកម្មភាពក្នុងក្រុម"និស្សិតជឿនលឿន"

នៅឆ្នាំ១៩៦៤ ហៃ គីមស៊ាង បានចូលរៀនក្នុងមហាវិទ្យាល័យវិជ្ជាពេលនៅទីក្រុងមូស្គូ និងបានរួមប្រាស្រ័យទាក់ទងជាមួយនិស្សិតខ្មែរមួយចំនួននៅក្នុងសមាគម"សហភាពខេមរនិស្សិត" ឬ"ក្រុមនិស្សិតជឿនលឿន" ។ ក្រុមនិស្សិតនេះត្រូវបានណែនាំឲ្យរៀនទ្រឹស្តី "ម៉ាក្សឡេនីន" ដោយសិក្សាក្នុងពីរអាទិត្យ ឬមួយខែម្តងទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ អ្នកណែនាំការពិភាក្សាក្នុងវគ្គនីមួយៗនៃការសិក្សាទ្រឹស្តីនេះគឺ ហាក់ ស៊ាងឡាយនី និង ប៉ែន ថៅងអាន ដែលបានលើកយកឧទាហរណ៍ច្រើនអំពីសហភាពសូវៀត ។ ដើម្បីឲ្យមានការឯកភាពក្នុងក្រុម "ក្រុមនិស្សិតជឿនលឿន" ចៀសវាងមិនយកទំនាស់រវាងចិន និងសូវៀតមកពិភាក្សានៅក្នុងអង្គប្រជុំទេ ។

ការសិក្សាទ្រឹស្តី"ម៉ាក្សលេនីន"នេះបានធ្វើឲ្យ ហៃ គីមស៊ាង យល់ឃើញថា "សហភាពសូវៀតជាមិត្តធំមួយរបស់ប្រជាជនគស៊ីប្រឆាំងនឹងចក្រពត្តិនិយមនិងអាណានិគមថ្មី-ចាស់" ។ ហៃ គីមស៊ាង មានការនឹកស្រមៃចង់ឲ្យប្រទេសកម្ពុជាក្លាយជាប្រទេសសង្គមនិយមសម្បូរសប្បាយ ប៉ុន្តែគ្មានទិសដៅអ្វីច្បាស់លាស់ឡើយ ។

ក្នុងសហភាពខេមរនិស្សិត ហៃ គីមស៊ាង ត្រូវបានជ្រើសរើសឲ្យធ្វើជាស្នងការខាងសង្គមកិច្ច វប្បធម៌ និងកីឡាដែលមានភារៈកិច្ចទទួលខុសត្រូវខាងតន្ត្រីប្រគុំនៅពេលមានការមមាញឹកម្តងៗក្នុងពិធីបុណ្យធំៗដូចជាបុណ្យឯករាជ្យជាតិ៩វិច្ឆិកាជាដើម ។

នៅឆ្នាំ១៩៦៥ សៀហ្គេ វ៉ាស៊ីលីវិច បានឲ្យ គីមស៊ាង ធ្វើជារៀមច្បងក្នុងក្រុមនិស្សិតបរទេសចំនួន១៣នាក់ដើម្បីពិនិត្យមើលថាតើនិស្សិតទាំងនេះចូលចិត្តសហភាពសូវៀត ឬទេ ហើយត្រូវរាយការណ៍ក្នុង១ អាទិត្យ ឬ១ខែម្តងដូចជារៀមច្បងក្នុងក្រុមឯទៀតៗដែរ ។

ការសិក្សាទ្រឹស្តីម៉ាក្ស-ឡេនីន បានប្រព្រឹត្តទៅជាហូរហែហូតដល់ឆ្នាំ១៩៦៩ ។ ដំបូងមានការសិក្សាទ្រឹស្តីនេះញឹកញាប់ណាស់ បន្ទាប់មកមានភាពរយាលស្ទើរបោះបង់ចោល ពីព្រោះនិស្សិតម្នាក់ៗជាប់រវល់រៀនសូត្រផ្ទាល់ខ្លួន ហើយសមាជិកដែលនៅសល់ទៀតសោតក៏កាន់តែតិចទៅៗ ។ ទោះបីជាមានសមាជិកតិចនិងគ្មានលក្ខន្តិកៈអ្វីក៏ដោយ ក្រុមនេះមានវិន័យនិងការចាត់តាំងជាលំនាំបក្សនយោបាយ ។ ការសម្ងាត់ត្រូវបានថែរក្សា ហើយតែងតែពិភាក្សាជារឿយៗដើម្បីរិះរកមាគ៌ានិងកម្មវិធីនយោបាយមួយ ប៉ុន្តែគ្មានបច្ច័យគ្រប់គ្រាន់ ។ ហៃ គីមស៊ាង គ្រាន់តែដឹងថា ទាំងអស់គ្នាឯកច្ឆន្ទក្នុងការកសាងប្រទេសសង្គមនិយមមួយដែលមានលក្ខណៈវិទ្យាសាស្ត្រ ។



នៅពេលមុនរដ្ឋប្រហារ១៨ មីនា ១៩៧០ ហៃ គីមស៊ាង បានលាឈប់ពី "សហភាពខេមរនិស្សិត" ហើយ បានចូលជាសមាគមនិស្សិតនិងអាណិកជនខ្មែរនៅសហភាពសូវៀតព្រមទាំងសុំចូលគណបក្សសង្គមរាស្ត្រនិយម ក្នុងគោលបំណងចង់វិលត្រឡប់ចូលមកប្រទេសខ្លួនវិញ ។

## ក្រោយរដ្ឋប្រហារ១៨មីនា១៩៧០

ក្រោយរដ្ឋប្រហារ ១៨ មីនា ១៩៧០ ហៃ គីមស៊ាង និងនិស្សិតខ្មែរ៣០រូបទៀតបានធ្វើញត្តិគាំទ្រសេចក្តីថ្លែងការណ៍ថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០របស់សម្តេចនរោត្តមសីហនុ ។ នៅចុងខែមីនា ឆ្នាំ១៩៧០ ឯកអគ្គរាជទូតខ្មែរនៅសូវៀតឈ្មោះ ជា សាន បានស្នើ ហេង ពេជ្រ និង ហៃ គីមស៊ាង ឲ្យទៅប៉េកាំង ដោយថ្លៃសំបុត្រយន្តហោះ គឺមហាវិទ្យាល័យមូស្គូជាអ្នកចំណាយ ។ មុននឹងចេញដំណើរទៅប៉េកាំង ហៃ គីមស៊ាង បានទៅជួបវ៉ាស៊ីលីវិច ទទួលបានដំបូន្មានផ្តែផ្តាំថា "ហាក់ ស៊ាងឡាយនី ក៏នៅជាមួយដែរ កុំភ្លេចពិគ្រោះគ្នាទៅវិញទៅមក" ។

## ក្រុងប៉េកាំង ប្រទេសចិនៈ

នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧០ ហៃ គីមស៊ាង ជាមួយនឹងខ្មែរពីររូបទៀត គឺ ជួន ម៉ុម និង សេង ចុងកាល បានមកដល់ទីក្រុងប៉េកាំង ។ ទស្សនៈរបស់ ហៃ គីមស៊ាង មានការផ្លាស់ប្តូរ ។ ការចាប់អារម្មណ៍របស់ ហៃ គីមស៊ាង នៅពេលមកដល់ប៉េកាំងដំបូង ធ្វើឲ្យកើតមានជាទំនាស់រវាងការរីកចម្រើនខាងសម្ភារវិទ្យាសាស្ត្របច្ចេកទេសនិងកម្រិតស្មារតីនយោបាយខ្ពស់ ។ ហៃ គីមស៊ាង ក៏យល់ និងឲ្យតម្លៃលើកម្រិតស្មារតីនយោបាយខ្ពស់ជាងកម្រិតសម្ភារ ។

ហៃ គីមស៊ាង ធ្លាប់ទៅស្ថានទូតសូវៀតប្រចាំនៅប៉េកាំងម្តងជាមួយ ហាក់ ស៊ាងឡាយនី ដើម្បីជួបអនុព័ន្ធវប្បធម៌ ហើយបានយកសំបុត្រមួយច្បាប់ដែលស្ថានទូតសូវៀតត្រូវប្រគល់ឲ្យស្ថានទូតខ្មែរនៅប៉េកាំង ។ ឆ្លៀតឱកាសនោះ ហាក់ ស៊ាងឡាយនី បានចូលជួបស្ងាត់ៗជាមួយអនុព័ន្ធវប្បធម៌ ហើយទុកឲ្យ ហៃ គីមស៊ាង នៅឈរចាំខាងក្រៅតែម្នាក់ឯង ។ ហាក់ ស៊ាងឡាយនី ខស្បាហ៍ជួបជាមួយអនុព័ន្ធវប្បធម៌ស្ថានទូតសូវៀតនេះណាស់ ប៉ុន្តែមិនដែលប្រាប់អំពីអ្វីដល់ ហៃ គីមស៊ាង ឡើយ ពីព្រោះ ហាក់ ស៊ាងឡាយនី ពុំសូវទុកចិត្ត ហៃ គីមស៊ាង ។ ម្យ៉ាងទៀត ហាក់ ស៊ាងឡាយនី មិនសូវសប្បាយចិត្តនឹង ហៃ គីមស៊ាង ដែលធ្វើជាអ្នកកាន់លុយកាក់ ហើយប្រកែកពុំព្រមធ្វើការនៅកន្លែងជាគន្លឹះដូចជាតំណែង លេខាធិការផ្ទាល់របស់សម្តេចប៉ែន នុត ជាដើម ។

ហៃ គីមស៊ាង ពុំសូវមានសកម្មភាពនយោបាយអ្វីទេនៅទីក្រុងប៉េកាំង ពិសេសបន្ទាប់ពីគាត់បានរៀបការប្រពន្ធរួចមក ។ នៅពេលនោះ ហៃ គីមស៊ាង ជាគណនេយ្យករនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោមការទទួលខុសត្រូវរបស់ ជួន ម៉ុម ។ នៅចុងឆ្នាំ១៩៧០ ស៊ាន អាន អគ្គរដ្ឋទូតកម្ពុជាប្រចាំទីក្រុងហាណូយប្រទេសវៀតណាម បានប្រាប់ គីមស៊ាង ថា "ពួកសូវៀតខិតខំដើរទាក់ទងអតីតនិស្សិតខ្មែរ ហើយសួរចង់ដឹងពីរណសិរ្សរួបរួមជាតិកម្ពុជា ។ ត្រូវប្រុងប្រយ័ត្នឲ្យមែនទែន" ។

## ក្រុងឡាហាវ៉ាន ប្រទេសគុយបាៈ

ហេតុដែលនាំឲ្យ ហៃ គីមស៊ាង សុំផ្លាស់ទៅធ្វើការនៅប្រទេសគុយបា មានមូលហេតុបីៈ ១)សភាពការណ៍ស៊ើរតែអនាធិបតេយ្យក្នុងចំណោមខ្មែរនៅប៉េកាំង និងការចោទប្រកាន់លើប្រពន្ធរបស់ ហៃ គីមស៊ាង (អំពីជម្លោះផ្ទៃក្នុងរវាងខ្មែរនៅប៉េកាំង) បានធ្វើឲ្យបរិយាកាសកាន់តែអាប់អួរចំពោះ ហៃ គីមស៊ាង និងប្រពន្ធ ។ ២)បញ្ហាសិក្សាប្រពន្ធរបស់ ហៃ គីមស៊ាង ប្រសិនបើនៅប៉េកាំង គឺមិនបានរៀនសូត្រទេ និង៣)ក្រៅពីកិច្ចការបរទេស ខ្មែរៗនៅក្រសួងឯទៀតពុំសូវមានការងារធ្វើទេ ។ ដោយសារតែមូលហេតុទាំងបីខាងលើនេះ ទើប ហៃ គីមស៊ាង ដាក់ពាក្យសុំចូលធ្វើការនៅក្រសួងការបរទេស ហើយក្រសួងក៏បានយល់ព្រមតាមសំណើ និងបញ្ជូនទៅធ្វើការនៅស្ថានទូតខ្មែរប្រចាំនៅប្រទេសគុយបា ។

នៅទីក្រុងឡាហាវ៉ាន ប្រទេសគុយបា ហៃ គីមស៊ាង បានធ្វើការជាលេខាធិការទី២នៃស្ថានទូតរណសិរ្សរួបរួមជាតិកម្ពុជាប្រចាំប្រទេសគុយបា (ខែកុម្ភៈ ឆ្នាំ១៩៧១ដល់ខែខសភា ឆ្នាំ១៩៧៦) ។ នៅក្នុងសង្គ្រាមតស៊ូ ស្ថានទូតខ្មែរនៅឡាហាវ៉ានបានទទួលភារកិច្ចពីរយ៉ាងពីក្រសួងការបរទេសនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា គឺទី១)ធ្វើដូចម្តេចឲ្យគុយបាជួយគាំទ្រសកម្ម

ខាងផ្លូវទូតដល់ការតស៊ូរបស់ប្រជាជនកម្ពុជាប្រឆាំងនឹងអំពើឈ្លានពានរបស់ចក្រពត្តិអាមេរិក និងទី២) ទាក់ទងប្រទេសអាមេរិកឡាទីនឲ្យមានសមានចិត្តមកលើការតស៊ូរបស់ប្រជាជនកម្ពុជា ។

ក្នុងនាទីជាលេខាធិការទី២ ហៃ គឹមស៊ាង បានខិតខំបំពេញភារកិច្ចខាងលើនេះ ។ ហៃ គឹមស៊ាង បានទាក់ទងជាមួយអ្នកសារព័ត៌មាន អង្គការមហាជន ជាពិសេសជាមួយគណៈកម្មាធិការខាងសាមគ្គីភាពជាមួយវៀតណាម លាវ និងកម្ពុជា បក្សកុម្មុយនិស្តនិងក្រសួងការបរទេសដើម្បីសម្រួលដល់កិច្ចការរបស់ស្ថានទូតរហូតដល់ពេលរំដោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។

នៅឆ្នាំ១៩៧១ ជារយៈកាលដែលសូវៀតពុំសូវមានឥទ្ធិពលលើប្រទេសគុយបា ការទាក់ទងរវាងស្ថានទូតខ្មែរនិងមជ្ឈដ្ឋានគុយបានានាមានភាពមមាញឹកខ្លាំង ។ ប៉ុន្តែ ហៃ គឹមស៊ាង ពុំសូវមានសកម្មភាពអ្វីទេ ពីព្រោះគាត់ខ្វះបទពិសោធន៍ខាងការងារទូត ហើយម្យ៉ាងទៀតពុំសូវចេះភាសាបរទេសក្នុងការទំនាក់ទំនងការទូត ។

នៅឆ្នាំ១៩៧២ ឥទ្ធិពលប្រទេសសូវៀតបានជ្រួតជ្រាបទៅក្នុងប្រទេសគុយបាយ៉ាងខ្លាំងគ្រប់វិស័យទាំងអស់ ។ ដូច្នេះសកម្មភាពគាំទ្ររបស់ប្រទេសគុយបាមកលើការតស៊ូរបស់ប្រជាជនកម្ពុជាបានចុះថយជាលំដាប់ ។ ចាប់តាំងពីឆ្នាំ១៩៧២ ហៃ គឹមស៊ាង បានពង្រីងសកម្មភាពរបស់ខ្លួនឆ្ពោះទៅខាងសារព័ត៌មានក្នុងទិសដៅឲ្យកាសែតទាំងអស់ចុះផ្សាយពីជោគជ័យរបស់ប្រជាជនកម្ពុជាក្នុងសង្គ្រាមរំដោះជាតិរំដោះប្រជាជន ។ ហៃ គឹមស៊ាង បានស្គាល់យ៉ាងជិតស្និទ្ធជាមួយចាងហ្វាងសារព័ត៌មាន"យុវជនបះបោរ" និងអ្នកសារព័ត៌មានឯទៀតៗដែលធ្វើការខាងផ្នែកអាស៊ី ។

ក្រៅពីនេះ ហៃ គឹមស៊ាង មានការទាក់ទងជាមួយបក្សកុម្មុយនិស្តនិងទំនាក់ទំនងល្អជាមួយគណៈកម្មាធិការខាងសាមគ្គីភាពជាមួយវៀតណាម លាវនិងកម្ពុជា ។ តាមធម្មតា ស្ថានទូតកម្ពុជាមិនសូវមានទំនាក់ទំនងល្អជាមួយបក្សកុម្មុយនិស្តគុយបាដែលមាននិន្នាការនិយមសូវៀតនោះទេ ។ ខាងក្រសួងការបរទេសគុយបា ហៃ គឹមស៊ាង មានទំនាក់ទំនងល្អជាមួយអ្នកធ្វើការខាងផ្នែកអាស៊ី ។ ការងារអស់ទាំងនេះ គឺស្ថិតក្នុងទិសដៅមួយសម្រួលដល់កិច្ចការរបស់ស្ថានទូតរហូតដល់ពេលរំដោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ទោះបីជាសកម្មភាពរបស់ ហៃ គឹមស៊ាង មានភាពរង្គើលបន្តិចយ៉ាងណាក៏ដោយ ក៏ ហៃ គឹមស៊ាង នៅតែរក្សាបានមិត្តភាពជាមួយអ្នកដែលធ្លាប់ស្គាល់ពីមុនៗ ជាពិសេសក្នុងមជ្ឈដ្ឋានសារព័ត៌មានដែរ ។

នៅប្រទេសគុយបា ហៃ គឹមស៊ាង បានប្រាស្រ័យទាក់ទងជាមួយ ឡាសារេវ សេសិនកូ មានឋានៈជាទីប្រឹក្សាទូត, យូរីជាលេខាធិការទី៣ និង ទីម៉ូសិនកូ ជាលេខាធិការទូតទី១ ។ ការទាក់ទងរបស់ ហៃ គឹមស៊ាង ជាមួយទូតសូវៀតប្រចាំនៅគុយបា តែងតែប្រព្រឹត្តទៅនៅស្ថានទូតជាចំហ ។

ការទាក់ទងគ្នារវាង ហៃ គឹមស៊ាង និង រ៉ាអ៊ូល រ៉ាល់ដេសវីវ៉ូ អតីតឯកអគ្គរដ្ឋទូតប្រទេសគុយបាប្រចាំនៅកម្ពុជាមុនពេលរដ្ឋប្រហារ ពុំសូវមានភាពស្និទ្ធស្នាលទេ ។ ប៉ុន្តែបន្ទាប់ពី រ៉ាអ៊ូល រ៉ាល់ដេសវីវ៉ូ បានឡើងធ្វើជាសមាជិកគណៈកម្មាធិការកណ្តាលបក្សកុម្មុយនិស្តគុយបានៅខែធ្នូ ឆ្នាំ១៩៧៥ គាត់ក៏បានប្តូរអាកប្បកិរិយាមករាក់ទាក់ជាមួយ ហៃ គឹមស៊ាង វិញ ។

នៅឆ្នាំ១៩៧៦ រ៉ាអ៊ូល រ៉ាល់ដេសវីវ៉ូ បានប្រាប់ ហៃ គឹមស៊ាង ថា "បក្សសម្រេចដូរគណៈកម្មាធិការខាងសាមគ្គីភាពគុយបា-វៀតណាម កម្ពុជា និងលាវ ឲ្យទៅជាសមាគមមិត្តភាពគុយបា-វៀតណាម គុយបា-កម្ពុជា និងគុយបា-លាវវិញ" ។ ហៃ គឹមស៊ាង ក៏បានធ្វើសេចក្តីរាយការណ៍ទៅក្រសួងការបរទេស ។ ក្រោយមកទើប ហៃ គឹមស៊ាង ដឹងថា នេះជាឧបាយកលរបស់ខ្មាំង ។

នៅខែមេសា ឆ្នាំ១៩៧៦ មុនពេលដែល ហៃ គឹមស៊ាង ចេញពីប្រទេសគុយបា ក៏បានជួបជាមួយ រ៉ាអ៊ូល រ៉ាល់ដេសវីវ៉ូ ក្នុងរឿងជំពាក់ប្រាក់ចំនួនជាង១៥០០ដុល្លាអាមេរិក ។ ហៃ គឹមស៊ាង ត្រូវបាន រ៉ាអ៊ូល រ៉ាល់ដេសវីវ៉ូ គំរាមថានឹងបរិហារកេរ្តិ៍ឈ្មោះ និងមិនឲ្យចេញពីប្រទេសគុយបា បើពុំព្រមសងប្រាក់ទាំងអស់នោះទេ ។ រ៉ាអ៊ូល រ៉ាល់ដេសវីវ៉ូ បានដាក់លក្ខខ័ណ្ឌមួយជាថ្នូរប្រសិនបើជា ហៃ គឹមស៊ាង សុខចិត្តទទួលភារកិច្ចមួយមកធ្វើគឺពុំបាច់សងប្រាក់ទាំងនោះឡើយ ។ ទីបំផុតដោយសារតែរកប្រាក់សងមិនបាន ហៃ គឹមស៊ាង ក៏សុខចិត្តទទួលយកភារកិច្ចពី

វ៉ាអ៊ីល វ៉ាល់ដេសវីវ៉ូ មកធ្វើជាថ្នូរនឹងការជំពាក់ប្រាក់នោះ ។

នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧៦ នៅពេលជួបជាមួយ វ៉ាអ៊ីល វ៉ាល់ដេសវីវ៉ូ ហៃ គឹមស៊ាង ត្រូវបានពន្យល់ថា “ស្ថានការណ៍នៅប្រទេសកម្ពុជាសព្វថ្ងៃប្រៀបដូចជាកំប៉ុងមួយបិទគ្របជិត ទោះបីខំប្រឹងមើលពីគ្រប់ជ្រុងជ្រោយក៏ដោយ ក៏មើលមិនឃើញរបស់នៅក្នុងកំប៉ុងនោះដែរ ។ ស្ថានទូតបរទេសនៅភ្នំពេញត្រូវអង្គការតាមដានគ្រប់ជំហានរកតែទៅណាក៏មិនកើតដែរ” ។ វ៉ាអ៊ីល វ៉ាល់ ដេសវីវ៉ូ បានបន្តទៀតថា “បានគិតគូរយ៉ាងយូរពីបញ្ហានេះ ហើយសម្រេចប្រថុយសំណាងបន្តិចចុះក្រែងលោបានការ ហើយនេះជាឱកាសមួយដែរ ចំណែកឯភារកិច្ចដំបូងក៏មិនពិបាកប៉ុន្មានដែរសម្រាប់អ្នក គ្រាន់តែឲ្យប្រុងប្រយ័ត្នព្រោះស្ថានការណ៍ក្នុងប្រទេសថ្មី ហើយអ្នកធ្លាប់រស់នៅបរទេសជិត១៣ឆ្នាំហើយ ។ បានជាយើងជ្រើសរើសអ្នកជាភ្នាក់ងារព្រោះអ្នកធ្លាប់ធ្វើទូតមានលទ្ធភាពអាចធ្វើការនៅក្រសួងជាហេតុងាយស្រួលទាក់ទងជាមួយស្ថានទូតបរទេសនៅភ្នំពេញ ជាពិសេសស្ថានទូតគុយបា ម្យ៉ាងទៀតងាយស្រួលដល់ការទាក់ទងមជ្ឈដ្ឋានឯទៀតៗ ។ យើងពុំដែលធ្លាប់ឃើញសមត្ថភាពអ្នកផ្ទាល់ទេ ប៉ុន្តែឥឡូវគ្មានច្រកចេញណាមួយ ត្រូវចង់ដឹងចំណុចមួយមុនសន្និសីទកំពូលនៃប្រទេសមិនចូលបក្សសម្ព័ន្ធនៅកូឡុំបូ ។ ធ្វើដូចម្តេចប្រមូលពត៌មានឲ្យបានកន្លះខែមុនសន្និសីទ” ។

## ភារកិច្ចនិងផែនការអនុវត្តនៅកម្ពុជាៈ

ភារកិច្ចដំបូងដែល ហៃ គឹមស៊ាង ត្រូវអនុវត្តគឺ ១) សង្កេតស្ថានការណ៍ឲ្យបានហ្មត់ចត់ ២) ប្រសិនបើនៅក្រសួងការបរទេស ត្រូវទាក់ទងជាមួយ ហាក់ ស៊ាង ឡាយនី ប៉ុន្តែត្រូវប្រុងប្រយ័ត្ន ព្រោះ ហាក់ ស៊ាង ឡាយនី ចូលក្នុងប្រទេសយូរ គឺអាចមានការផ្លាស់ប្តូរ ។ បើមិនផ្លាស់ប្តូរ ពិគ្រោះផែនការជាមួយគ្នា ។ ៣) បើមិនជួប ហាក់ ស៊ាង ឡាយនី ឬមានការផ្លាស់ប្តូរពត៌មាននៅស្ថានទូតគុយបា ចូររង់ចាំបញ្ហាថ្មី ហើយឆ្លៀតសួរបណ្តើរៗពីខ្មែរឯទៀតៗ ។ ៤) ឆ្លៀតបំពេញភារកិច្ចបន្ទាន់ៗជាបណ្តើៗ ។ ៦) ទាក់ទងឲ្យប្រយ័ត្នមែនទែន ហើយត្រូវជ្រើសរើសអ្នកជំនិតបន្ថែមទៀត ។

ចំពោះភារកិច្ចទី១ សង្កេតស្ថានការណ៍ឲ្យបានហ្មត់ចត់ គឺត្រូវស៊ើបសួរប្រជាជននៅភូមិឬក្រសួង តើមានប៉ុន្មានភាគរយដែលចង់បានជំនួយបរទេស ជាពិសេសជំនួយសូវៀត ក្នុងពេលដែលប្រទេសឆ្លងកាត់ការលំបាកដូច្នេះ? ហើយតើនៅខែណាទើបខ្មែរក្រហមនឹងចាប់ផ្តើមចាយលុយវិញ? ភារកិច្ចទី១នេះមានរយៈពេលពី១ខែទៅ១ខែកន្លះ ដោយជ្រើសរើសភូមិឬក្រសួងពី១០ទៅ១៥ ។ លទ្ធផលនៃការអនុវត្តត្រូវប្រគល់ផ្ទាល់ទៅឲ្យលេខាធិការទី៣ ហើយចាំទទួលបញ្ជាមកវិញ ។

ក្រៅពីភារកិច្ចដំបូងទាំង៦ចំណុចខាងលើនេះ នៅមានភារកិច្ចបន្ទាន់ៗមួយចំនួនទៀតដូចជា រាយការណ៍ឲ្យបានច្បាស់អំពីស្ថានការណ៍នៅក្នុងប្រទេសកម្ពុជានៅឆ្នាំ១៩៧៦នៃការទាក់ទងតាមក្រសួងនិងតាមភូមិ ។ អំពីផែនការផលស្រូវបាន៣តោនក្នុងមួយហិកតារហូតដល់ខែធ្នូ ។ អំពីរបបហូបចុក ។ អំពីពេលវេលានៃការប្តូររបបគ្រប់គ្រងឲ្យបានឆាប់ ។ អំពីចំនួនអ្នកបច្ចេកទេសចិនចេញចូលនៅក្នុងកម្ពុជា ។ អំពីប្រាក់ខែដែលផ្តល់ឲ្យក្នុងវិស័យណាខ្លះ ជាប្រញាប់ ។ អំពីអ្នកដឹកនាំជាន់ខ្ពស់នៅក្នុងប្រទេសដោយភ្ជាប់នឹងប្រវត្តិរូបសង្ខេប ។ អំពីការស្លាប់ឬរស់របស់ ហ៊ូ យន់ ដោយបញ្ជាក់ពីមូលហេតុនិងកន្លែងធ្វើការនិងនាយករដ្ឋមន្ត្រីទី១ពិតប្រាកដ ។ អំពីចំនួនរោងចក្រដែលដំណើរការខាងវិស័យណាខ្លះនិងការប្រជុំជីវភាពនៅក្នុងរោងចក្រឬសហករណ៍ ជាការប្រញាប់ និងអំពីបញ្ហាដោះស្រាយទឹកនៅកម្ពុជាជាប្រញាប់ ហើយពត៌មាននេះត្រូវផ្តល់ទៅឲ្យលេខាធិការទី៣ផ្ទាល់ ។

ដើម្បីកុំឲ្យបែកការណ៍ ត្រូវរង់ចាំលទ្ធផលពីក្នុងប្រទេសកម្ពុជាសិន ទើបបញ្ជូនផែនការល្អិតល្អន់ជាក្រោយ នៅដើមឆ្នាំ១៩៧៧ តាមរយៈលេខាធិការទី៣ ហើយដើម្បីរៀបចំផែនការល្អិតល្អន់ ត្រូវមានកម្រិតស្មារតីប្រុងប្រយ័ត្នខ្ពស់បំផុត ។ ចំពោះផែនការជាគោលនេះមានទិសដៅដាក់ប្រទេសកម្ពុជាឲ្យចូលទៅក្នុងវង្វង់ឥទ្ធិពលសូវៀតខាងផ្នែកនយោបាយ សេដ្ឋកិច្ច និងយោធា ដោយមានរយៈពេលកំណត់ពី៥ទៅ១០ឆ្នាំ ហើយសំណូមពរឲ្យមានការអនុវត្តដែលត្រូវធ្វើតាមរបៀបសន្តិវិធីដោយយកនយោបាយ និងសេដ្ឋកិច្ចជាធំ ។ ក្នុងការអនុវត្តត្រូវបែងចែកជាបីផ្នែក ។ **(នៅមានត)** **ថ្លងសុភារិទ្ធ**

# កាលប្បវត្តិរបស់ហាណូយ
# (១៩៦០-១៩៧៨)

**(តចប់) ៣១ធ្នូ :** រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យបោះផ្សាយនូវសេចក្តីប្រកាសមួលបង្កាច់សាធារណរដ្ឋសង្គមនិយមវៀតណាម និងចោទថាមានផែនការយូរអង្វែងក្នុងការឈ្លានពានទឹកដីកម្ពុជា ព្រមទាំងចោទថាចង់បង្ខំឲ្យកម្ពុជាចូលក្នុងអ្វីដែលហៅថាសហព័ន្ធឥណ្ឌូចិនដែលដឹកនាំដោយវៀតណាមផ្ទាល់ ។ នៅថ្ងៃដដែលនោះដែរ ក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យប្រកាសផ្អាកជាបណ្តោះអាសន្ននូវទំនាក់ទំនងការទូតជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម ព្រមទាំងផ្អាកផ្លូវអាកាសភ្នំពេញ-ហាណូយថែមទៀត ។

សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាមបដិសេធការចោទប្រកាន់ខុសរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យដោយប្រកាសនូវការទន្ទ្រានចូលទឹកដីវៀតណាមពីសំណាក់កងទ័ពកម្ពុជា ព្រមទាំងស្នើឲ្យភាគីទាំងពីរជួបប្រជុំគ្នាឆាប់ៗតាមតែអាចធ្វើទៅបានទោះជាកិច្ចប្រជុំត្រូវរៀបចំក្នុងកម្រិតណាក៏ដោយ ដើម្បីដោះស្រាយបញ្ហាព្រំដែនរវាងប្រទេសទាំងពីរ ។ សេចក្តីថ្លែងការណ៍សង្កត់ធ្ងន់ថាជំហររបស់សាធារណរដ្ឋសង្គមនិយមវៀតណាមនៅលើបញ្ហានេះគឺចង់ដោះស្រាយបញ្ហានេះជាមួយកម្ពុជាប្រជាធិបតេយ្យដោយឈរលើគោលការណ៍គោរពបូរណភាពទឹកដីគ្នាទៅវិញទៅមក ស្របតាមការពង្រឹងនិងពង្រីកសាមគ្គីភាពនិងមិត្តភាពកិច្ចសហប្រតិបត្តិការជាបងប្អូន ដើម្បីបង្កើតព្រំប្រទល់មិត្តភាពយូរអង្វែងរវាងវៀតណាមនិងកម្ពុជាតាមលក្ខណៈស្មើភាព និងសមហេតុសមផល ។

## ១៩៧៨

**២ មករា :** ក្រុមប្រឹក្សាសន្តិភាពពិភពលោកគាំទ្រដោយឥតសំចៃចំពោះសេចក្តីប្រកាសរបស់សាធារណរដ្ឋសង្គមនិយមវៀតណាមថ្ងៃទី៣១ខែធ្នូ និងអំពាវនាវដល់រដ្ឋាភិបាលនានានៅលើពិភពលោកឲ្យប្រើឥទ្ធិពលរបស់ខ្លួនដើម្បីនាំមកនូវកិច្ចចរចារវាងវៀតណាមនិងកម្ពុជាឲ្យបានឆាប់ៗតាមតែអាចធ្វើទៅបាន ។

**៣ មករា :** រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋឥណ្ឌាមានប្រសាសន៍ថា លោកសង្ឃឹមថាជម្លោះរវាងវៀតណាមនិងកម្ពុជាអាចនឹងដោះស្រាយបានដោយសន្តិភាព គ្មានទំនោរទៅរកការប្រើកម្លាំងឡើយ ។

**៤ មករា :** សេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេសគុយបាគាំទ្រដល់ជំហររបស់រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាមនិងបក្សវៀតណាម អំពីបញ្ហាព្រំដែនរវាងប្រទេសវៀតណាមនិងប្រទេសកម្ពុជា ។

នៅក្នុងបទសម្ភាសន៍ជាមួយទីភ្នាក់ងារសារព័ត៌មានវៀតណាម វ.អិន.អា នាយករដ្ឋមន្ត្រីវៀតណាម ផាម វ៉ាន់ ដុងនៃសាធារណរដ្ឋសង្គមនិយមវៀតណាមបានថ្លែងថា “ដរាបណាប្រជាជនវៀតណាមស្រឡាញ់ឯករាជ្យនិងសេរីភាពរបស់ខ្លួនកាន់តែខ្លាំង ដរាបនោះប្រជាជនវៀតណាមគោរពឯករាជ្យនិងសេរីភាពរបស់កម្ពុជាកាន់តែខ្លាំងដែរ ។ យើងយល់ច្បាស់ណាស់ថាក្រោយពីមានការបង្ហូរឈាមអស់ជាច្រើនក្នុងបុព្វហេតុឯករាជ្យដែលទទួលបានមកវិញនោះ ប្រជាជនកម្ពុជាពិតជាស្រឡាញ់ណាស់ឯករាជ្យភាពការពារសាមគ្គីភាពរវាងប្រជាជាតិជាបងប្អូននិងមិនឲ្យចក្រពត្តិឬប្រតិកិរិយាណាមកបង្កការបែកបាក់និងបំផ្លាញសាមគ្គីភាពនេះបានឡើយ” ។

**៥ មករា :** សហព័ន្ធអ្នកសារព័ត៌មានអាមេរិកឡាទីនប្រកាសថា “យើងឈរខាងរដ្ឋាភិបាលនិងប្រជាជនវៀតណាម ហើយស្វាគមន៍ដល់សុឆន្ទៈរបស់សាធារណរដ្ឋសង្គមនិយមវៀតណាមក្នុងការកម្រិតភាពប្រទូសរ៉ាយនិងបញ្ចប់តាមរយៈការចរចា” ។



ទីក្រុងភ្នំពេញ ៧ មករា ១៩៧៩

**១៤ មករា ៖** យោងតាមទីភ្នាក់ងារសារព័ត៌មានវៀតណាម វ.អិន.អា បានឲ្យដឹងថា ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៨មក កងកម្លាំងប្រដាប់អាវុធកម្ពុជាបានបន្តវាយចូលទឹកដីវៀតណាម នៅក្នុងខេត្តអានហ្សាង ឡុងអាន ដុងថាប តាយនិញ...។ ជាងនេះទៅទៀត កងទ័ពកម្ពុជាថែមទាំងបានធ្វើប្រតិបត្តិការចូលវាយទន្ទ្រានទៀតផង ។ ការវាយប្រហារធ្ងន់ធ្ងរនោះគឺ នៅថ្ងៃទី ១១ ខែមករា ឆ្នាំ១៩៧៥ វេលាម៉ោង៥ព្រឹកដែលធ្វើឡើងដោយកងកម្លាំងប្រដាប់អាវុធកម្ពុជាពីរកងវរសេនាធំមកលើតំបន់នានា នៅតាមបណ្តោយស្ទឹង វិញតេ (ខេត្តអានហ្សាង) និងទន្លេប៊ីញឌី (ខេត្តកៀនហ្សាង) ចូលក្នុងទឹកដីវៀតណាមចម្ងាយ៨គីឡូម៉ែត្រ ។

**១៥ មករា ៖** ក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ ចេញសេចក្តីថ្លែងការណ៍មួយស្តីអំពីដែនទឹកតំបន់ត្រួតស៊ីគ្នា តំបន់សេដ្ឋកិច្ច និងខ្ពង់រាបបាតសមុទ្រកម្ពុជា ។ មាត្រាទី៦ចែងថា រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យត្រូវដោះស្រាយបញ្ហាជាមួយប្រទេសនានាដែលពាក់ព័ន្ធដោយយកសភាពការណ៍បច្ចុប្បន្នមកគិតគូរពិចារណា ។

**១៧ មករា ៖** នៅក្នុងសុន្ទរកថាក្នុងឱកាសពិធីរំឭកខួបបង្កើតកងទ័ពកម្ពុជា ប៉ុល ពត លេខាមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជា បានបរិហារវៀតណាមសាជាថ្មីហើយចោទប្រកាន់វៀតណាមថា "ចិញ្ចឹមចិត្តប្រឆាំងនឹងកម្ពុជា ហើយបម្រុងបង្កើតសហព័ន្ធឥណ្ឌូចិនដែលក្រោយពីបង្កើតហើយនឹងមានតែបក្សមួយ រដ្ឋមួយ និងប្រជាជនតែមួយ" ។

**១៩ មករា ៖** កម្ពុជាផ្តោងកាំភ្លើងធំរាប់រយគ្រាប់ជាលើកដំបូងទៅលើក្រុងចូវដុក និងជាយខេត្តតាយនិញ ។ ជនស៊ីវិលជាច្រើនត្រូវស្លាប់ និងផ្ទះជាច្រើនខ្នងត្រូវបំផ្លាញខ្ទេចខ្ទីអស់ ។

**២៧ មករា ៖** មានការរៀបចំសន្និសីទកាសែតមួយនៅទីក្រុងហូជីមិញដោយមន្ទីរព័ត៌មាននៃក្រសួងការបរទេសវៀតណាមស្តីអំពីសភាពការណ៍បញ្ហាព្រំដែនរវាងប្រទេសវៀតណាមនិងកម្ពុជា ។ អ្នកកាសែតវៀតណាមនិងអ្នកកាសែតបរទេសត្រូវបានបង្ហាញជូននូវឯកសារស្តីអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយភាគីកម្ពុជានិងអ្វីដែលបណ្តាលមកពីការញុះញង់បង្កឲ្យមានភាពប្រទូសរ៉ាយ ។ ក្រោយពីសន្និសីទនេះ អ្នកកាសែតបានចុះពិនិត្យដល់ទីកន្លែងកើតហេតុនិងមើលឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយកងកម្លាំងប្រដាប់អាវុធកម្ពុជា នៅក្នុងខេត្តអានហ្សាងនិងខេត្តតាយនិញ ។

**២៨ មករា ៖** សារព័ត៌មានរបស់បារាំងចំនួនបីៈ *L'Humanité,*

*Le Monde* និង *Le Quotidien de Paris* ចុះផ្សាយរបាយការណ៍របស់អ្នកឆ្លើយឆ្លងពត៌មានពិសេសស្តីអំពីភ័ស្តុតាងខក្រិដ្ឋកម្មរបស់កងកម្លាំងប្រដាប់អាវុធកម្ពុជានៅឃុំអានដូ (ខេត្តអានហ្សាង) ។

**១ មករា ៖** សេចក្តីថ្លែងការណ៍របស់សហព័ន្ធអន្តរជាតិនៃស្ត្រីប្រជាធិបតេយ្យគាំទ្រដល់ជំហរត្រឹមត្រូវរបស់រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម ទាក់ទងនឹងបញ្ហាព្រំដែនរវាងប្រទេសវៀតណាមនិងកម្ពុជា ។

**៥ មករា ៖** សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាមនិងសំណើ៣ចំណុចសុំឲ្យមានការដោះស្រាយគ្រប់បញ្ហាទាំងអស់ទាក់ទងនឹងទំនាក់ទំនងរវាងវៀតណាមនិងកម្ពុជា ÷

១) បញ្ឈប់រាល់សកម្មភាពប្រទូសរ៉ាយផ្នែកយោធានៅតំបន់ជាប់ព្រំដែន ។ កងកម្លាំងប្រដាប់អាវុធនៃភាគីនីមួយៗត្រូវដាក់ឲ្យឈរជើងនៅក្នុងទឹកដីរបស់ផងខ្លួនចម្ងាយ៥គីឡូម៉ែត្រពីព្រំដែន ។

២) ភាគីទាំងពីរត្រូវជួបប្រជុំមួយដងនៅទីក្រុងហាណូយ ឬនៅទីក្រុងភ្នំពេញ ឬនៅកន្លែងណាមួយនៅព្រំដែន ប្រយោជន៍ដើម្បីពិភាក្សានិងសម្រេចសន្ធិសញ្ញាលើការគោរពគ្នាទៅវិញទៅមកនិងសន្ធិសញ្ញាស្តីពីព្រំដែនរវាងប្រទេសទាំងពីរ ។

៣) ភាគីទាំងពីរត្រូវយល់ស្របគ្នាតាមទម្រង់សមរម្យដែលមានការធានា និងការត្រួតពិនិត្យជាអន្តរជាតិ ។

**៦ មករា ៖** រដ្ឋមន្ត្រីការបរទេស ង្វៀន ដុីជិញ នៃសាធារណរដ្ឋសង្គមនិយមវៀតណាមបានបញ្ជូនសេចក្តីថ្លែងការណ៍ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ១៩៧៨ របស់រដ្ឋាភិបាលវៀតណាមនេះ ជូនចំពោះអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ និងជូនចំពោះសមាជិករដ្ឋាភិបាលជាគណៈកម្មាធិការសម្របសម្រួលនៃប្រទេសមិនចូលបក្សសម្ព័ន្ធ ។

អនុរដ្ឋមន្ត្រីការបរទេសសហភាពសូវៀត ហ្វ្រីរីប៊ីន ដែលបញ្ជាក់ថាបានទទួលនូវសេចក្តីថ្លែងការណ៍ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ១៩៧៨របស់សាធារណរដ្ឋសង្គមនិយមវៀតណាមនោះ បានសម្តែងនូវការគាំទ្ររបស់ខ្លួនចំពោះសំណើសមហេតុសមផលនេះដែលចែងដោយភាគីវៀតណាមក្នុងគោលបំណងដោះស្រាយបញ្ហាទំនាក់ទំនងរវាងប្រទេសវៀតណាមនិងកម្ពុជាតាមរយៈការចរចា ។

**៨ កុម្ភៈ ៖** នាយករដ្ឋមន្ត្រី អាលី ណាស័រ មូហាម៉េត នៃសាធារណរដ្ឋប្រជាធិបតេយ្យយេមែន មានប្រសាសន៍ថារដ្ឋាភិបាលនិងប្រជាជនរបស់លោកយល់ស្របនិងគាំទ្រចំពោះសេចក្តីថ្លែងការណ៍របស់សាធារណរដ្ឋសង្គមនិយមវៀតណាម ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ១៩៧៨ ។

**៩និង១១ កុម្ភៈ ៖** កងកម្លាំងប្រដាប់អាវុធកម្ពុជាបានប្រើប្រាស់កាំណុង១២២និង១៣០មីលីម៉ែត្រ វាយលុកទីប្រជុំជននៅតាមជនបទនៃខេត្តតាយនិញ, ម៉ុកហ័រ(ឡុងអាន) ចូវដុក (អានហ្សាង) ហុងងូ(ដុងថាប) ។ គ្រាន់តែនៅទីរួមខេត្តតាយនិញតែមួយ មានមនុស្ស១០នាក់ត្រូវស្លាប់ និង៥០នាក់ទៀតត្រូវរងរបួស ។

**រាត្រីថ្ងៃទី១៣-១៤ កុម្ភៈ ៖** កងកម្លាំងប្រដាប់អាវុធកម្ពុជាចំនួន៤កងវរសេនាតូចវាយប្រហារមកលើឃុំញ៉ាន់ហ័យ ខាន់ប៊ិញ ខាន់អាន ភូហៀវ និងវិញសឿង ក្នុងខេត្តអានហ្សាង ដោយសម្លាប់រង្គាលជនស៊ីវិលអស់ជាច្រើននាក់ ។

**១៦ កុម្ភៈ ៖** កងកម្លាំងប្រដាប់អាវុធកម្ពុជាវាយទន្រ្ទានចូលទឹកដីវៀតណាមភាគខាងជើង កាទុំ នៃខេត្តតាយនិញ ។

**៣-៥ មីនា ៖** សេចក្តីថ្លែងការណ៍បោះផ្សាយដោយសន្និសីទសមាជិកសភាអន្តរជាតិមកពីប្រទេសចំនួន១៤ដែលត្រូវបានរៀបចំធ្វើឡើងនៅ ហែលស៊ីនគី ថ្លែងថា «យើងមានការសោកស្តាយណាស់ដែលថ្នាក់ដឹកនាំកម្ពុជាបានបដិសេធមិនព្រមចូលមកចរចាជាមួយភាគីវៀតណាមដើម្បីបញ្ចប់ភាពប្រទូសរ៉ាយឲ្យបានឆាប់បំផុត ។ ការបដិសេធនេះធ្វើឲ្យប៉ះពាល់ដល់មិត្តភាពរវាងប្រជាជាតិទាំងពីរនេះ ព្រមទាំងដល់សន្តិភាពនៅក្នុងផ្នែកមួយនៃទ្វីបអាស៊ី ហើយវាផ្តល់ប្រយោជន៍បានត្រឹមតែនាំឲ្យពួកចក្រពត្តិនិងប្រតិកិរិយាបំបែកបំបាក់ប៉ុណ្ណោះ ។ យើងយល់ស្របតាមជំហររបស់រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាមដូចដែលបានគូសបញ្ជាក់នៅក្នុងសេចក្តីថ្លែងការណ៍ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ និងថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ១៩៧៨» ។

# សមមិត្តនារីខ្មែរអ៊ីស្លាម

## មិនស្តាយនេកម្លាំងធ្វើបដិវត្តន៍ ប៉ុន្តែតូចចិត្តនឹងខាសនាបច្ចុប្បន្ន


ស៊ុន សុខា ១៩៧៣


ស៊ុន សុខា ២០០១

ស៊ុន សុខា ហៅ មូសា សុខា ជាអតីតសមមិត្តនារីប្រធាន "ចាស់បាល" ឬប្រធាន (សមាគមនារី) នៃរបបកម្ពុជាប្រជាធិបតេយ្យ ។ មុននឹងក្លាយជាប្រធានចាស់បាល សុខា ធ្វើជាប្រធានកុមារខាងផ្នែកសិល្បៈ ។ សុខា មានស្រុកកំណើតនៅភូមិដីមាន់ ឃុំក្រែក ស្រុកពញាក្រែក ខេត្តកំពង់ចាម ។ ម្តាយឈ្មោះ ម៉ាត់ ចៅ (ខ្មែរអ៊ីស្លាម) ឪពុកឈ្មោះ ស៊ុន ជា (ជនជាតិខ្មែរចូលសាសន៍ចាម) ។ សុខាមានកូន១៣នាក់ ហើយសព្វថ្ងៃនេះគាត់កំពុងមានផ្ទៃពោះកូនម្នាក់ទៀត ។ កូនរបស់គាត់៣នាក់បានរៀបចំគូស្រករួចហើយ ។ កូន៦នាក់នៅក្នុងបន្ទុកសព្វថ្ងៃ ។ កូន៤នាក់ទៀតស្លាប់នៅក្រោយពីចាប់កំណើតបានមួយខែ ឬមួយសប្តាហ៍ដោយសារជំងឺតម្កាត់ ។ ចូលដល់ឆ្នាំ២០០១នេះ សុខា មានអាយុ៤៣ឆ្នាំ ។ ប្តីរបស់គាត់មានអាយុ៤៥ឆ្នាំ មានឈ្មោះ ណុះ លាស់ ជាអតីតយុទ្ធជនជញ្ជូនគ្រាប់នៅក្នុងរបបខ្មែរក្រហម ។

សព្វថ្ងៃ សុខា ប្រកបមុខរបរចិញ្ចឹមជីវិតដោយដាំដំណាំពោត សណ្តែកនៅលើផ្ទៃដី២ហិកតាដែលបានកម្រៃបន្តិចបន្តួចផ្គួបផ្សំនឹងប្រាក់ចំណូលបន្ទាប់បន្សំពីប្តីដែលជាកម្មករចៀរជ័រកៅស៊ូឲ្យក្រុមហ៊ុនចម្ការកៅស៊ូស្នួល ។ សុខា ចេះវិជ្ជាពេទ្យបន្តិចបន្តួចសម្រាប់គ្រាន់តែបម្រើអ្នកភូមិអ្នកស្រុកនៅជិតខាង ។ ចំណេះវិជ្ជាមានកម្រិតបឋមនេះ គឺជាកេរដំណែលដែលគាត់ទទួលបានពីរបបខ្មែរក្រហម បន្ថែមទៅលើនយោបាយ សតិអារម្មណ៍ចាត់តាំងដែលជិតជាប់នៅក្នុងគំនិតគាត់មកដល់សព្វថ្ងៃ ។

### ជីវិតសិក្សា

សុខា កើតនៅឆ្នាំ១៩៥៩ ។ នៅពេលដែលគាត់មានអាយុ១០ឆ្នាំ ឪពុកម្តាយក៏បញ្ជូនឲ្យទៅរស់នៅជាមួយជីដូននៅភូមិពោធិ៍ឥន្ទុ ឃុំកោងកាង ស្រុកពញាក្រែក ខេត្តកំពង់ចាម ។ ជីដូនក៏បញ្ជូនគាត់ឲ្យទៅរៀនអក្សរសាស្ត្រនិងវប្បធម៌ខ្មែរ ។ សុខា រៀនបានត្រឹមថ្នាក់អាទិកដ្ឋានពីសង្គម(ថ្នាក់ទី៣បច្ចុប្បន្ន)ក៏ត្រូវអាក់ខានដោយសារការកើតឡើងនូវបាតុកម្មឆ្នាំ១៩៦៥ ។ គោលបំណងរបស់ សុខា ពេលចាប់ផ្តើមចូលរៀនដំបូង គឺចង់ធ្វើពេទ្យព្រោះគាត់យល់ថា វិជ្ជានេះអាចជួយដោះស្រាយការលំបាកឈឺស្កាត់ក្នុងក្រុមគ្រួសារ ។ ចំណែកគោលបំណងទីពីររបស់គាត់ គឺចង់ចេះកាត់ដេរសម្លៀកបំពាក់ ។ ប៉ុន្តែគោលបំណងទាំងពីរនេះត្រូវរលាយបាត់អស់ ។

ទន្ទឹមនឹងពេលនោះដែរ សុខា ក៏ចាប់ផ្តើមកស្រវាស្រទេញរៀនសូត្រខាងចំណេះវិជ្ជាទំនៀមទម្លាប់ខាងសាសនាអ៊ីស្លាម ។ ចូលមកដល់ឆ្នាំ១៩៧២ សុខា ក៏សម្រេចចិត្តចូលបម្រើបដិវត្តន៍ខ្មែរក្រហម ។ នៅក្នុងភូមិ សុខា ជាមនុស្សម្នាក់ដែលរួសរាយនិងឆាប់យល់សភាពការណ៍ ។ សុខា រំឭករឿងចាស់ថា÷ "ចូលដល់រដ្ឋប្រហារដំនាន់រណសិរ្សរួបរួមជាតិបដិវត្តន៍ក្នុងភូមិស្រុកហ្នឹងដូចជាចាស់ៗ ប្រធានតាគិន ចាស់ទុំហ្នឹងគេយល់ឃើញថា ខ្ញុំជាក្មេងម្នាក់ដែលចេះអក្សរជាងគេខាងអក្សរខ្មែរហ្នឹង គេក៏ចាត់តាំងឲ្យខ្ញុំធ្វើជាប្រធានកុមារ" ។ មិនថាតែរូប សុខា ផ្ទាល់ សូម្បី

តែប្រជាជនទាំងក្មេងទាំងចាស់នៅក្នុងភូមិក៏ពេញចិត្តចូលបម្រើបដិវត្តន៍នេះដែរ ។ តើមូលហេតុអ្វីបានជាប្រជាជនក្នុងភូមិរួមទាំង សុខា ផងជឿស្ងប់នឹងបដិវត្តន៍ខ្មែរក្រហម? សុខា ក៏បានរ៉ាយរ៉ាប់ប្រាប់ពីដំណើរដើមទងថា“កាលហ្នឹងកម្មាភិបាលខ្មែរក្រហម (តាសាឡាត់) គេមកធ្វើការខាងគណៈស្រុកតាមភូមិតាមឃុំទៅចេះតែមកឃោសនាទៅចូលបដិវត្តន៍ទាំងអស់គ្នា ។ ដូចថាមួយភូមិហ្នឹងមានកុមារ៥០នាក់ចូលទាំងអស់គ្នា ហើយខ្ញុំប្រធានគេតែហ្មងទៅ ។ កាលហ្នឹងគ្មានអ្នកណាបង្ខំទេ គេឃោសនា យើងជឿថាល្អយើងចូលទៅ» ។

## អនុស្សាវរីយ៍អាពាហ៍ពិពាហ៍

នៅឆ្នាំ១៩៧៤ សុខា ក៏បានរៀបការជាមួយយុវជនជញ្ជូនគ្រាប់ម្នាក់ឈ្មោះ ណុះ លាស់ ។ ទាក់ទិននឹងការរៀបអាពាហ៍-ពិពាហ៍នេះ សុខា ហាក់ដូចជាស្តាយក្រោយថា មិនគួរឆាប់យកគូស្រករអីចឹងសោះ ពីព្រោះគាត់នៅស្តាយការងារ ។ សុខា និយាយថា “ថីមិនស្តាយ...ស្តាយទល់តែដល់សព្វថ្ងៃហ្នឹង...បើកុំយកប្តីទៅវាស្អី ។ យកប្តីឡប់អារឿងគិតគូរពីរឿងគ្រួសារទៀតហើយ ។ បើយកប្តីហើយគិតពីរឿងជីវភាពគ្រួសារខ្លួនឯងដោះស្រាយរឿងកូនចៅក្មេចបាត់អស់ហើយការងារ» ។ ម្យ៉ាងវិញទៀត កាលនៅលីវ មានបុរសជាច្រើនចោមរោមចង់បានធ្វើជាគូស្រករ ហើយមានអ្នកខកចិត្តក៏មិនស្ទើរដែរ ក្រោយពេល សុខា រៀបចំគ្រួសាររួច ។ ក្នុងនោះយុវជនម្នាក់ទៀតឈ្មោះ ហ្សេន រស់នៅភូមិស្រុកជាមួយគ្នា និងត្រូវជាក្មើម្រាក់របស់ប្តីគាត់ទៀតផង ។ យុវជន ហ្សេន (នៅថ្ងៃផ្សំដំណេករបស់សុខា) បានមកឡើងដល់លើផ្ទះ ហើយពោលពាក្យខកចិត្តដាក់គាត់ថា “ធ្វើម៉េចអត់មាននិស្ស័យ! ប៉ុន្តែយ៉ាងណាក៏ខ្ញុំនៅតាមរហូតទោះជាមានកូនប៉ុន្មានក៏ដោយ» ។ “កាលហ្នឹងខ្ញុំនៅក្មេង និយាយទៅថាអួតដូចមិនអួតទេ...គូដណ្តឹងនិយាយពីអ្នកចង់បានពេញភូមិ...ក្មួយតាម៉ាត់ លី ហ្នឹងក៏ចូលសួរដែរ» ។

សុខា ចូលរោងការនៅឆ្នាំ១៩៧៤ ក្នុងអាយុ១៥ឆ្នាំ ចំណែកប្តីគាត់មានអាយុ១៧ឆ្នាំ ។ អ្នកទាំងពីររៀបការតាមការផ្សំផ្គុំតាំងពីនៅក្មេងតូចៗ ។ ឪពុកម្តាយទាំងសងខាងធ្វើការក្នុងភូមិជាមួយគ្នា ។ ឪពុករបស់ ណុះ លាស់ ធ្វើជាកូប្រាល់ (ប្រធានក្រុម) ចំណែកឪពុករបស់ សុខា ធ្វើជាសូរិយ៉ង(ប្រធានភូមិ) ។ កាលពីនៅតូចៗមិនទាន់ដឹងក្តីអ្នកទាំងពីរតែងតែដឹកដៃគ្នាដើរលេង ។ អ្នកភូមិស្រុកជិតខាងតែងតែនិយាយលេងចំអន់ដាក់អ្នកទាំងពីរ ។ ម្តាយក្មេក សុខា តែងតែនិយាយជាមួយឪពុកម្តាយរបស់ សុខា ថា “ធំឡើងអញសុំភ្ជាប់កូនឯងជាមួយគ្នាហើយ» ។ ដល់ពេលមានបាតុកម្មកើតឡើងគូស្រករក្មេងៗទាំងពីរនាក់នេះក៏ត្រូវបែកគ្នា ដោយសុខាត្រូវទៅភូមិពោធិ៍ឥន្ទ ចំណែកឯ ណុះ លាស់ ក៏ទៅភូមិដីមាន់ ។ ដល់ពេលធំដឹងក្តីៗ រៀងៗខ្លួនហើយចាស់ទុំទាំងសងខាងក៏សើរើពាក្យសម្តីសន្យាកាលពីមុនសុំផ្សំផ្គុំអ្នកទាំងពីរឡើងវិញ ។ គួររំឭកដែរថា កាលនោះ ណុះ លាស់ មានគូដណ្តឹងហើយ ប៉ុន្តែគាត់ក៏សុំផ្តាច់ពាក្យ សុខចិត្តមករក សុខា


ស៊ិន សុខា និងកូនៗ

ដែលជាគូដណ្តឹងចាស់វិញ ។ សុខា រំឭករឿងចាស់ថា “ចាស់ៗគេសើរើពាក្យសម្តីពីក្មេងៗហ្នឹងមកវិញ ។ ប្តីខ្ញុំហ្នឹងក៏មានគូដណ្តឹងប្រុងនឹងរៀបការដែរ ។ គេថាមិនគួរ ក៏សុំផ្តាច់ពាក្យពីខាងហ្នឹងមករៀបចំ ។ ម្តាយគេសួរមកដល់ចំណុចខ្ញុំហ្នឹង គាត់នៅស្ងៀម ក៏សុំចូលដណ្តឹងតាមច្បាប់តែម្តង» ។ មុនពេលរៀបការ ណុះ លាស់ រៀននៅថ្នាក់ទី៧ ។

សុខា និង ណុះ លាស់ ហាក់ដូចជាសំណាងជាងអ្នកភូមិស្រុកជាមួយគ្នា ដោយហេតុថារំលងបានមួយខែក្រោយពីអ្នកទាំងពីររៀបការរួច មានច្បាប់ថ្មីចេញមកមិនឲ្យមានពាក់អលង្ការហ៊ឺហាអ្វីឡើយ ពីព្រោះអង្គការយល់ថាទាំងអស់នេះជារបស់បក្រពត្តិ ។ សុខា រំឭកថា «មិនដល់១ខែផងខ្ញុំការរួចគេចាប់ផ្តើមចុះច្បាប់ហ្នឹងមកចាប់ប្រកាសហ្នឹងហ្នឹង ។ សូម្បីតែគ្រឿងកាឡៃក៏អត់ឲ្យមានដែរ ។ ឲ្យតែខាងគ្រឿងលម្អ គឺអត់មានទេ សុទ្ធតែគេថាបក្រពត្តិទាំងអស់» ។ សុខា និយាយបន្ថែមទាំងអស់សំណើចថា អំឡុងពេលនោះអង្គការចាប់ឲ្យរៀបការពី៥ទៅ១០គូ ហើយអ្នកដែលមិនព្រមចុះសម្រុងគ្នានឹងត្រូវយកទៅកសាង ។ ប្តីប្រពន្ធក្រោយពេលរៀបការហើយត្រូវបានបំបែកឲ្យនៅឆ្ងាយពីគ្នា ។ ប្រហែលជា១ខែ អង្គការឲ្យជួបគ្នាម្តងដោយត្រូវរូវគ្នារវាងប្រធានភូមិ និងកងនារី ។

នៅពេលរៀបការ សុខា មានអ្នកកំដរ មានគ្រឿងអលង្ការពាក់ ដូចជាខ្សែក ចិញ្ចៀន ប៉ុន្តែក្នុងសម្លៀកបំពាក់ឯកសណ្ឋានអាវខ្មៅ ខោខ្មៅ ស្បែកជើងកង់ឡាន ។ មិនតែប៉ុណ្ណោះថែមទាំងមានសិល្បៈស្រុកមកលេងកំដរផង ។ សុខា នៅចាំបានថា បទចម្រៀងច្រៀងកាលនោះ គឺបទដាំផេង ហើយច្រៀងដោយឈ្មោះ ដាំ ផេង ផ្ទាល់តែម្តង ដែលជាប្រធានសិល្បៈឃុំត្នោតស្រុកពញាក្រែក ។ ដាំ ផេង មានស្រុកកំណើតនៅស្រុកបាភ្នំខេត្តព្រៃវែងក្នុងគ្រួសារកសិករក្រមួយ ។ នៅក្នុងកម្រងរឿងបដិវត្ត(ដកស្រង់ពីកាសែតនិងទស្សនាវដ្តីផ្សេងៗភាគ១) ដែលមានចំណងជើងថា«វីរភាពរបស់ប្រជាជននិងកងទ័ពបដិវត្តកម្ពុជា» ពីទំព័រ៣៨ដល់៥៨មានរៀបរាប់ប្រវត្តិលម្អិតរបស់ដាំ ផេង ដែលមានឈ្មោះលេចធ្លោនៅក្នុងជួរបដិវត្តន៍នាសម័យនោះ ។ ពិសេសជាងនេះទៀត មានកំណាព្យដែលនិពន្ធដោយដាំ ផេង ផ្ទាល់តែម្តង ។ កំណាព្យនេះមានន័យថា«បេះដូងក្រហមខ្ញុំថ្នាក់ ខ្ញុំថ្នម លត់ដំរាល់ថ្ងៃ ទុកជូនបដិវត្តន៍ ដ៏មានតម្លៃ ជូនអ្នកក្រក្រី វណ្ណៈអធន ។ ពេលនេះហើយណា ជនកម្ពុជាត្រូវការទាន់ហន់ យកបេះដូងខ្ញុំទៅដោះទុក្ខធ្ងន់ បុត្រប្រជា រីករាយបូជា» ។

ចូលរួមរៀបការ សុខា និង ណុះ លាស់ បានប្រហែលជា១០ថ្ងៃ ដាំ ផេង ក៏ត្រូវអង្គការចាប់យកទៅដាក់គុក ។ សូមរំឭកដែរថាសៀវភៅកំណត់ហេតុវគ្គរៀនសូត្រនយោបាយមួយច្បាប់មានតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ សៀវភៅនោះមានរៀបរាប់ពី«ធាតុខុសគ្នារវាងអ្នកវប្បធម៌បដិវត្តនិងអ្នកវប្បធម៌ក្បត់បដិវត្ត» ហើយរិះគន់ថា«អ្នកវប្បធម៌ទាំងពីរប្រភេទនេះខុសគ្នាមេឃនិងដី ។ អ្នកវប្បធម៌បដិវត្តមានឧត្តមគតិតស៊ូប្រយុទ្ធនឹងខ្មាំងដាច់ខាតដើម្បីរំដោះជាតិ ប្រជាជន និងវណ្ណៈ ។ រីឯឧត្តមគតិរបស់អ្នកវប្បធម៌ប្រឆាំងនឹងបដិវត្តន៍វិញ គឺលុយ គឺសរសេរយ៉ាងម៉េចឲ្យតែខាងលក់ដាច់បានលុយ ទោះជាត្រូវក្បត់ជាតិ ក្បត់ប្រជាជនក៏ដោយ» ។

រៀបការបានតែបីថ្ងៃ សុខា ត្រូវបែកបាក់ក្រុមគ្រួសារអត់បាននៅជាមួយគ្នាជាប្តីប្រពន្ធល្អូកល្អិនឡើយ ដោយហេតុថាអង្គការស្នើពីខាងយោធាមកឲ្យទៅវាយរំដោះភ្នំពេញ ។ មានសំបុត្រអង្គការមួយច្បាប់ស្នើប្តីរបស់ សុខា ថា «មិត្តលាស់ត្រូវទៅសមរភូមិមុខ» ។ សុខា ដែលទើបតែរៀបការថ្មីថ្មោងក៏សុខចិត្តទៅសុំអង្វរលន់តួខាងឃុំ ប៉ុន្តែមិនបានផលអ្វីឡើយ ។ ជាការឆ្លើយតបវិញ ខាងឃុំក៏បញ្ឈាក់ពីកិច្ចសន្យាប្តេជ្ញាចិត្តដែល សុខា បានទៅបំពេញសំណុំបែបបទរៀបអាពាហ៍ពិពាហ៍ដែលមានស្នាមផ្តិតមេដៃទាំងសម្តីធំៗថា«មិត្តឯងកុំមកសុំអីត្រូវយើងលះបង់ខ្លះៗទៅ ។ ពេលមិត្តឯងមកធ្វើប្រវត្តិរូបការមិត្តឯងបានប្តេជ្ញារួចហើយ» ។

ប្តីរបស់ សុខា ទៅបានតែមួយយប់ប៉ុណ្ណោះភ្នំពេញក៏ត្រូវវាយបែក ។ លាស់ ក៏ត្រឡប់មកវិញរួមរស់ជាមួយ សុខា ហើយ សុខាក៏ចាប់ផ្តើមមានផ្ទៃពោះតាំងពីពេលនោះមក ។ នៅឆ្នាំ១៩៧៦ សុខា ឆ្លងទន្លេបានកូនប្រុសមួយ ។ ប៉ុន្តែជាអកុសលក្រោយពេលសម្រាលកូនបាន១សប្តាហ៍ កូនរបស់ សុខា ក៏ស្លាប់ដោយសារជំងឺ ។

## ជីវិតបដិវត្តន៍

ក្រោយពីធ្វើជាប្រធានកុមារផ្នែកសិល្បៈ សុខា ក៏ត្រូវបានជ្រើសតាំងឲ្យធ្វើជាប្រធាន«ចាស់បាល» ។ ក្នុងតួនាទីជាអ្នកដឹកនាំ សុខា ត្រូវប្រជុំរៀងរាល់ថ្ងៃ ។ ពេលប្រជុំម្តងៗតែងតែមានលើកឡើងពីកំហុសការងារទិតៀនស្វ័យទិតៀន ។ សុខា ជាអ្នកអប់រំកែតម្រង់ ។ អ្នកដែលមានកំហុសច្រើនដងពេកច្បាស់

ជាមានផលវិបាកមិនខាន ។ សុខា បញ្ជាក់ថា អ្នកដែលមានកំហុស អង្គការកសាងលើកទី២ ទី៣ ទី៤ហើយ ច្បាស់ជាត្រូវបានស្នើទៅរៀនសូត្រហើយ ។ ពាក្យថា«រៀនសូត្រ»នេះមានន័យជ្រៅណាស់ ។

សុខា ជាកម្មាភិបាលខ្មែរក្រហមប្រហែលជាយល់ពាក្យនេះដូចប្រជាជនកម្ពុជាភាគច្រើនដែរ ។ «រៀនសូត្រនេះ ខ្ញុំយល់ថាដល់គេកសាងលើកទី២ ទី៣ ទី៤ហើយ តែនេះហើយ គេយកទៅមិនដឹងថាគេយកដាក់គុក មិនដឹងយកទៅធ្វើអ្វី ។ ជ្រៅណាស់ ។ ពាក្យរៀនសូត្រហ្នឹងជ្រៅតែម្តង ។ បើតាមខ្ញុំយល់ពាក្យរៀនសូត្រហ្នឹងមិនមែនរៀនសូត្រទេ យកទៅបាត់ខ្លួន ។ ក្នុងបទបញ្ជាផ្ទៃក្នុងរបស់គេ សីលធម៌រស់នៅហ្នឹងគឺ៥ជង» ។ សុខា ចង់បញ្ជាក់ថា អ្នកដែលមានកំហុស ជាពិសេសកំហុសសីលធម៌៥ជង ហើយអង្គការហៅមកកសាងមិនព្រមកែច្បាស់ជាទទួលផលវិបាកមកលើខ្លួន អាចត្រូវអង្គការយកទៅដាក់គុក ឬអាចយកទៅសម្លាប់ចោល ។ សុខា រៀបរាប់ពីការងារប្រចាំថ្ងៃរបស់គាត់ថា«គេដាក់ជាឯកសារបទវិន័យផ្ទៃក្នុងរបស់គេ ។ សីលធម៌រស់នៅហ្នឹងវាមានប៉ុន្មានយ៉ាង គឺ១៥យ៉ាង ។ សរសេរដាក់ឲ្យគេអីចឹង ។ មកពីធ្វើការងារវិញយើងអង្គុយប្រជុំគ្នា ។ ការងារយើងបានលូតលាស់បានប៉ុនណា ។ ឥឡូវមិត្តណាខុសមានអារម្មណ៍ម៉េចខ្លះទៅលើកឡើងទៅ ។ យើងជាប្រធានសរុបឲ្យគេទៅ ។ សរុបថាឥឡូវគុណសម្បត្តិគេក្នុងថ្ងៃនេះ គឺការងារបានប៉ុណ្ណេះ ហើយក្នុងសីលធម៌និយាយស្តីអីហ្នឹង...សរុបថាដូចជាបានពិន្ទុប៉ុណ្ណេះៗអីចឹង ។ ហើយថ្ងៃស្អែកម៉ោងប៉ុណ្ណេះទៅធ្វើនេះ ។ ទៅប្រូតស្បូវ ឬក៏ទៅធ្វើអីដែលគេឲ្យចាត់តាំងមកខ្ញុំប្រជុំរួមនឹងគេមក ។ ប្រជុំនឹងប្រធានភូមិអីចឹង ។ ក្នុងមួយថ្ងៃៗមានតែប៉ុណ្ណឹងការងារគ្មានអីទេ» ។

សុខា រំឭកឡើងវិញថា ព្រឹកឡើងខ្មែរក្រហមវាយជួងម៉ឺងម្នាក់ៗត្រូវរួសរាន់ ។ ចាប់បានអីយកហ្នឹង ។ គេគោរពវិន័យទៀងទាត់ណាស់ ហើយសង្កត់ធ្ងន់ថាអត់ដូចឥឡូវនេះទេ ។ «វិន័យគេទៀងទាត់តែម្តង ។ តម្រង់ជួររួចឲ្យចាស់ៗហ្នឹងច្រៀងបទក្រោកឡើងអស់អ្នកខ្ញុំគេទាំងប៉ុន្មាន» ។ សុខា ប្រហែលជាមិនទាន់ភ្លេចបទចម្រៀងជាតិកម្ពុជាប្រជាធិបតេយ្យនេះនៅឡើយទេ ពីព្រោះសុខានៅត្រូតពិនិត្យផ្នែកនារីរាល់ថ្ងៃរាល់ព្រឹក ។

«ក្រោកឡើងអស់អ្នកខ្ញុំគេទាំងប៉ុន្មាន ក្រោកឡើងអស់អ្នកតោកយ៉ាករាល់ប្រាណ ក្តៅណាស់គឹងណែនស៊ើរប្រេះដើមទ្រូងធ្លាយ គ្រាម្តងនេះស្លាប់រស់មិនស្តាយ ។ របបចាស់យើងបំផ្លាញឲ្យអស់ឆាប់ អស់អ្នកខ្ញុំគេ ក្រោកឈរឡើងទៅ! ថ្ងៃស្អែករបបថ្មីយើងបានវិញ ។ ប្រយោជន៍ប៉ុន្មានធ្លាក់បានដៃយើង ។ តស៊ូនេះគ្រាចុងក្រោយបំផុត រួមគ្នាមកដល់ថ្ងៃមុខ ឡាំងទែរណាស្យូណាស់ គឺជាសង្គមអនាគតតស៊ូនេះគ្រាចុងបំផុតរួមគ្នាមកដល់ថ្ងៃមុខ ឡាំងទែណាស្យូណាស់ គឺជាសង្គមអនាគត» ។

ទាក់ទងនឹងនយោបាយរបស់ខ្មែរក្រហម សុខា ហាក់យល់ថាល្អទាំងអស់ ប៉ុន្តែ សុខា មិនពេញចិត្តទង្វើពីរយ៉ាងរបស់របបនេះពោលគឺការយកមនុស្សទៅសម្លាប់ចោលនិងបង្ខំឲ្យបងប្អូនខ្មែរអ៊ីស្លាមហូបសាច់ជ្រូក ។ សុខា និយាយថា ខ្មែរក្រហមឲ្យជនជាតិខ្មែរអ៊ីស្លាមហូបសាច់ជ្រូក ។ ដើម្បីចៀសវាងទង្វើប្រឆាំងនឹងសាសនាបែបនេះ សុខា និងក្រុមគ្រួសារក៏បានស្នើអង្គការដាំបាយនៅផ្ទះហូបដោយយកលេសថាដាំបាយឲ្យប្តីដែលជាយុទ្ធជនជញ្ជូនគ្រាប់ដែលមានសមាជិកមកជាមួយ ។ សុខា បានសម្រេចយកវិធីនេះដើម្បីសម្របខ្លួនបានដោយជោគជ័យ ។ ប៉ុន្តែក្រោយមកទៀត ពេលវៀតណាមវាយចូលលើកទី១និងទី២ ខ្មែរក្រហមចាប់ផ្តើមបង្ខំឲ្យបងប្អូនខ្មែរអ៊ីស្លាមហូបសាច់ជ្រូកដោយលែងអនុញ្ញាតឲ្យដាំស្លដោយឡែកទៀតហើយ ពោលគឺ តម្រូវឲ្យដាំស្លហូបចុកជាមួយគ្នាទាំងខាងយោធានិងសហករណ៍ ។

សុខា មិនពេញចិត្តទង្វើនេះដោយនិយាយថា «អត់ដែលទេអត់ដែលអីចឹងទេ ។ គឺទាញទៅតែផ្លូវតែមួយហ្នឹង-រណសិរ្សបដិវត្តន៍គេហ្នឹងតែម្តង ។ អត់មាននិយាយរឿងសាសនាទេ ។ គេទាញទៅទាំងអស់អារឿងសំយ៉ាំងអីៗគេអត់ឲ្យយើងធ្វើទេ ដល់ថ្នាក់ទាញឲ្យយើងស៊ីសាច់ជ្រូក កាត់សក់កាត់អីហ្នឹង ។ គេអត់និយាយអំពីរឿងវត្តអារាមវត្តអីឯណា ។ សូម្បីតែលោកក៏គេផ្សឹកដែរ» ។

ចំពោះការសម្លាប់វិញ សុខា អះអាងថា មានថ្ងៃមួយនៅពេលកំពុងដកស្ទូងនៅឃុំស្វាយជ្រះ ស្រុកស្ទួល ខេត្តក្រចេះ គាត់ឃើញកម្មាភិបាលខ្មែរក្រហមចាប់ស្ត្រីម្នាក់សម្រាតខោអាវអស់

ហើយវះយកដោះទាំងពីរមកឆាស៊ីជាអាហារ ។ កម្មាភិបាលម្នាក់នោះមានឈ្មោះ ស្តី ជាប្រធានយុវជន (សព្វថ្ងៃនៅរស់ប៉ុន្តែមិនដឹងថាគាត់រស់នៅទីណាឲ្យពិតប្រាកដឡើយ) ។ សុខា ភ័យតក់ស្លុតហើយក៏នឹកដល់ករណីម្តាយបង្កើតរបស់គាត់ផ្ទាល់ ។ ម្តាយ សុខា ឈ្មោះ ម៉ាត់ ចៅ កើតជំងឺស្រឹត ធ្វើការធ្ងន់មិនបានទេ ។ ដោយម្តាយរបស់ សុខា មិនសូវបានទៅធ្វើការ ខ្មែរក្រហមក៏មកចាប់ម្តាយសុខាដល់ផ្ទះ ។ សុខា គិតថា ជីវិតម្តាយរបស់គាត់ពិតជាត្រូវអស់ត្រឹមហ្នឹងហើយ ។ សំណាងល្អ ប្តីរបស់ សុខា ក៏ទឹមរទេះគោដេញតាមទាន់ ហើយក៏សម្រួលជាមួយខ្មែរក្រហមបានសម្រេចដោយហេតុថា គាត់មានមុខមានមាត់នៅក្នុងគ្រួសារនិងភូមិនេះដែរ(យុទ្ធជនកាំភ្លើងធំ) ។

## ជីវិត«មុខពីរ»

ក្រោយពេលវិលត្រឡប់មករស់នៅស្រុកកំណើតវិញនៅឆ្នាំ១៩៧៩ ប្តីប្រពន្ធទាំងពីរនាក់ប្រកបមុខរបរចិញ្ចឹមជីវិតបានកាក់កបណាស់រហូតបានសង់រហូតដល់ផ្ទះក្បឿងមួយខ្នង ។ ប៉ុន្តែមិនយូរប៉ុន្មានក៏ត្រូវចាញ់បោកមិត្តភក្តិម្នាក់ដែលធ្វើការនៅក្រសួងមហាផ្ទៃ ។ គ្រួសារក៏បែករឿងរកាំរកូស ប្តីរបស់ សុខា ដើរចេញពីផ្ទះទាំងខកចិត្តព្រោះបាត់បង់ដើមទុនដែលខ្លួនខំសន្សំយូរណាស់មកហើយ ។ សុខា ជាអ្នកទទួលខុសត្រូវរ៉ាប់រងទាំងអស់នូវបំណុលខាតបង់ទាំងប៉ុន្មាន ។ ទ្រព្យសម្បត្តិគេរអាករសព្វបែបយ៉ាងត្រូវយកទៅលក់ដើម្បីដោះបំណុល ។ គ្រួសាររបស់ សុខា ក៏ធ្លាក់ខ្លួនមកសង់ខ្ទមតូចមួយប្រកបមុខរបររកស៊ីបន្តិចបន្តួចនៅភូមិក្រសាំងស្រែវែង ស្រុកដំបែរ ខេត្តកំពង់ចាម ។ នៅឆ្នាំ១៩៨៥ សុខា ក៏សម្រេចចិត្តដើរតួជា«ជនមុខពីរ» ។ នៅតំបន់នោះមានលាយឡំសមាសភាពទាំងខាងរដ្ឋកម្ពុជានិងខ្មែរក្រហម ។ ប្រជាជនរស់នៅស្រុកភូមិនេះតែងតែសម្របខ្លួនតាមកាលៈទេសៈ ។ បើមិនធ្វើយ៉ាងដូច្នេះទេច្បាស់ជាមានផលវិបាកធ្លាក់មកលើខ្លួនមិនខាន ។

សុខា និយាយថា ឈ្មោះ លី ស្នងការខេត្ត(ឆ្នាំ១៩៨៥) បានទាក់ទងឲ្យ សុខា ធ្វើការជាគិញសម្ងាត់ ។ ចំណែកខាងខ្មែរក្រហមវិញ សុខា ជាអ្នកដោះដូរគ្រឿងសម្ភារផ្សេងៗ ដូចជាវិទ្យុនិងអាយកូមជាដើម ជាពិសេសជាងនេះទៅទៀត គឺដូរប្រាក់ដុល្លាជាលុយខ្មែរឲ្យមេខ្មែរក្រហម បើកប្រាក់ខែឲ្យកូនទាហានរបស់ខ្លួន ។ សុខា បានទាក់ទងជាមួយ នួន ប៉ែត (ប្អូនថ្លៃ សឿន) ខាងកងពល៩២០ និងខាង១០០៣ ឈ្មោះ ឡុង យិន ។ ក្នុងតួនាទីជាគិញរបស់រដ្ឋកម្ពុជាផងនិងជាមនុស្សរបស់ខ្មែរក្រហមផង សុខា ដើរចូលព្រៃ និងចេញពីព្រៃចូលក្រុងភ្នំពេញដើម្បីដោះដូររបស់របរនិងស៊ើបការណ៍សម្ងាត់ ។ សុខា និយាយថា ធ្លាប់ឲ្យការណ៍ទៅខាងរដ្ឋកម្ពុជាឲ្យចូលទៅវាយកន្លែងដែលខ្មែរក្រហមស្នាក់នៅក្នុងព្រៃដែរ ។ សុខា បញ្ជាក់ថា គាត់ធ្លាប់បានដូរដុល្លាររហូតដល់ផ្សារអូឫស្សីផ្ទះរបស់នាយកដ្ឋានចម្ការកៅស៊ូ ។ ជីវិត «មុខពីរ» ពិតជាមានគ្រោះថ្នាក់គ្រប់ជំហាន ។

ជីវិត សុខា មិនខុសពីជីវិតគិញទូទៅដែលរង់ចាំតែថ្ងៃអន្សារនោះទេ ។ មានថ្ងៃមួយ សុខា បាននាំខ្មែរក្រហមពីរនាក់ គឺ៩២០ និងនិរសាម្នាក់ទៀត ។ សុខា បញ្ជាក់ថា មុនយកអ្នកទាំងពីរមកឡើងលើផ្ទះគាត់ៗបានទាក់ទងជាមួយនគរបាលសព្វគ្រប់អស់ហើយ ។ ខ្មែរក្រហមពីរនាក់នេះចង់ទៅជួបខ្សែរយៈរបស់ខ្លួនបង្កប់នៅភ្នំពេញ ។ ប៉ុន្តែផែនការនេះមិនបានសម្រេច ហើយទាំងអស់គ្នានិងខ្មែរក្រហមទាំងពីរនាក់ក៏ត្រូវបានរដ្ឋអំណាចចាប់ដាក់ពន្ធនាគារ ។ សុខាយល់ថា មូលហេតុនៃការចាប់ខ្លួនគាត់ គឺដោយសារខាងទាហានគេចង់បានមុខមាត់ ។ ចំណែកឯកសារទាក់ទង នួន ជា ដែល សុខា យកបានពីខាងខ្មែរក្រហម សុខា អះអាងថាបានប្រគល់ជូនខេត្តអស់ទៅហើយ ។

នៅពេល សុខា កំពុងកាន់តួនាទីជាប្រធាន "ចាស់បាល" សុខា ហាក់ដូចជាពេញចិត្តនិងមានមោទកភាពណាស់ចំពោះកិច្ចការដ៏ពិសេសនេះ ។ ប៉ុន្តែមកដល់សព្វថ្ងៃដោយសារជីវភាព ចុះដុនដាបខ្វះមុខខ្វះក្រោយ សុខា លែងសោកស្តាយចំពោះការផ្លាស់ប្តូរបដិវត្តន៍ស្អីគេនោះទៀត ហើយដោយគិតគូរពីរឿងជីវភាពរស់នៅចិញ្ចឹមកូនរបស់ខ្លួនវិញ ។ សុខា ពោលទាំងមុខមុខស្រងូតស្រងាត់ថាគាត់មិនស្តាយទេកម្លាំងធ្វើបដិវត្តន៍តែតូចចិត្តនឹងវាសនាបច្ចុប្បន្ន÷ «ធ្វើបដិវត្តន៍កន្លងមក គឺគាត់អត់មានសោកស្តាយអីទេ ។ គ្រាន់តែមានទឹកចិត្តមួយ អារម្មណ៍មួយនឹកឃើញថា កាលពីដើមធ្លាប់តស៊ូដែរដល់មកដំនាន់នេះ...វាចុះខ្សោយ ហើយចង់ទៅរកការផ្លាស់ណាមួយដើម្បីសម្រាលជីវភាពកូនចៅ» ។

**ស្វ ប៊ុនស៊ូ**

# រូបថតដែលនៅមានជីវិត

រូបថតដែលភ្ជាប់ជាមួយអត្ថបទនេះជាប្រភេទរូបថតស-ខ្មៅនៃសមមិត្តនារីខ្មែរក្រហមឥស្លាមពីររូប ឈរថតទន្ទឹមគ្នា ។ សមមិត្តនារីដែលឈរនៅខាងឆ្វេងមានឈ្មោះថា មូសា សុខា និង សមមិត្តនារីម្នាក់ទៀតឈ្មោះ ម៉ាត់ រកីយ៉ាស់ ហៅ រកី ។ អ្នកទាំងពីរបានឈរថតនៅពីមុខផ្ទាំងរូបភាពទេសភាពព្រៃភ្នំ ។ រកី ត្រូវជាកូនបង្កើតរបស់ឯកឧត្តម ម៉ាត់ លី និងត្រូវជាចៅបង្កើតរបស់តា សុះ ម៉ាន រកី ស្លាប់នៅឆ្នាំ១៩៧៨ ។ សុខា សព្វថ្ងៃរស់នៅភូមិថ្ពងលើក្រោម(ភូមិសូបា) ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ កំពុងស្ថិតក្នុងស្ថានភាពក្រីក្របំផុត ។ សុខា មានកូនទាំងអស់១៣នាក់ ។

សុខា បានទទួលស្វាគមន៍ខ្ញុំនៅក្នុងគេហដ្ឋានដ៏កម្សត់របស់គាត់ ។ សុខា បាននិយាយប្រាប់ថា រូបថតនេះ គឺថតនៅឆ្នាំ១៩៧៣ដោយជាងថតឈ្មោះ ខ្មៃ ក្រោមការរៀបចំពីលោកតា សុះ ម៉ាន ដែលជាកម្មាភិបាលតំណាងជនជាតិចាម នៅភូមិភាគបូព៌ា ។ សុខា និយាយថា គាត់បានលះបង់គ្រួសារដែលជាត្រកូលអ្នកមានម្នាក់មកចូលរួមធ្វើបដិវត្តន៍តាមការឃោសនាដែលមានយាយរបស់គាត់ឈ្មោះ ម៉ាស់ ជាអ្នកណែនាំ ។ ស្ថិតក្នុងវ័យ១៦ឆ្នាំ រួមផ្សំនឹងរូបសម្រស់ដ៏ស្រស់ផូរផង់បានធ្វើឲ្យជីវិតក្នុងជួរបដិវត្តន៍របស់ សុខា កាលនោះហាក់រីកធំធាត់ជាលំដាប់ ។

ក្នុងរវាងឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៣ នៅតាមទីជនបទនានាដែលមានទីតាំងឆ្ងាយដាច់ស្រយាលពីទីប្រជុំជន របបកម្ពុជាប្រជាធិបតេយ្យដែលកាលនោះមានឈ្មោះថា ខ្មែររំដោះ បានចាប់ផ្តើមធ្វើការឃោសនាស្វែងរកការគាំទ្រពីបណ្តាប្រជាជនគ្រប់ជាន់ថ្នាក់មិនថាប្រជាជនខ្មែរ ឬជាតិសាសន៍ផ្សេងៗឡើយ ។ ពិធីបើកវគ្គបង្រៀនពីគោលមាគ៌ានយោបាយនានាក្នុងការកសាងបដិវត្តន៍ក៏បានរីកដុះដាលឡើងព្រោងព្រាតដែរ ។ នៅឯស្រុកពញាក្រែក ខេត្តកំពង់ចាមឯណោះវិញ មានការបើកវគ្គបង្រៀនពីគោលនយោបាយក្នុងការបំផុសប្រជាជនឲ្យចូលរួមធ្វើបដិវត្តន៍ប្រឆាំងនឹងរបបសក្តិភូមិនាយទុនប្រតិកិរិយា ជាពិសេសចក្រពត្តិអាមេរិកដើម្បីកសាងបដិវត្តន៍មួយថ្មីដែលស្អាតស្អំ គ្មានការជិះជាន់កេងប្រវ័ញ្ច និងគ្មានការកៀបសង្កត់ពីអ្នកមានមកលើអ្នកក្រ ។ សុខា បានចូលរៀនវគ្គនេះតាំងពីដើមរហូតដល់ចប់ ។

ចំណែក រកី វិញក៏ដូចគ្នាដែរ ។ ទោះបីជាការរៀនសូត្រនៅអន់ជាង សុខា ក៏ដោយ រកី ពូកែខាងទ្រឹស្តីជាង សុខា ។ ក្នុងពេលរៀន អ្នកទាំងពីរបានអង្គុយជិតគ្នាជានិច្ច ។ លោកគ្រូឈ្មោះ សិត គុលល័ស ជាអ្នកបង្រៀនក្នុងវគ្គនេះ ។ ការសិក្សានៅក្នុងថ្នាក់បានធ្វើឲ្យមានការចាប់អារម្មណ៍យ៉ាងខ្លាំងពីកម្មាភិបាលធំៗ ។

មូសា សុខា និង ម៉ាត់ រកីយ៉ាស់



សុខា បានប្រាប់ថា គាត់បានស្គាល់ រកី នៅពេលដែល រកី មករៀនក្នុងវគ្គជាមួយគ្នា ។ តាំងពីបានស្គាល់គ្នាបូករួមទាំងការទំនុកបម្រុងពីចាស់ៗដូចជាយាយម៉ាស់ តា សុះ ម៉ាន និងឪពុក

ម្ដាយរបស់ សុខា ឈ្មោះ ស៊ុន និងម៉ាត់ ចៅ ផងអ្នកទាំងពីរបាន ក្លាយទៅជាមិត្តប្ដូរផ្ដាច់នឹងគ្នា ។ សុខា និយាយថា “សូម្បីតែគេងក៏គេងនៅលើគ្រែតែមួយជាមួយគ្នាដែរ” ។

ដោយភាពឆ្លាតវៃនិងម៉ឺងម៉ាត់ អ្នកទាំងពីរ(សុខានិងរកី) បានត្រូវបានជ្រើសរើសឲ្យថតជាគំរូដល់ខ្មែរឥស្លាមដទៃទៀតនិងជាការអួតសរសើរមិនដាច់នូវការលះបង់ខ្ពស់នៃអ្នកទាំងពីរផងនៅពេលបញ្ចប់វគ្គសិក្សាលើកនេះ ។ មោទកភាពនិងកិត្តិយសបានកើតមានឡើងយ៉ាងទន្ទឹមគ្នាសម្រាប់សុខា និង រកី ។ អ្វីៗដែលអ្នកទាំងពីរបានធ្វើ និងរូបថតដែលអ្នកទាំងពីរបានថតសុទ្ធតែជាការអួតអាងមួយដល់ប្រជាជនដទៃទៀតថា ខ្លួនជាយុវនារីគំរូនិងជាអ្នកស្នេហាជាតិដែលលេចធ្លោជាងគេ ។ ប៉ុន្តែផ្ទុយទៅវិញ សុខានិយាយប្រាប់ថា“ខ្ញុំចូលបដិវត្តន៍គ្មានដឹងរឿងអ្វីក្រៅពីសប្បាយឡើយ” ។

រូបថតមួយសន្លឹកនេះត្រូវបានផ្សព្វផ្សាយជាសាធារណៈថាជាសមមិត្តនារីឥស្លាមគំរូពីរនាក់ក្នុងជួរបដិវត្តន៍ ។ អត្ថន័យជាច្រើនមានបង្កប់នៅក្នុងរូបថតមួយសន្លឹកនេះដែលឆ្លុះបញ្ចាំងពីស្ថានភាពនយោបាយនាពេលនោះ(១៩៧៣) ។ ស្ថិតក្នុងសម្លៀកបំពាក់ជាឯកសណ្ឋានកម្មាភិបាលខ្មែរក្រហមដែលមានពាក់មួកស្បែកជើងកង់ឡាន និងបង់កក្រមា ពិតជាធ្វើឲ្យមានការចាប់អារម្មណ៍ថាជាកម្មាភិបាលដែលផុសចេញពីវណ្ណៈកម្មករកសិករពិតៗ ។

សុខា បានប្រាប់ថា គាត់ស្រឡាញ់សម្លៀកបំពាក់ដែលពាក់ថតនេះណាស់ ព្រោះជាសម្លៀកបំពាក់ដែលអង្គការចែកឲ្យ ។ ចំណែកឯស្បែកជើងកង់ឡានដែលពាក់នៅជាប់ជើងវិញ សុខាបានទិញក្នុងតម្លៃ១ជីមាស ។ នៅលើតួខ្លួនរបស់ សុខា ក្នុងរូបថតនេះមានពាក់ក្រវិលត្បូង នាឡិកាម៉ាកស៊ីទីហ្វៀន(រូបស្មាំង) និងខ្សែកមួយតម្លឹងប្រាំជី ។ រកី ដែលជាមិត្តភក្ដិថតជាមួយក៏មានពាក់គ្រឿងអលង្ការដូចគ្នាដែរ ។

សុខា បញ្ជាក់ថាគ្រឿងអលង្ការទាំងនេះមិនត្រូវបានដោះចេញឡើយ ព្រោះមិនទាន់មានការហាមឃាត់ ។ ប៉ុន្តែចំពោះសម្លៀកបំពាក់វិញ ពិតជាមានការហាមឃាត់យ៉ាងដាច់ខាត ។ សុខា បំភ្លឺថា នរណាក៏ដោយឲ្យតែហ៊ានស្លៀកពាក់មានចម្រុះពណ៌ គឺពិតជាត្រូវហៅទៅកសាងភ្លាម ពីព្រោះយល់ថាជាចក្រពត្តិ ជានាយទុនសក្តិភូមិនិងជាអ្នកដែលមិនទាន់លះបង់ជ្រះស្រឡះក្នុងការកសាងបដិវត្តន៍ ។ សុខា បន្តថា “កាលនោះអ្នកណាក៏ចូលចិត្តសម្លៀកបំពាក់ខ្មៅដែរ បើមានសម្លៀកបំពាក់ក្រៅពីពណ៌ខ្មៅគឺប្រាកដជាត្រូវយកទៅជ្រលក់ទឹកភក់ហើយដើម្បីឲ្យមានពណ៌ខ្មៅ” ។

មូលហេតុនៃការថតរូបនេះត្រូវបាន សុខា រៀបរាប់ប្រាប់ថា មានអត្ថន័យធំធេងណាស់សម្រាប់ភាពជាភាតរៈក្នុងការគោរពគ្នាទៅវិញទៅមកនិងបញ្ជាក់យ៉ាងច្បាស់ពីសាមគ្គីគ្នាជាអមតៈផង ។ សុខា បានចាប់ដៃគ្នាជាមួយ រកី ក្នុងន័យសាមគ្គីភាពខ្ពស់បំផុតនិងយូរអង្វែង ជាពិសេសចង់បញ្ជាក់ពីការសាមគ្គីគ្នារវាងខ្មែរអ៊ីស្លាម ។ ក្នុងរូបថត អ្នកទាំងពីរបានលើកដៃគោរពព្រមគ្នាក្នុងឯកសណ្ឋានជាកម្មាភិបាលខ្មែរក្រហម ។ ក្នុងន័យនេះ សុខាបានបញ្ជាក់ប្រាប់ថា “ឲ្យមានការបេះគោរពគ្នាទៅវិញទៅមករវាងកម្មាភិបាលនិងប្រជាជន និងរវាងខ្លួនគាត់និង រកី ។ គាត់បន្តថាការថតរូបមួយសន្លឹកនេះត្រូវបានគ្រោងទុកជាមុនរួចស្រេចដោយលោកតា សុះ ម៉ាន ដែលត្រូវជាជីតារបស់ រកី ។ លោកតាមានគោលបំណងច្បាស់លាស់ក្នុងការបណ្ដុះបណ្ដាលចៅរបស់គាត់និង សុខា ទៅថ្ងៃអនាគតឲ្យទៅជាកម្មាភិបាលគំរូនិងឈានមុខជានិច្ចនូវរាល់កិច្ចការទាំងឡាយរបស់បក្ស ។

សុខា បានសម្លឹងមើលរូបថតរបស់គាត់យ៉ាងយូរទើបនិយាយថា “ខ្ញុំពេញចិត្តនឹងរូបថតនេះណាស់ ព្រោះជារូបថតដែលខ្ញុំបានថតដំបូងបំផុតក្នុងមួយជីវិតរបស់ខ្ញុំ” ។ រូបថតបានបញ្ជាក់យ៉ាងច្បាស់ពីសកម្មភាពយ៉ាងរស់រវើកនៃជនបដិវត្តន៍ពីរនាក់ដែលកំពុងសាមគ្គីគ្នាវេញធ្លុងតែមួយសំដៅរកទិសដៅពិតប្រាកដនាពេលអនាគត ។ រូបថតមួយសន្លឹកនេះ បានធ្វើឲ្យ សុខាគិតទៅដល់អតីតភាពរបស់ខ្លួនថា មិនគួរធ្វើបដិវត្តន៍ដោយគ្មានដឹងអ្វីទាល់តែសោះនោះឡើយ ។ ការធ្វើបដិវត្តន៍របស់ សុខា បានដើរដល់ពាក់កណ្ដាលផ្លូវទៅហើយ ក៏ត្រូវឈប់ទៅវិញព្រោះត្រូវយកគូស្រករ ។ សុខា បានរៀបការនៅឆ្នាំ១៩៧៤ ជាមួយ ណុះលាស់ ។ សុខា បានរៀបរាប់ពីការងាររបស់គាត់តាំងពីចូលបដិវត្តន៍ប្រាប់ថា នៅឆ្នាំ១៩៧២ គាត់បានចូលធ្វើជាអ្នកសិល្បៈខាងសម្ដែងចម្រៀងនិងច្រៀង ។ បទចម្រៀង **(តទៅទំព័រ៦០)**

**(តពីលេខមុន)** នៅពេលដែល "អ្នកមានកំហុស" ត្រូវបាននាំយកមកមន្ទីរស-២១ គ្មានសកម្មភាពណាមួយត្រូវបានចាត់ទុកថាជារឿងចៃដន្យទេ ទោះជាសកម្មភាពពិត ឬប្រឌិត សំខាន់ ឬមិនសំខាន់ក៏ដោយ ។ តើទៅជាយ៉ាងម៉េចទៅវិញបើមេដឹកនាំបក្សអនុវត្តតាមច្បាប់ប្រវត្តិសាស្ត្រនោះ? អារម្មណ៍ប្រឆាំងនឹងបដិវត្តន៍របស់អ្នកទោសដែលស្តែងឲ្យឃើញតាមរយៈការចាប់ខ្លួន និងតាមគំនិតរបស់អ្នកសួរចម្លើយ គឺជះឥទ្ធិពលដល់អ្វីៗគ្រប់យ៉ាងដែលខ្លួនបានប្រព្រឹត្ត រួមទាំងអ្វីដែលអាចកើតឡើងចំពោះអ្នកដទៃទៀតដែលជាការបម្រើដោយស្មោះស្ម័គ្រចំពោះបក្ស ។ "បទល្មើស" ដែលត្រូវផ្តន្ទាទោសតាមច្បាប់ត្រូវបានកំណត់ទៅតាមកម្រិតនៃ "អំពើក្បត់" ដោយបង្ហាញនូវមូលហេតុក្បត់ចំពោះអ្វីៗដែលអ្នកទោសបានប្រព្រឹត្តឡើង ។

ស្ថិតនៅក្រោមការបំភិតបំភ័យឲ្យរកគំនិតច្នៃប្រឌិត ប៉ុន្តែដោយការបង្ខំឲ្យនឹកស្រមៃនោះ អ្នកទោសបានខំ "រកនឹក" រាល់កំហុសទាំងឡាយដែលអ្នកសួរចម្លើយគ្មានបន្ទូរដៃនិងដីគូរឲ្យរន្ធត់ចង់ឲ្យខ្លួនឆ្លើយ ។ ជាលទ្ធផលអ្នកទោសខ្លះបានបង្ហាញនូវចម្លើយដ៏ចម្លែកៗដែលជាការដាក់ចេញជាចម្លល់អំពីការរៀបចំបណ្ណសារទាំងអស់នៅមន្ទីរ ស-២១ ។ ឧទាហរណ៍ ឡឿន មឿន ទាហាននៅវរសេនាធំលេខ ១៧១ បានឆ្លើយថា÷ "នៅខែ១ ឆ្នាំ១៩៧៧ ខ្ញុំបានបាញ់ស្ពានទូតវៀតណាមអស់បីគ្រាប់ ។ ខ្ញុំបាញ់ស្ពានទូតចិនអស់បីគ្រាប់ហើយពីរគ្រាប់ទៀតបាញ់ដាក់សណ្ឋាគារសម្រាប់កម្មករក្មេងៗជនជាតិចិន ស្នាក់នៅដើម្បីផ្តាច់នយោបាយរបស់កម្ពុជាចំពោះចិន ។ ក្រោយមកខ្ញុំបានរាយការណ៍ទៅ សុវណ្ណ អំពីបញ្ហាដែលខ្ញុំជួបប្រទះក្នុងការប្រមូលកម្លាំង...ក្រោយមកទៀតនៅខែ៣ ឆ្នាំ១៩៧៧ ខ្ញុំបានប្រាប់ សុវណ្ណ ។ ដុត និងខ្ញុំ បានទៅបាញ់ដាក់ស្ពានទូតអាល់បានី បីគ្រាប់ បាញ់ដាក់ស្ពានទូតកូរ៉េបីគ្រាប់ និងដាក់វិមានឯករាជ្យមួយគ្រាប់ ។ បាញ់ហើយខ្ញុំបានទៅប្រាប់សុវណ្ណអំពីការលំបាកនៅក្នុងការបាញ់នេះ ។ នៅពេលខ្ញុំប្រាប់គាត់ សុវណ្ណ និយាយថា "សមមិត្តគួរតែលាក់បាំងឲ្យជិត មិនត្រូវឲ្យគេដឹងថាមិត្តពាក់ព័ន្ធក្នុងសកម្មភាពបាញ់នេះទេ ។ យើងគួរតែរៀបចំផែនការខ្លាំងៗមួយចំនួនទៅថ្ងៃអនាគត ហើយប្រើប្រាស់កម្លាំងដែលមិត្តប្រមូលបានកន្លងមក ។ យើងចាំបាច់ត្រូវតែបាញ់ដាក់ស្ពានទូត កន្លែងអគ្គការ រោងចក្រនិងក្រសួងមន្ទីរនានានៅភ្នំពេញ ។ ក្រោយពីទទួលសេចក្តីណែនាំនេះរួចមក ខ្ញុំបានត្រឡប់មកផ្ទះវិញ ហើយនៅថ្ងៃទី២៧ ខែ៣ ឆ្នាំ[១៩]៧៧ ខ្ញុំក៏ត្រូវបានចាប់ខ្លួនតែម្តង" ។



**សំឡេងពីមន្ទីរ ស-២១**
**វគ្គទី៤: បង្កើតសំណួរទម្លាក់កំហុស**
**ដោយសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ**

ក្នុងចំណោម"ទោសកំហុស"បណ្តាលមកពីសកម្មភាពមិនល្អដែលរៀបរាប់មកនេះនិងនៅក្នុងចម្លើយសារភាពនានា គ្មានទោសកំហុសណាមួយអាចត្រូវដាក់ទណ្ឌកម្មដល់ជីវិតទេ កាលពីរបបមុនបដិវត្តន៍ ។ អំពើខ្លះមិនទាំងធ្វើឲ្យគ្រួសារ ឬអ្នកជិតខាងអ្នកប្រព្រឹត្តបទល្មើសចាប់អារម្មណ៍ទៀតផង ។ ប៉ុន្តែជាការសំខាន់ណាស់សម្រាប់បុគ្គលិកធ្វើការនៅមន្ទីរស-២១ ក្នុងការស្រង់យកចម្លើយសារភាពដែលឆ្លើយថា បានធ្វើអ្វីមួយ ។ ឧទាហរណ៍ អឿ អៀប បានឆ្លើយថាមាន"អាកប្បកិរិយាចង្អៀតចង្អល់" ដោយមិនស្រោចទឹកដំណាំនិងមិនគោរពការរស់នៅជាសមូហភាព ។ ម៉ុល មឿន បានឆ្លើយថាបាន "ហូបច្រើនដូចជាកម្មាភិបាលដែរ" ចំណែកឯ ពៅ ឈឹមថា គាត់ "ខ្ជិល ហើយមិនត្រឹមត្រូវនិងនិយាយពីរឿងស្រីញី" ។

ចម្លើយសារភាពក្រោយឆ្នាំ១៩៧៦ ភាគច្រើនមានបញ្ចូលផ្នែកមួយដាក់ថា"ផែនការ"ដែលរៀបរាប់អំពីសកម្មភាពប្រឆាំងនឹងបដិវត្តន៍ដែលអ្នកទោសសង្ឃឹមទុកថានឹងអនុវត្ត ប៉ុន្តែត្រូវបានខកខានដោយសារខ្លួនត្រូវចាប់ឃុំឃាំង ។ ចំពោះអ្នកទោសជាច្រើននាក់ "ផែនការ"របស់ខ្លួនបានបង្ហាញនូវភាពមិនគួរឲ្យចាំបាន

ឬទឹកស្អុយដល់ ។ ដាក់ស្តែងអ្នកសួរចម្លើយបានតវ៉ាជាញឹកញយនៅក្នុងចំណាររបស់ខ្លួនដាក់លើចម្លើយសារភាពថា “ផែនការ” របស់អ្នកទោសមានលក្ខណៈ“ប្រេបូកប្រេបល់” “ខ្វះខាត” ឬ“មិនច្បាស់លាស់” ។ ផែនការមួយចំនួនត្រូវបាន “លាតត្រដាង” ក្រោយពីការធ្វើទារុណកម្មដ៏ធ្ងន់ធ្ងរ ។ ទម្រង់ចម្លើយសារភាពដែលចាំបាច់ត្រូវមាន គឺថាអ្នកទោសម្នាក់ៗដែលត្រូវបានសួរចម្លើយយូរនឹងត្រូវធ្វើឯកសារដោយភ្ជាប់មកជាមួយនូវ “ផែនការ”ផង ។ វាជាការសំខាន់សម្រាប់ប្រវត្តិសាស្ត្ររបស់បក្ស សុខុមាលភាពរបស់អ្នកដែលនៅក្នុងជួរបក្សដោយសារតែ “ផែនការ”មានច្រើន ហើយគ្មានប្រសិទ្ធភាព ។ “ផែនការ”ជាច្រើនដូចដែលបានរៀបរាប់នៅក្នុងចម្លើយសារភាពនានាមិនសមហេតុសមផល ហើយនៅក្នុងករណីជាច្រើនផែនការទាំងនេះប្រហែលជាបញ្ជាក់អំពីអ្វីដែលអ្នកសួរចម្លើយជឿថាជាការសមរម្យ ។ ដូច្នេះយុទ្ធជនមកពីជនបទបានឆ្លើយសារភាពថាបានរៀបចំផែនការធ្វើឃាត“អង្គការ ឬបងលេខ១”ដែលខ្លួនមិនដែលបានឃើញមុខទាល់តែសោះ ឬថា“ផ្តួលរំលំបដិវត្តន៍” នៅក្នុងពេលដែលខ្លួនមានគ្នាតែមួយក្តាប់តូចនិងគ្មានអាវុធនោះ ។

អតីតឆ្មាំគុកមន្ទីរស-២១ ឈ្មោះ ទុំ ធុន និយាយថាបានរៀបចំផែនការជាមួយអ្នកធ្វើការជាមួយក្នុងការបន្ធូរខ្នោះអ្នកទោស បើកទ្វារចំហ ធ្វើជាដេកលក់នៅច្រកចេញ-ចូល ដើម្បីបើកដៃឲ្យអ្នកទោសលួចរត់ចេញពីគុក ហើយថាខ្លួនបានវាយអ្នកទោសរហូតដល់ស្លាប់ ។ គួរឲ្យចាប់អារម្មណ៍ដែរ ទុំ ធុន មិនបានឆ្លើយថាបានប្រព្រឹត្តកំហុសទេ ។ បើឆ្លើយគ្រង់នឹងនាំឲ្យមានបញ្ជីស្មើឈ្មោះខ្លួនមិនខានឡើយ ។ ឆ្មាំនៅមន្ទីរស-២១ម្នាក់ទៀតឈ្មោះ ហុត បានឆ្លើយថាខ្លួន“បានរៀបចំផែនការធ្វើជាដេកលក់នៅពេលយាម” ។ អ្នកកាន់ខាងការស្មឹសម្រាប់ថតភាពយន្តឈ្មោះ គីម យូ បានរៀបចំផែនការ“បន្តុំទំនាស់ក្នុងជួរភ្ញៀវបរទេស”ដោយរៀបចំបញ្ចាំងខ្សែភាពយន្តជូនភ្ញៀវទស្សនាមិនបានល្អ ។ ឈ្មោះ ជួន នៅកងពលលេខ៤៥០ បានសារភាពថាខ្លួនបានរៀបចំផែនការ“ធ្វើសតិអារម្មណ៍” អ្នកធ្វើការជាមួយបាន៣០នាក់ ដោយមិនបាននិយាយច្បាស់ថា ផែនការនេះត្រូវសម្រេចតាមរបៀបណាទេ ។ ចំណែកឯអ្នកទោសម្នាក់ទៀតបានរៀបចំផែនការបំផុសឲ្យមិត្តភក្តិរបស់ខ្លួនរត់ទៅប្រទេសថៃ ឬប្រទេសវៀតណាម ។ និយាយរួម ផ្នែកនិយាយអំពី“ផែនការ” នៅក្នុងចម្លើយសារភាពនៅក្នុងករណីជាច្រើនមើលទៅហាក់ដូចជាត្រូវបានផ្គុំគ្នាដោយអ្នកធ្វើការនៅមន្ទីរស-២១ ។ ផែនការនេះបង្ហាញរឿងរ៉ាវតិចតួចបំផុត ហើយប្រហែលជាការប្រឌិតឲ្យដូចៗគ្នាផងនៅក្នុងឯកសារទាំងនេះ ។







លិខិតប្រវត្តិរូបខ្លីៗច្រើនបញ្ចប់ដោយមានដាក់ឈ្មោះនិងអាសយដ្ឋានរបស់សមាជិកគ្រួសារដែលអាចនឹងត្រូវហៅឲ្យមកធានាអះអាងថា រាល់សំណេរអំពីប្រវត្តិជីវិតនេះពិតជាត្រឹមត្រូវមែន ។ នៅក្នុងចម្លើយសារភាព ឈ្មោះអ្នកទាំងនេះតែងតែត្រូវបានជំនួសនៅចុងអត្ថបទដោយពាក្យថា“ខ្សែក្បត់”និង “ខ្សែសម្ងាត់” ។ បញ្ជីទាំងនេះហាក់ដូចជាមានភាពងាយស្រួលសម្រាប់អ្នកសួរចម្លើយក្នុងការស្រង់យកពត៌មាន ហើយទិន្នន័យនៅក្នុងបញ្ជីនេះក៏ងាយនឹងអាចបញ្ជាក់ពីប្រភពផ្សេងៗទៀត ។ ក្នុងករណីជាច្រើនអ្នកទោសបានផ្តល់ឈ្មោះមនុស្សដែលត្រូវបានចាប់ខ្លួនហើយ ឬដែលបោសសម្អាតដោយអង្គការរួចហើយ ។ ហើយឈ្មោះទាំងនេះត្រូវបានចារថា “ចាប់” ចំណែកឈ្មោះមួយចំនួនទៀតត្រូវបានដាក់ជាសញ្ញា “X” ប្រហែលជាចង់និយាយថាឈ្មោះនេះត្រូវបានសម្លាប់រួចហើយ ។ បញ្ជីដាក់ថា “ខ្សែ”ត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការចាប់ខ្លួនបន្តទៅទៀត ។ ឈ្មោះទាំងនេះក៏ត្រូវបានយកមកសង្ខេបនិងវាយជាអង្គលីលេខដោយដាក់ឈ្មោះអ្នកដែលពាក់ព័ន្ធនៅតាមអង្គភាពយោធា តំបន់ មន្ទីរ រោងចក្រ ឬការដ្ឋាននានា ។

ហេតុអ្វីទៅបានជារាល់តែចងក្រងនិងប្រឌិតជាឯកសារគរដូចភ្នំយ៉ាងដូច្នេះទៅវិញ? មូលហេតុមួយទំនងគួរឲ្យជឿដូច

ដែលខ្ញុំលើកឡើងនៅក្នុងវគ្គទី៣ គឺថាថ្នាក់ដឹកនាំបក្សចង់បានចម្លើយសារភាពដាក់ក្នុងប្រអប់ទុកជាឯកសារដើមសម្រាប់បញ្ជាក់ពីការអបអរជ័យជម្នះជាប្រវត្តិសាស្ត្ររបស់បក្សបន្តទៅមុខឥតឈប់ឈរ ។ មូលហេតុមួយទៀត គឺថា ចម្លើយសារភាពនិងរូបថតពាក់កណ្តាលខ្លួនបានបង្ហាញពីគោលគំនិតមិនទុកចិត្តនិងសង្ស័យរបស់ថ្នាក់ដឹកនាំបក្ស ហើយឯកសារទាំងនេះត្រូវបានប្រើប្រាស់សម្រាប់ធ្វើឲ្យថ្នាក់ដឹកនាំទាំងនេះជឿថាខ្មាំងរាប់មិនអស់កំពុងតែត្រូវបានវែកមុខសួរចម្លើយនិងសម្លាប់ជាបន្តបន្ទាប់ ។ ក៏ប៉ុន្តែការពន្យល់ផ្សេងៗទៀតមានបុសគល់ចេញមកពីសំណេរប្រវត្តិសាស្ត្រនិងប្រពៃណីនៅក្នុងប្រទេសកម្ពុជា ។

នៅក្នុងប្រទេសកម្ពុជាមុនសម័យបដិវត្តន៍ អំណាចកណ្តាលនិងការកាន់កាប់ឯកសារប្រវត្តិសាស្ត្រពិតជានៅជាប់គ្នាស្អិតល្មួត ។ កាលប្បវត្តិ គឺជាប្រវត្តិសាស្ត្រដែលត្រូវបានរៀបចំនៅព្រះបរមរាជវាំង និងព្រះរាជបរិពារជាន់ខ្ពស់ ដើម្បីប្រារព្ធជាព្រះរាជពិធីនិងធ្វើឲ្យពង្សាវលីមានលក្ខណៈស្របច្បាប់សម្រាប់អ្នកកាន់អំណាចនិងអ្នកស្នងរាជ្យបន្តបន្ទាប់ទៀត ។ ឯកសារអំពីវីរបុរសដែលតម្កល់ទុកនៅព្រះបរមរាជវាំងក្លាយជាផ្នែកមួយនៃសញ្ញាណសន្តតិវង្សរបស់ព្រះរាជា ។ នៅទូទាំងប្រទេសកម្ពុជាការសរសេរប្រវត្តិសាស្ត្រត្រូវបានឲ្យតម្លៃខ្ពស់ណាស់ មួយផ្នែកគឺដោយសារការចេះអាន ចេះសរសេរ គឺជាជំនាញមួយដែលបព្វជិតនិងសិស្សឃ្លាំមើលយ៉ាងយកចិត្តទុកដាក់ ហើយមួយផ្នែកទៀត គឺដោយសារអត្ថបទសំណេរជាច្រើនផ្ទុកនូវមាតិកា(ដែលមានសារប្រយោជន៍និងសម្ងាត់)ឬមានឥទ្ធិពល ។ នៅក្នុងន័យព្រះពុទ្ធសាសនា ប្រវត្តិសាស្ត្រត្រូវបានចាត់ទុកថា ជាទម្រង់ការនៅក្នុងដំណើរធ្លាក់ចុះដែលមិនអាចទប់បានក្នុងអំឡុងពេលរាប់ពាន់ឆ្នាំក្រោយពីព្រះពុទ្ធត្រាស់ដឹងនិងចូលនិព្វាននៅឆ្នាំ៥៤៣មុនគ្រិស្តសករាជ ។ នៅក្នុងអំឡុងពេលដ៏វែងនេះ ប្រវត្តិសាស្ត្រមានចារិកតាមសន្តតិវង្សជានិទានខ្លីៗគួរឲ្យចាប់អារម្មណ៍ តែមិនមែនជាការពិត និងកើតមានឡើងក្នុងរយៈពេលដ៏ទៀងទាត់ដោយផ្តោតសំខាន់លើសកម្មភាពរបស់អ្នកកាន់អំណាច និងបញ្ចូលនិទានខ្លីៗយកមកពីកាលប្បវត្តិផ្សេងៗទៀត(ដោយដូរឈ្មោះ) ដែលនិយាយអំពីរឿងគួរឲ្យសប្បាយនៅក្នុងសមរភូមិ ពិធីបុណ្យផ្សេងៗ និងដំណើរស្នេហារឿងមួយចំនួនទៀត ។

ក្រោមរបប ប៉ុល ពត ឯកសារប្រវត្តិសាស្ត្រក៏ត្រូវបានតាក់តែងឡើង គ្រប់គ្រង និងកាន់កាប់ដោយ "ក្បាលម៉ាស៊ីន" ដឹកនាំ ហើយការនិយាយរឿងរ៉ាវប្រវត្តិសាស្ត្រនៅតែពិពណ៌នាអំពីបរាជ័យរបស់ខ្មាំងសត្រូវ ។ នៅពេលទន្ទឹមគ្នានេះដែរ ការសរសេរអំពីប្រវត្តិសាស្ត្រត្រូវបានចាប់ផ្តើមប្រឌិតតាមវិធីមួយផ្សេង ។ របៀបសរសេរទាំងពីរនេះទាក់ទងទៅនឹងព្រឹត្តិការណ៍ដែលគាំទ្រដល់អ្នកកាន់អំណាចណាម្នាក់ ។ ចំណែកឯប្រវត្តិសាស្ត្របែបម៉ាក្ស-ឡេនីន គឺទាក់ទងនឹងការពន្យល់ពីបាតុភូត ការអង្កេតពីរឿងពិតដោយមានការពិភាក្សានិងការជជែកវែកញែកច្បាស់លាស់រវាងមនុស្សគ្រប់ឋានៈដែលជារបៀបសរសេរបែបទំនើបមួយប្រហែលជាដើរតាមគន្លងច្បាប់វិទ្យាសាស្ត្រ ។ ដោយធ្វើម្ចាស់បានលើច្បាប់ទាំងនេះ តាមការគិត គឺបក្សម៉ាក្ស-ឡេនីនដូចជាបក្សកុម្មុយនិស្តកម្ពុជាដែរអាចឆក់យកអំណាចមកគ្រប់គ្រងនិងរក្សាខ្លួនឯងផ្ទាល់រហូតមក ។ ដូច្នេះនៅពេលដែលអ្នកនាំពាក្យរបស់បក្សប្រកាសនៅឆ្នាំ១៩៧៦ថា"ប្រវត្តិសាស្ត្រពីរពាន់ឆ្នាំ"បានបញ្ចប់បុគ្គលនោះប្រហែលជាមិនត្រឹមតែចង់និយាយថារាល់ការអនុវត្តកាលពីអតីតកាលបានរលាយបាត់អស់ហើយនោះទេ តែថែមទាំងចង់និយាយថា ប្រវត្តិសាស្រផ្តោតតែទៅលើបក្សពេលនេះអាចជំនួសកាលប្បវត្តិនិងអ្វីៗដែលមានចរិតដូចគ្នានេះ ។ ការសរសេរប្រវត្តិសាស្ត្រកម្ពុជាក៏ដូចជាទំនាក់ទំនងសង្គមត្រូវបានក្រឡាប់ចាក់អស់ហើយ ។

នៅក្នុងឯកសារដែលគ្មានចុះកាលបរិច្ឆេទមានចំណងជើងថា"លក្ខណៈសម្បត្តិរបស់បក្សកុម្មុយនិស្តកម្ពុជា" អ្នកនាំពាក្យរបស់បក្សបានលើកឡើងចំណុចទាំងនេះក្រោយពេលផ្តល់នូវចំណុចសំខាន់ៗនៃប្រវត្តិបក្ស ។ "ពួកជិះជាន់កេងប្រវ័ញ្ចបានសរសេរប្រវត្តិដើម្បីជិះជាន់កេងប្រវ័ញ្ចប្រជាជនកាន់តែខ្លាំងថែមទៀត ។ ចំណែកយើងវិញសរសេរប្រវត្តិរបស់ប្រទេសយើង គឺយើងសរសេរអំពីការតស៊ូរបស់បក្សនិងប្រជាជនយើងដើម្បីឯករាជ្យ ហើយមិនមែនធ្វើជាខ្ញុំគេទៀតទេ ។ ឧទាហរណ៍ពេលយើងសរសេរប្រវត្តិអង្គរយើងសរសេរថាប្រជាជនជាអ្នកកសាងនេះជាការពិតប្រជាជនជាអ្នកកសាងមិនមែន

ស្តេចទេ» ។

ប្រវត្តិបក្សជាច្រើនចាប់ពីទសវត្សរ៍ឆ្នាំ៧០ បង្ហាញពីការផ្តោតសំខាន់និងវិធីសាស្ត្រដែលមានលក្ខណៈខុសគ្នា ។ ជាមួយអ្វីដែល ទីម៉ែធី ខានី បានហៅថា «ជ័យជម្នះមិនសង្ស័យថានឹងទទួលបាន» របស់បក្សនេះនៅខែមេសាឆ្នាំ១៩៧៥ ។ បក្សកុម្មុយនិស្តកម្ពុជាបានបញ្ចប់នូវអ្វីដែលខ្វះខាតនៅក្នុងឯកសារទាំងឡាយកាលពីដើមដំបូង ហើយក្តាប់បាន«កង់ប្រវត្តិសាស្ត្រ» ។ ដោយទទួលបានជ័យជម្នះប្រវត្តិសាស្ត្រកម្ពុជា«កាលពីពីរពាន់ឆ្នាំមុន» ប្រសព្វគ្នាជាមួយនឹងការឡើងកាន់អំណាចរបស់បក្ស ។ និយាយម្យ៉ាងវិញទៀត ជ័យជម្នះរបស់ជនកុម្មុយនិស្តនៅឆ្នាំ១៩៧៥ បង្ហាញច្បាស់អំពីអតីតភាពរបស់បក្ស ។ បំណកស្រាយផ្សេងៗអំពីអតីតភាពនិងសត្រូវស៊ីសាច់ហុតឈាមរបស់បក្ស គឺបក្សមិនឲ្យអ្នកណាគិតដល់ ហើយបក្សត្រូវតែ «បោសសម្អាត» ចោលទាំងអស់ ។

ការទាក់ទិនរបស់មន្ទីរស-២១ នៅក្នុងការសរសេរប្រវត្តិ-សាស្ត្ររបស់បក្សចាប់ផ្តើមមានសារសំខាន់ក្រោយពីខែមេសាឆ្នាំ១៩៧៦ (ដូចដែលយើងឃើញស្រាប់) ភាពចលាចលផ្នែកយោធានៅទីក្រុងភ្នំពេញត្រូវបានថ្នាក់ដឹកនាំបក្សកុម្មុយនិស្តកម្ពុជាហៅថាជាការបះបោរដែលគំរាមកំហែងដល់ការដឹកនាំរបស់បក្សនិងបំផ្លាញដល់ប្រវត្តិជោគជ័យដែលមានមកដល់បច្ចុប្បន្ន ។ ដោយសារមាន«ភ័ស្តុតាង»យ៉ាងច្រើនសន្ធឹកសន្ធាប់ស្តីអំពីការរួមគំនិតដែលចេញពីមន្ទីរស-២១ដល់មជ្ឈិមបក្ស ប្រវត្តិបក្សចាប់ពីពេលនោះមកត្រូវបានយល់ជាទូទៅថាជាការតស៊ូមិនចេះចប់ប្រឆាំងនឹងខ្មាំងផ្ទៃក្នុង ។ មន្ទីរស-២១ ក្លាយជាមុខកាំបិតដ៏មុតស្រួចរបស់របបកម្ពុជាប្រជាធិបតេយ្យ ។

ដូចដែលខ្ញុំបានលើកឡើងខាងដើមមកហើយថា ចម្លើយសារភាពស្រង់បានមកពីមន្ទីរស-២១ បានបម្រើឲ្យគោលបំណងផ្នែកចិត្តសាស្ត្រដោយបង្ហាញចេញនូវគំនិតសង្ស័យនិងមិនទុកចិត្តរបស់ថ្នាក់ដឹកនាំនៃរបបនេះ ។ ចំពោះបញ្ហានេះ ភាពដូចគ្នារវាងវិធីសាស្ត្រនិងគោលបំណងរបស់អ្នកសួរចម្លើយនិងការយល់ឃើញរបស់លោក ហ្វ្រឹដ ដែលមានចរិតជាការព្យាបាលរោគតាម «បុរាណវិទ្យា» គឺគួរឲ្យចាប់អារម្មណ៍បំផុត ។ អ្នកសួរចម្លើយនៅមន្ទីរស-២១ ក៏ដូចជាមនោវិភាគវិទូដែរ គឺជីកកកាស់ការចងចាំរបស់«បុគ្គលមានកំហុស»ដែលត្រូវបានសន្មតថា លាក់បាំងប្រវត្តិសកម្មភាព ផែនការ និងខ្សែរយៈប្រឆាំងនឹងបដិវត្តន៍ ។ អ្នកសួរចម្លើយមិនខុសពីមនោវិភាគវិទូជាច្រើនរូបទេ បានធ្វើជាដឹងនូវអ្វីដែលខ្លួនកំពុងតែរុករក ហើយមានគំនិតមួយចំនួនទៅលើ «ការចងចាំ» ដែលខ្លួនចង់ឲ្យអ្នកទោស «រំឭកឡើងវិញ» ។ មិនតែប៉ុណ្ណោះ អ្នកសួរចម្លើយដឹងអំពីទម្រង់ចម្លើយសារភាពពេញលេញ ប៉ុន្តែអ្នកទោសក៏ដូចជាអ្នកជំងឺចិត្តសាស្ត្រជាច្រើននាក់ទៀតមិនបានដឹងឡើយ ។

ទាក់ទងនឹងរឿងផ្សេងៗទៀត ការប្រៀបធៀបរវាងអ្វីដែលបានកើតឡើងនៅមន្ទីរស-២១ និងអ្វីដែលកើតឡើងម្តងម្កាលនៅក្នុងមនោវិភាគ គឺយកជាការមិនបានទេ ។ នៅក្នុងការចាប់ផ្តើមដំបូង អ្នកវិភាគកម្រនឹងផាកទៅប្រើអំពើហិង្សាណាស់ ចំណែកឯមន្ទីរស-២១វិញ ចាប់ផ្តើមភ្លាមចូលដល់អំពើហិង្សាតែម្តង ។ អ្នកជំងឺសរសៃប្រសាទជាទូទៅមានសេរីភាពក្នុងការងើបឈរនិងដើរចេញដោយបោះបង់ចោលនូវដំណើរការកំពុងតែប្រព្រឹត្តទៅ ឬស្វែងរកដៃគូសន្ទនាដែលមានចរិតទន់ភ្លន់ មានក្តីអាណិតអាសូរជាងអ្នកមុន ។ ចំណែកឯអ្នកទោសនៅមន្ទីរស-២១ គឺត្រូវបានសម្លាប់ចោលទាំងអស់ បន្សល់ទុកនូវចម្លើយសារភាពដែលជាអក្ខរាចុងក្រោយពីផ្ទះមរណៈ ។ ទិដ្ឋភាពមួយទៀតនៃការសួរចម្លើយនៅមន្ទីរស-២១ ដែលផ្ទុយគ្នាទៅនឹងមនោវិភាគនោះ គឺថាគំនិតវើរវាយដែលកំពុងតែត្រូវបានជីកកាស់សើរើបង្ហាញចេញនិងនិយាយចេញអំពីគុកសម្ងាត់របស់ប៉ុល ពត មិនមែនជាអំពើប្រព្រឹត្តដោយអ្នកទោសទេ ប៉ុន្តែជាអំពើដែលអ្នកទោសទទួលរងពីអ្នកសួរចម្លើយជួសមុខឲ្យចៅហ្វាយរបស់ខ្លួនក្នុងជួរមជ្ឈិមបក្ស ។ ភាពខុសប្លែកពីគ្នារវាងការវិភាគនិងការសួរចម្លើយគឺប្រហែលជាថា ការវិភាគតាមទ្រឹស្តីមានគោលបំណងធ្វើឲ្យអ្នកជំងឺមានភាពប្រសើរឡើង ចំណែកឯការសួរចម្លើយមានគោលបំណងស្រង់យកភស្តុតាងពីអ្នកទោសដើម្បីយកមកប្រើក្នុងដំណើរនីតិវិធី ។ នៅពេលដែលការសួរចម្លើយនៅមន្ទីរស-២១ មានបំណងជួយជំរុញឲ្យមានចម្លើយដែលស្របគ្នាទៅនឹងទ្រឹស្តីអប់រំតាមលទ្ធិម៉ៅនិយមបែបបទក្នុង

ការសួរទាំងពីរយ៉ាងនេះហាក់ដូចជាចូលគ្នាខ្លះ ។ ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ក៏នៅមានភាពដូចគ្នាមិនគួរឲ្យជឿរវាងការសន្ទនាទាំងពីរបែប និងរវាងទំនាក់ទំនងអំណាចដែលផ្ទៀងម្ខាងៗ ។ លោក ហ៊្រីដ ខ្លួនឯងធ្លាប់បានផ្តល់ជាយោបល់ថា៖ «យើងមិនត្រូវជឿអ្វីដែលអ្នកជំនឺសរសៃប្រសាទនិយាយទេ យើងត្រូវទាញការសន្និដ្ឋានគ្រប់ពេល ហើយប្រាប់អ្នកជំងឺផងថា គេនៅលាក់រឿងអ្វីម្យ៉ាង...យើងត្រូវតែទទូចហើយទទូចទៀត យើងត្រូវសម្តែងការគាបសង្កត់ម្តងហើយម្តងទៀត ហើយបង្ហាញថាយើងមិនចេះខុសទេធ្វើយ៉ាងនេះរហូតដល់យើងបានទទួលអ្វីម្យ៉ាង» ។

វិធីរបស់អ្នកសួរចម្លើយនៅមន្ទីរស-២១ដែលមានធម៌ត្រជាក់ជាងលោក ហ៊្រីដ នោះលើកឡើងនូវចំណុចដូចគ្នានេះដែរ នៅពេលយើងរំពុកឡើងនូវវាសនារបស់អ្នកទោស៖ «អ្នកទោសត្រូវសរសេរចម្លើយសារភាពតាមសំឡេងខ្លួនឯងផ្ទាល់ច្បាស់ដោយប្រើប្រយោគពាក្យពេចន៍និងគំនិតផ្ទាល់ខ្លួន ។ យើងគួរតែចៀសវាងកុំប្រាប់អ្នកទោសនូវអ្វីដែលគេចង់សរសេរ ។ នៅពេលរៀបរាប់ដំណើររឿងរបស់ខ្លួន ឬសរសេរចប់សព្វគ្រប់ហើយ ទើបយើងលើកឡើងនូវចំណុចខ្សោយសង្កត់ឲ្យគេពន្យល់ថាតើហេតុអ្វីបានជាធ្វើយ៉ាងដូច្នេះ? ហេតុអ្វីក៏កុហកយ៉ាងនេះ? ហេតុអ្វីលាក់កំបាំងរឿងនេះ? ហេតុអ្វីបានជានិយាយកាត់ៗបែបនេះទៅវិញ?» ។

ហេតុផលទីបីអំពីមូលហេតុនៃការថែរក្សាបណ្ណសារមន្ទីរស-២១ត្រូវបានផ្តល់ជាយោបល់ដោយលោក ភីតធ័រ ហូលឃ្វីស នៅក្នុងបរិបទផ្សេងៗដែលសរសេរអំពី «ការបញ្ចូលគ្រប់ព័ត៌មាន»ស្តីអំពី«បរិយាកាសនយោបាយ»នៅសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត និងទំនាក់ទំនងរវាងការប្រមែប្រមូលព័ត៌មាននិងការថែរក្សាដោយប្រុងប្រយ័ត្នរបស់នគរបាលរដ្ឋ ។ ទីមួយ ហើយទីពីរទៀតសរសេរអំពីអ្វីដែល ហូលឃ្វីស ហៅថាជាការយល់ឃើញរបស់លោក បូល សឺវិច ថាជា«ការឆ្លាក់» ឲ្យចេញជារូបរាងសង្គម ។

ស្ថិតក្រោមការមើលឃើញតាមផ្លូវនេះ ព័ត៌មានដែលប្រមូលបាននៅមន្ទីរស-២១អាចយកមកប្រើប្រាស់ដោយមជ្ឈិមបក្សដើម្បីវាស់ស្ទង់«បរិយាកាសនយោបាយ»របស់ប្រជាជនក្នុងគោលបំណងបង្ការកុំឲ្យមានការប្រឆាំងនឹងខ្លួន និងដើម្បីកសាងអ្នកដែលមិនទាន់ចាប់ដាក់គុកតាមមាគ៌ាបដិវត្តន៍ត្រឹមត្រូវ ។ ការប្រមូលប្រវត្តិរូបម្នាក់ៗដើម្បី«ដឹង»អំពីប្រជាជនគ្រប់ៗរូបនៅក្នុងប្រទេស គឺចូលនៅក្នុងគ្រោងការនេះហើយ ។ម្យ៉ាងវិញទៀតកម្ពុជាប្រជាធិបតេយ្យហាក់ដូចជាជាប់ក្នុងគំនិតមួយថាការប្រមូលព័ត៌មានពីខាងក្នុងខ្លួនបានបង្កើនសមត្ថភាពរបស់ខ្លួនក្នុងការជះឥទ្ធិពលទៅលើព្រឹត្តការណ៍នានា ។ ជាអកុសលសម្រាប់របបនេះ ប៉ុន្តែជាការល្អទៅវិញសម្រាប់អ្នកដែលមានឱកាសបានរស់រានមានជីវិតជាច្រើនព្រោះថាព័ត៌មានដែលប្រមូលបានតាមអំណាចប្រើប្រាស់តាមចិត្តរបស់របបកម្ពុជាប្រជាធិបតេយ្យភាគច្រើនមានលក្ខណៈមិនពេញលេញ ឬពិតប្រាកដទេ ហើយ«ខ្មាំង»រាប់សែននាក់មិនដែលត្រូវបានរកឃើញឡើយ ។

ប្រសិនបើយើងសន្មតថាចម្លើយសារភាពនៅមន្ទីរស-២១«ពិត» នោះគ្រាន់តែអានតែបន្តិចប៉ុណ្ណោះក៏អាចយល់បានថាថ្នាក់ដឹកនាំបក្សដែលមានគំនិតខ្មៅងងឹត មានការសមគំនិតធ្វើអំពើទុច្ចរិតនិងក្បត់ បានសម្តែងចេញនូវភាពល្ងង់ខ្លៅដូចជាកូនក្មេង ទុកចិត្តលើមនុស្សខុស និងនាំឲ្យយល់ខុសអំពីអាទិភាពនិងបំណងរបស់ប្រជាជន ។ ម្យ៉ាងវិញទៀត នេះគឺជាមាគ៌ាដែល ប៉ុល ពត ប្រកាន់យកដោយមានការរអ៊ូបន្តិចបន្តួចក្រោយឆ្នាំ១៩៧៩ នៅក្នុងពេលនិយាយអំពីសម័យកាន់អំណាចរបស់ខ្លួន ។ ប៉ុល ពត បានប្រាប់កូនចៅរបស់ខ្លួនមួយចំនួនកាលពីឆ្នាំ១៩៨១ថាអ្វីដែលខុសនោះគឺថា ប៉ុល ពត ខ្លួនឯងបាន«ទុកចិត្តមនុស្សខ្លាំងជ្រុលពេក» ។ នៅក្នុងឆ្នាំ១៩៩៥ ប៉ុល ពត និយាយថាការស្លាប់ដែលកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺដោយសារ«យើងជាកូនក្មេងដែលទើបតែចេះដើរតេះតះ» ។ ការចៀសពីការទទួលខុសត្រូវរបស់ ប៉ុល ពត គឺងាយយល់ណាស់ ហើយការសោកស្តាយរបស់ ប៉ុល ពត ក៏មិនពិបាកយល់ដែរ ។ ប៉ុន្តែកាលនោះកម្ពុជាប្រជាធិបតេយ្យមិនមែនជាក្មេងដូច ប៉ុល ពត ប្រៀបធៀបនោះទេ ពីព្រោះបើក្មេងមែន តើធ្វើដូចម្តេចទើបអាចដើរត្រាច់ចរមើលទិដ្ឋភាពប្រទេសកម្ពុជាទាំងមូលដោយ

បង្កឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរបាន ។

ចម្លើយសារភាពដែលត្រូវបានស្រង់ចេញមកមិនមែនចង់បង្ហាញនូវភាពស្មោះត្រង់របស់មជ្ឈិមបក្សទេ ប៉ុន្តែជាភស្តុតាងនៃការដឹងព្រួរបស់បក្សកុម្មុយនិស្តកម្ពុជាទៅលើអ្វីៗគ្រប់យ៉ាងដែលចេះតែបន្តកើតមានឡើងតែប្រមូលបានដោយយឺតៗនិងលទ្ធភាពឥតខ្ចោះរបស់ថ្នាក់ដឹកនាំក្នុងការក្តាប់កង់ប្រវត្តិសាស្ត្រ ដើម្បីបង្កើតនិងគ្រប់គ្រងការរៀបរាប់ជាដំណើររឿងអំពីជ័យជម្នះរបស់បក្ស ។ ដូចគ្នាទៅនឹងរឿងរ៉ាវ“ជាតិ” និងបុគ្គលជាច្រើនដែលបានធ្វើដំណើរជាមួយគ្នាចូលក្នុងការរៀបរាប់ដែលមានការគ្រប់គ្រងនៃជ័យជម្នះរបស់បក្សកុម្មុយនិស្តកម្ពុជាទៅលើអ្វីដែលហៅថា“អាមេរិក”នៅខែមេសាឆ្នាំ១៩៧៥នោះ “សកម្មភាពក្បត់” “ផែនការ” និង“ខ្សែក្បត់”ដែលកំពុងតែលាតត្រដាង ក៏ត្រូវបានទាញចូលទៅក្នុងប្រវត្តិនោះដែរ ហើយ“ខ្មាំង”ត្រូវបានធ្វើឲ្យអស់លទ្ធភាពមុនពេលសកម្មភាពក្បត់ ឬ“ផែនការ” របស់ខ្លួនចាប់ដំណើរការ ។ ក្រោមការយល់ឃើញតាមរបៀបនេះ ចម្លើយសារភាព គឺជាមន្តអាគមដែលមិនត្រឹមតែការពារមជ្ឈិមបក្សមិនឲ្យមានខ្មាំងរបស់ខ្លួនទេ ប៉ុន្តែថែមទាំងការពារមិនឲ្យមានអ្នកណាយល់ពីអ្វីដែលកំពុងតែកើតឡើងទៀតផង ។ ឌុច, ប៉ុន, ច័ន្ទ, និងអ្នកធ្វើការជាមួយខ្លួន គឺជាបព្វជិត ជាគ្រូពេទ្យ ជាកម្មករអណ្តូងរ៉ែ អ្នកវះកាត់សត្វ និងអ្នកប្រវត្តិសាស្ត្រ ។ នៅក្នុងការប្រឌិតប្រវត្តិសាស្ត្រតាមគំនិតរវើរវាយរបស់ថ្នាក់ដឹកនាំខ្លួនដែលប្រហែលជាតាមគំនិតរបស់ខ្លួនដែរនោះ អ្នកទាំងនោះបានបម្រើចៅហ្វាយរបស់ខ្លួនបានយ៉ាងពេញចិត្ត ។

(នៅមានត)

# មូលហេតុនៃការធ្វើអត្តឃាតរបស់អ្នកទោសឈ្មោះកង

នៅពេលដែលអង្គការចោទប្រកាន់ជនណាម្នាក់ថា «ក្បត់» គឺភាគច្រើនត្រូវបានបញ្ជូនមកដាក់នៅក្នុងមន្ទីរស-២១ ។ ចំពោះអ្នកទោសទាំងនេះគឺកម្រនឹងមានឱកាសរួចផុតពីការសួរចម្លើយ ការធ្វើទារុណកម្មនិងការកាប់សម្លាប់ពីសំណាក់យុទ្ធជនសួរចម្លើយនៃមន្ទីរស-២១ ដោយហេតុថាវិន័យនៅក្នុងមន្ទីរនេះមានលក្ខណៈតឹងតែងជាទីបំផុត ។ បញ្ជាដែលបានដាក់ចុះពីអង្គការត្រូវតែអនុវត្តឲ្យបាន១០០ភាគរយ ។ អ្នកទោសជាង១ម៉ឺននាក់នៅមន្ទីរស-២១បានស្លាប់ក្រោមការធ្វើទារុណកម្ម បង្អត់អាហារ ជំងឺ និងការយកទៅសម្លាប់ចោល ។ អ្នកទោសមួយចំនួនតូចស្លាប់ដោយការធ្វើអត្តឃាត ។ អ្នកទោសម្នាក់ឈ្មោះកង បានធ្វើអត្តឃាតដោយសារតែមិនអាចស៊ូទ្រាំនឹងការធ្វើទារុណកម្មពីសំណាក់កម្មាភិបាលនៅមន្ទីរស-២១ ។

វិន័យសន្តិបាលនៃមន្ទីរស-២១បានដាក់ចុះចំនួន៩ចំណុចថាៈ ១)សួរអីឆ្លើយហ្នឹង មិនបង្វែរសំណួររបស់អញ ។ ២)មិនឲ្យដោះស្រាយ យកលេសនេះ លេសនោះ តាមគំនិតឯងលាក់ ឬប្រកែកតមាត់ដាច់ខាត ។ ៣)មិនឲ្យធ្វើល្ងង់ មិនយល់បញ្ហា ព្រោះឯងជាមនុស្សហ៊ានប្រឆាំងប.វ(បដិវត្តន៍) ។ ៤)សួរភ្លាមឆ្លើយភ្លាម មិនឲ្យដំអក់មួយនាទីឡើយ ។ ៥)រឿងខុះខាតកុហកបន្តិចបន្តួច ខូចសីលធម៌ ខូចនេះ ខូចនោះ ក៏មិនឲ្យនិយាយរឿងខ្លឹមសារប.វ ក៏មិនឲ្យនិយាយ ។ ៦)រំពាត់ ឆក់ខ្សែភ្លើង មិនឲ្យស្រែកៗដាច់ខាត ។ ៧)មិនឲ្យធ្វើអីទាំងអស់ គឺអង្គុយស្ងៀមរង់ចាំអញបញ្ជា អត់បញ្ជាកុំធ្វើ អញបញ្ជាអីធ្វើហ្នឹងភ្លាម ប្រកែកប្រិមប្រិមមិនបានទេ ។ ៨)កុំយកលេសកម្ពុជាក្រោមបាំងមុខមាត់ក្បត់ប.វរបស់អាឯងឲ្យសោះ ។ និង៩)គ្រប់បញ្ហាខាងលើមិនធ្វើតាម គឺមួយថ្ងៃៗរងរំពាត់ ខ្សែភ្លើងឆក់រាប់មិនឈ្នះទេ ។ ប្រឆាំងចំណុចអញមួយចំណុចត្រូវរងរំពាត់១០រំពាត់ ឬឆក់ខ្សែភ្លើង៥ឆាប់ ។

ម្យ៉ាងទៀត ឯកសារសារាចរមួយរបស់មន្ទីរស-២១ ក៏បានសរសេរថា ស្មើមិត្តទាំងអស់អនុវត្តតាមសារាចរនេះឲ្យបានដាច់ខាត ។ សារាចរនេះបានចែងជាបីចំណុច÷

ទី១)អំពីវិន័យការពារខ្មាំងដោយបញ្ជាក់ថា ពេលយាមមិនឲ្យអង្គុយ ឬផ្អែក និងមិនឲ្យសរសេរអ្វីទាំងអស់ត្រូវដើរចុះឡើង ។ ពេលយាមមិនឲ្យសួរឈ្មោះខ្មាំងដាច់ខាតនៅក្នុងបន្ទប់ ឬក្នុងផ្ទះ ។ ពេលយាម មិត្តណាមានភារកិច្ចយាមមិនឲ្យដើរចោលកន្លែងយាម ពេលយាមមិនឲ្យមិត្តណាគ្មានភារកិច្ចយាមហាមចូលលុកលុយ បើកទ្វារ ឬបង្អួចមើលអ្នកទោសដាច់ខាត ។

ចំពោះអ្នកទោសដែលជាប់នៅក្នុងមន្ទីរឃុំឃាំង បើទោះជាស្គាល់ ឬមិនស្គាល់ មិនឲ្យសាកសួរដាច់ខាត ។ ចំពោះខ្មាំងដែលជាប់ នៅកន្លែងយើងមិនអនុញ្ញាតឲ្យសម្លុត ឬវាយដាដាច់ខាត បើ ខ្មាំងសេរី អ្នកយាមនិយាយមិនស្តាប់ ស្នើរាយការណ៍ជាបន្ទាន់ ឲ្យអ្នកទទួលខុសត្រូវជាផ្ទាល់ ឬជាក្រដាស ។ បើខ្មាំងមានសកម្ម-ភាព វាយសោ ឬចាក់សោ ចងក អារដៃ អារក បម្រុងនឹង លេបខ្មៅ ត្រូវមានវិធានការជាបន្ទាន់ ដាក់ខ្នោះដៃមកក្រោយ ហើយរាយការណ៍ឲ្យអ្នកទទួលខុសត្រូវ កុំចាំទុកយូរ ។ ពេលខ្មាំង រត់រួច ត្រូវរាយការណ៍ជាបន្ទាន់ ត្រូវចាត់កម្លាំងតាមចាប់ភ្លាម កុំនិយាយរឿងអត់កម្លាំង ។ ពេលយាមល្បាតការពារ កម្មាភិ-បាល ក្រុម កងហាត្រូវមានមុខនៅកន្លែងយាមតាមមុខសញ្ញា របស់ខ្លួន តាមមុខសញ្ញាដែលបក្សប្រគល់ឲ្យទទួលខុសត្រូវ ។ ពេលយាម កម្មាភិបាលមិនឲ្យលួចដេក ឬអង្គុយផ្អែក ត្រូវដើរ ត្រួតពិនិត្យឲ្យជាប់ជាប្រចាំ ។ ពេលយាម កម្មាភិបាលនិងយុទ្ធជន ត្រូវឆែកឆេរគ្រប់ពេលវេលាតាមកាលកំណត់ដាច់ខាត គឺ២៤ ម៉ោងឆែក៤ដងជាកំហិត ។ គឺព្រឹកម៉ោង៦ម្តង ម៉ោង១១ថ្ងៃ ត្រង់ម្តង ល្ងាចម៉ោង៦ម្តង និងយប់ម៉ោង១១ម្តងទៀត ។ ពេលឆែកឆេរដោះខោអាវវា ហើយត្រូវឲ្យវាស្លៀកពាក់វិញ ចាំអ្នកឆែកឆេរចេញពីបន្ទប់ ។ ចំពោះខោអាវខ្មាំងត្រូវឲ្យវា ស្លៀកពាក់ទាំងអស់ មិនឲ្យដោះចេញពីខ្លួនឡើយ បើវាដោះចេញ គ្មានការអនុញ្ញាត ត្រូវដកលែងឲ្យស្លៀកពាក់ ។ ពេលល្បាត កម្មាភិបាលត្រូវកាន់កូនសោដោយខ្លួនឯង មិនឲ្យបណ្តែតបណ្តោយ តាមចិត្ត ខ្លួនខ្ជិល ។ ដាច់ខាតមិនឲ្យបាត់កូនសោ បើបាត់កូនសោ មិនត្រូវអាវមេសោត្រូវរកកូនឲ្យឃើញ ។ អ្នករត់រួចកន្លែងបាត់ សោត្រូវទទួលខុសត្រូវចំពោះសមូហភាព ។ ពេលយាមត្រូវ ស្លៀកពាក់ជាឯកសណ្ឋានយោធា មិនអនុញ្ញាតឲ្យស្លៀកខោខ្លី ឬដោះអាវ ។

ទី២) អំពីសោខ្នោះក៏បានបញ្ជាក់ច្បាស់ថា ចាក់សោខ្មាំង ត្រូវពិនិត្យសោ កង រនងឲ្យបានល្អិត ទើបដោះខ្នោះដៃ ស្រាយ មុខ ។ ពេលចាក់សោខ្មាំង កង រនង ត្រូវយកចេញពីក្នុងបន្ទប់ មកទុកខាងក្រៅ មិនត្រូវឲ្យទុកខាងក្នុងទេ ។ ចាក់សោខ្មាំង យក មកចាក់អាចម៍ ត្រូវដាក់ច្រវាក់ដៃម្ខាងនិងជើងម្ខាងទៀត ហើយ មិនត្រូវដើរឆ្ងាយពីខ្មាំងទេ ។ ខ្មាំងដែលយកមកពីកន្លែងសួរ ចម្លើយវិញត្រូវឆែកឆេរខ្លួនឲ្យបានហ្មត់ចត់និងនៅពេលប្តូរយាម ទាំងកង ទាំងរនង ។ ច្រវាក់ត្រូវចាក់ឲ្យខ្លី យ៉ាងវែងកន្លះម៉ែត្រ បើករណីពិសេសត្រូវខាងលើសម្រេច ។

ទី៣) អំពីវិធានការបានលើកឡើងថា ខ្មាំងនៅតាមផ្ទះ មិន ឲ្យវាទាក់ទងគ្នាបានទេ ។ ខ្មាំងដែលនៅកន្លែងយើង គឺដាច់ខាត មិនឲ្យវានិយាយគ្នា ។ ចំពោះអ្នកដែលមានភារកិច្ចខាងក្នុង គឺ ដាច់ខាតមិនអនុញ្ញាតឲ្យដើរចេញមកក្រៅទេ ប្រយ័ត្នខ្មាំងវា ទាក់ទងគ្នាបាន ឬខ្មាំងវាមានប្រតិកម្មផ្សេងៗ ។ នៅតាមផ្ទះ នីមួយៗត្រូវមានបញ្ជីឈ្មោះខ្មាំង និងលេខបន្ទប់ ។ ចំពោះអាវុធ ពេលយាមត្រូវដោះគ្រាប់ចេញពីបង់ ដែលជាប់អាវុធ តែចំពោះ បង់ដែលជាប់នឹងកាសេតត្រូវមានគ្រាប់ពេញ ។ យាមជាប់ជាមួយ ខ្មាំងខាងក្នុងមិនឲ្យកាន់អាវុធ អនុញ្ញាតឲ្យកាន់ដំបង ។ អាវុធត្រូវ មានអ្នកកាន់ច្បាស់លាស់ មិនត្រូវទុកអាវុធចោល ត្រូវកាន់ជាប់ នឹងខ្លួន មិនត្រូវទុកអាវុធនៅក្បែរខ្មាំង ឬស្ពាយអាវុធទៅឈរ ជិតខ្មាំង ។ ប្តូរយាមត្រូវប្រគល់ភារកិច្ចច្បាស់លាស់ និងរាយ ការណ៍ពីស្ថានការណ៍អ្នកទោស និងស្ថានការណ៍ផ្សេងៗទៀតឲ្យ ទៅអ្នកយាមថ្មី ។ ពេលប្តូរវេនយាម ទើបអនុញ្ញាតឲ្យយកធុង អាចម៍និងធុងនោម និងឆែកឆេរ ភារកិច្ចនេះ អ្នកប្តូរវេនយាម បំពេញ ហើយអ្នកយាមចាស់មិនទាន់ឲ្យទៅណាទេ ទាល់តែអ្នកប្តូរ យាមបំពេញ ហើយអ្នកយាមបំពេញភារកិច្ចខ្លួនជាដំបូងនេះ ហើយ ។

ឯកសារមួយទៀតស្តីអំពីផែនការរបស់បក្ស ផ្ញើនៅថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៧៦ ។ ផែនការនោះបានលើកឡើងអំពីការ បែងចែកពេលម៉ោងយាមអ្នកទោសដោយបញ្ជាក់ថា“ក្នុងមួយផ្ទះ ពេលយប់យាម៩នាក់ ៣នាក់យាមខាងលើ ៣នាក់ទៀតយាម ខាងក្រោម ហើយនៅខាងក្នុងអត់កាន់អាវុធទេ ត្រូវកាន់ដំបង ៣នាក់ទៀតយាមខាងក្រោមដែរ ។ យាមពេលថ្ងៃក្នុងមួយ ជាន់២នាក់ ពីរជាន់៤នាក់ ។ ១) ម៉ោង៦ៈ៣០នាទីដល់ម៉ោង ៧ៈ៣០នាទី ២) ម៉ោង១០ៈ៣០នាទីដល់ម៉ោង១១ៈ៣០នាទី ៣) ម៉ោង១ៈ៣០នាទីដល់ម៉ោង២ៈ៣០នាទី ៤) ម៉ោង៤ៈ៣០ នាទីដល់ម៉ោង៥ៈ៣០នាទី ៥) ម៉ោង៦ៈ៣០នាទីដល់ម៉ោង




៧:៣០នាទី ៦) ម៉ោង១០:៣០នាទី ដល់ម៉ោង១១:៣០នាទី ។ ត្រូវមានអ្នកប្រចាំការពេលម៉ោងនេះជារៀងរាល់ថ្ងៃ ក្នុងមួយផ្ទះ៤នាក់ ក្នុងមួយជាន់២នាក់ ។ ក្រោយពេលនេះធ្វើការងារពលកម្ម ហើយនៅសល់កងរយមួយ និងមិត្តយើង៣នាក់ទៀត ។ វិធានការថ្ងៃទី២ ខែសីហា ឆ្នាំ១៩៧៦ ។ អ្នកសួរចម្លើយពេលមកយកខ្មាំង មិនឲ្យចូលទៅក្នុង ហើយមិនឲ្យបើកបង្អួចមើលខ្មាំង» ។

មិនតែប៉ុណ្ណោះទៀតសោត ទាក់ទងទៅនឹងការធ្វើអត្តឃាតរបស់អ្នកទោសឈ្មោះ កង មានឯកសារមួយទៀតដែលធ្វើនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៧៦ និងមានចុះហត្ថលេខាដោយសមមិត្តឌុច ដែលបានសរសេរអំពីបញ្ហាខ្មាំងយកអាវុធបាន ហើយបាញ់សម្លាប់ខ្លួនឯង ។ ក្នុងឯកសារនេះបានបង្ហាញថា «អគ្គភាពដែលយាមនេះជាអគ្គភាពថ្មីរបស់កងសម្ងាត់ ។ អគ្គភាពចាស់ជាប់រៀនសូត្រ ។ កាំភ្លើងខ្លីដែលប្រចាំការនៅកន្លែងនោះមាន៣ដើម ។ មិត្ត លី ស្រ៊ាង ទទួលកាំភ្លើងពីអនុសេនាតូចមកប្រគល់ប៉េអាកុលមួយដើមឲ្យមិត្តគុន មួយដើមឲ្យមិត្តរី ។ នៅសល់ស្មីតមួយដើមទុកក្នុងទូ ប្រគល់ឲ្យមិត្តណាក៏អត់ គ្រាន់តែប្រាប់មិត្តណុប ណាត ឲ្យដឹង ឲ្យឃើញ ។ ពេលប្រាប់ មិត្តណុប ណាត នេះ អាចអាកង វាឃើញដែរ ។ ម៉ោង១២ ខ្វះ១០ ភាគច្រើនទៅហូបបាយមិនទាន់មកវិញ ។ មិត្ត ណុប ណាត ប្រចាំការកន្លែង អាកង មិត្ត យ៉ាន់ប្រចាំការជាប់គ្នា កន្លែង កែវ មន្នី គឺជាជាន់ជាប់ដីនៃផ្ទះដែលដាក់មនុស្សសំខាន់ៗ ។ ពេលនោះ ណុប ណាត យកកន្ទោរលាមកទៅចាក់ ក៏មិនបានផ្តាំជាមួយ មួង យ៉ាន ។ ឮក្តុងក្តាំងក្បែរ មួង យ៉ាន រត់ទៅមើលឃើញអាកង វាយកកាំភ្លើងបាន ហើយរត់ទៅរាយការណ៍បណ្តោយ» ។

ការខ្វះខាតការដឹកនាំពិសោធន៍ក្នុងការការពារកន្លងមកបង្ហាញថា «ភាគច្រើន គឺពីលើចុះក្រោម គឺទាំងស្រុងពីលើចុះក្រោមហើយមិនបានសរុបពិសោធន៍ជាបច្ចេកទេសឲ្យជ្រៅជ្រះ និងមិនបានសរុបពិសោធន៍ជារបៀបរបបធ្វើការងារ គឺពង្រឹងជំហរបំពេញភារកិច្ចរបស់យុទ្ធជន ប្រធានពួក ប្រធានក្រុម អនុសេនាតូច ។ ការខ្វះខាតជាការអនុវត្តលាក់ការណ៍ គឺមានកាំភ្លើងដែលគ្មានមនុស្សជាអ្នកទទួលខុសត្រូវ កន្លែងទុកដាក់កាំភ្លើងមិនសម្ងាត់ ដើរចោលកាំភ្លើង ដើរចោលអ្នកទោសពេលផ្លាស់ប្តូរយាមមិនប្រគល់ភារកិច្ចឲ្យច្បាស់ ។ ការខ្វះខាតគោលជំហរចំពោះខ្មាំង គឺចាក់សោក៏សន្តិភាព ប្រវាក់វែងថែមខ្នោះនិងរនុងខ្នោះទៀត ល្មមដល់ទូកាំភ្លើង អ្នកសួរដែលចុះឡើងឃើញខ្លះៗ ក៏មិនបានជួយមតិ ឬលើកសំណូមពរ» ។

ការចាប់អារម្មណ៍របស់គណៈដឹកនាំពិសោធ(ណាត ឌុច និង ហ៊ី)

“ចំពោះមិត្ត លី ស្រ៊ាង ដែលមិនប្រគល់កាំភ្លើងមួយដើមនេះឲ្យនរណាកាន់ឲ្យច្បាស់លាស់ តុដិតដៃខ្លាំង ហើយខ្ញុំអាចឃើញ” ។

លទ្ធផលនៃការតាមដានល្អិតកន្លែងកើតហេតុ គឺថា“កាំភ្លើងបាញ់តែបីគ្រាប់គត់ កាំភ្លើងដែលប្រើប្រាស់នៅពេលបាញ់នេះ ពិនិត្យទាំងអស់ឃើញថាពិតជាកាំភ្លើងតែមួយគឺស្មឹត ។ ប្រវាក់និងខ្នោះ តាមការចូលសាក ឃើញថាពិតជាចូលដល់ទូកាំភ្លើងដោយស្រួល ហើយដើរមកបានរហ័សដែរ ល្មមតែមិត្ត ណុប ណាត គាត់ចេញទៅចាក់កន្ថោរ វាមកដល់ទូភ្លាម ។ អាកង ដែលស្លាប់នេះត្រូវតែមួយគ្រាប់គត់ដែលវាបាញ់(ដោយបៀមកាណុងធុះពីក្បែរកន្ទើតទៅធ្លាយក្បាលឆៀងខាងឆ្វេងបន្តិច) ។ អំពីគ្រាប់កាំភ្លើងពីរគ្រាប់ទៀត មួយគ្រាប់បាញ់ពីក្រៅ បាញ់ជិតទ្វាររំសេវនៅខ្មៅៗនៅឡើយ ។ ធុះទ្វារពីក្រៅទៅក្នុងត្រង់តំណស្លាបព្រិលនិងមេទ្វារធ្លាយទៅប៉ះជញ្ជាំងខាងក្នុង គ្រាប់ផ្លាតទៅទៀត ។ មួយគ្រាប់ទៀតក៏បាញ់ចេញពីក្រៅដែរ កន្លែងបាញ់មិនច្បាស់ជាត្រង់ណាពិតប្រាកដ គ្មានដាន ឃើញតែធុះខ្ទង់ទូដែលធ្វើអំពីក្តារបន្ទះ ។ សរុបមកបាញ់ពីក្រៅធុះចូលក្នុងផ្ទះ ។ អាកង វាបាញ់ ព្រោះដាក់ស្តែងឃើញទាំងអស់គ្នាថា កាំភ្លើងដែលបាញ់មានតែមួយដើមទេ បាញ់តែបីគ្រាប់ទេ វាត្រូវតែមួយគ្រាប់ទេ ។ វាចង់ឲ្យយើងច្របូកច្របល់ វាយគ្នាឯង ។ អាកង វាបាញ់មិត្ត ណាត ដែលដើរទៅក្រោយផ្ទះ យកកន្ថោរទៅចាក់ ។ បរាជ័យនេះ ទោះបីមានខ្លាំងបង្កប់ ឬអត់ក្នុងជួរយុទ្ធជនអស់នេះ វាផ្ទុះទៅបានដោយគន្លឹះសំខាន់មួយគួរឲ្យឈឺចាប់ គឺគណៈស-២១ មិនទាន់មានសាមគ្គីភាព ឯកភាព រឹងប៉ឹង ។ សូមប្តេជ្ញាដោះស្រាយបញ្ហានេះឲ្យបានជាបន្តបន្ទាប់” ។

អ្នកទោសដែលត្រូវបានអង្គការចោទប្រកាន់ថា “ក្បត់បដិវត្តន៍” ហើយធ្វើអត្តឃាតមិនដឹងពិតប្រាកដថាមានចំនួនប៉ុន្មាននាក់ឡើយ ។ ការស្លាប់ដោយសារការធ្វើអត្តឃាតរបស់អ្នកទោសអាចមានចំនួនតិចតួចប៉ុណ្ណោះ ពីព្រោះថាវិន័យរបស់មន្ទីរឃុំឃាំងនេះ ក៏មានវិធានការទប់ស្កាត់ចំពោះអ្នកទោសដែលមានបំណងធ្វើអត្តឃាតដែរ ។ ទោះជាយ៉ាងនេះក្តី ក្រៅពីករណីនៃការធ្វើអត្តឃាតរបស់អ្នកទោសឈ្មោះ កង ក៏នៅមានករណីអ្នកទោសខ្លះៗទៀតបានធ្វើអត្តឃាតតាមបែបផ្សេងទៀត ដូចដែលត្រូវបង្ហាញតាមរយៈរូបថតក្នុងអត្ថបទទាំងនេះ ។

**ឌួង សុភារិទ្ធ**

អត្តឃាតនៅមន្ទីរស-២១



# ខ្មែរក្រហមពិតជាបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍មែន

សាស្ត្រាចារ្យ វីលៀមស្កាបាស់ បានអះអាងខុសថា ខ្មែរក្រហមមិនបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដូចដែលមានចែងនៅក្នុងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ទេ ។ មិនតែប៉ុណ្ណោះ លោក ក៏នៅអះអាងខុសត្រង់ចំណុចនៃពេលវេលាដែលឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិបានក្លាយជាច្បាប់អន្តរជាតិដោយរួមបញ្ចូលទាំងឃាតកម្មទ្រង់ទ្រាយធំកើតឡើងក្នុងស្រុកផង ។

ទាក់ទងនឹងអំពើមនុស្សឃាតជាទ្រង់ទ្រាយធំដែលធ្វើឡើងដោយខ្មែរក្រហមមកលើជនជាតិចាមដែលជាជនជាតិភាគតិច ខ្មែរក្រហមមិនមែនត្រឹមតែឲ្យមករស់នៅដូចៗគ្នាដូចស្កាបាស់បានលើកឡើងនោះទេ ។ លោកច្បាស់ជាវិភាគអង្គហេតុខុសហើយ ។ ការសិក្សាស្រាវជ្រាវរបស់ប្រវត្តិវិទូ ប៉ែន យៀនិន និងខ្ញុំផ្ទាល់ព្រមទាំងកម្មវិធីសិក្សាស្រាវជ្រាវពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា នៅក្នុងភូមិចាមមួយចំនួនបង្ហាញថា អត្រាស្លាប់នៃជនជាតិចាមមានរហូតដល់ជាង៥០ភាគរយ ពោលគឺលើសពីការស្លាប់របស់ជនជាតិភាគច្រើនក្នុងស្រុកពីរដង ។ នៅមានឧទាហរណ៍ជាក់ស្តែងមួយចំនួនទៀតទាក់ទងនឹងមនុស្សឃាតក្នុងទ្រង់ទ្រាយធំមកលើភូមិចាម ។ នៅថ្ងៃមួយក្នុងឆ្នាំ១៩៧៧មានប្រជាជនចាមជាង៥ពាន់នាក់ត្រូវបានសម្លាប់ហើយទម្លាក់ចោលទៅក្នុងជ្រោះជ្រៅនៅខេត្តកំពង់ចាម ។ សាក្សីដែលនៅរស់ដល់សព្វថ្ងៃក៏បានបញ្ជាក់ប្រាប់យើងសង្ខេបៗអំពីជនជាតិចាមនៅក្នុងតំបន់ដែលគាត់រស់នៅដោយបាននិយាយពីការសម្លាប់មនុស្សជាទ្រង់ទ្រាយធំបូករួមទាំងអំពើឃោរឃៅផ្តុតជនរងគ្រោះទាំងរស់ទៀតផង ។ ក្រៅពីនេះ ភ័ស្តុតាងបង្ហាញពីលទ្ធផលដែលចេញពីការប្រព្រឹត្តមនុស្សឃាតជាប្រព័ន្ធដែលជាតឹកតាងដ៏មានទម្ងន់សម្រាប់បង្ហាញថា មានចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ហើយក៏នៅមានភស្តុតាងបង្ហាញថាការបំផ្លិចបំផ្លាញជនជាតិចាម គឺជានយោបាយជាផ្លូវការរបស់គណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនិស្តកម្ពុជាក្នុងនោះមានបញ្ញត្តិច្បាស់ក្រឡែតមួយសរសេរថា "ត្រូវបំបែកចាមកុំឲ្យរស់នៅផ្តុំគ្នានៅក្នុងប្រទេសកម្ពុជា" ។

លោក គ្រេក អិចឆេសាន់ បានកត់សម្គាល់រួចមកហើយនូវភ័ស្តុតាងដែលមានទម្ងន់ដែលថាខ្មែរក្រហមក៏បានប្រព្រឹត្តអំពើប្រល័យពូជសាសន៍មកលើជនជាតិភាគតិចវៀតណាមដែរ ។ ការអះអាងរបស់លោក ស៊ីវ ហេដឌ័រ ដែលថាជនជាតិវៀតណាមទាំងអស់សុទ្ធតែជា"ជនបរទេស" គឺមិនមានអ្វីទាក់ទងក្រោមអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ទេ ។ បើទោះបីជាជនជាតិវៀតណាមទាំងអស់ជាជនបរទេសយ៉ាងណាក៏ដោយ ប៉ុន្តែជនជាតិវៀតណាមទាំងនេះ គឺជាក្រុមជាតិសាសន៍មួយក្រុម ហើយការបំផ្លាញក្រុមនេះនឹងក្លាយជាអំពើប្រល័យពូជសាសន៍ហើយ ។

ការអះអាងរបស់ ហាន ណាំ ដែលថាការកម្ទេចប្រជាជននៅភូមិភាគបូព៌ានៃប្រទេសកម្ពុជាក៏ជាអំពើប្រល័យពូជសាសន៍ដែរ ដោយសារការបំផ្លាញដោយផ្នែកនៃក្រុមជនជាតិ(កម្ពុជា)នោះប្រហែលជាពង្រីកដែនសមត្ថកិច្ចរបស់អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍កាន់តែធំ ពីព្រោះនេះជាការសម្លាប់ដែលធ្វើឡើងដោយជនជាតិខ្មែរនៅតំបន់មួយមកលើជនជាតិខ្មែរនៅតំបន់មួយទៀត ។ ការសម្លាប់ប្រជាជននៅភូមិភាគបូព៌ាជាទ្រង់ទ្រាយធំ គឺធ្វើឡើងដោយនយោបាយរបស់គណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនិស្តកម្ពុជា ។ ការសម្លាប់នេះត្រូវបានធ្វើឡើងជាប្រព័ន្ធ ហើយសមាជិកនៃក្រុមជនរងគ្រោះត្រូវខ្មែរក្រហមដាក់តម្រុយសម្គាល់ដោយឲ្យប្រើក្រមាក្រឡាចត្រង្គខៀវលាយស ។ នេះជាតម្រុយដែល ប៉ែន យៀវនិន និងខ្ញុំរកឃើញនៅឆ្នាំ(១៩៨៦) នៅពេលដែលក្រុមជនរងគ្រោះទាំងនេះដើរកាត់ទីក្រុងភ្នំពេញក្នុងពេលជម្លៀសចេញពីភូមិភាគបូព៌ា ។ លោក ស្កាបាស់ យល់ខុសដែលលោកបដិសេធថា អំពើនេះមិនមែនជាអំពើប្រល័យពូជសាសន៍ដោយលោកអះអាងថា ជាករណីខ្មែរសម្លាប់ខ្មែរ ។ បើដូច្នេះ តម្រូវឲ្យលោក ស្កាបាស់ សម្រេចឲ្យច្បាស់លាស់ថា

ដើម្បីឲ្យក្លាយជាជនជាតិ ឬជាតិពន្ធមួយក្រុមត្រូវមានលក្ខខណ្ឌអ្វីខ្លះដោយមិនចាំបាច់គិតពីគំនិតផ្នែកជាតិពន្ធវិទ្យារបស់កម្ពុជា ដូចដែលខ្មែរក្រហមបានកំណត់នោះទេ ។ ខ្មែរក្រហមបានចាត់ទុកប្រជាជនភូមិភាគបូព៌ាថាជាជាតិពន្ធ ផ្សេងពីប្រជាជនកម្ពុជាដទៃទៀតដោយហៅថា«ក្បាលយួនខ្លួនខ្មែរ» ។ ការឲ្យនិយមន័យរបស់ជនដែលដល់ទៅលើពាក្យជាតិពន្ធ ឬជាតិសាសន៍គឺជាលក្ខណៈពិសេសនៃអំពើប្រល័យពូជសាសន៍ ។ អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍មិនបានបដិសេធវិធីនេះទេ ហើយក៏មិននិយាយថាអ្នកសិក្សាជាន់ខ្ពស់ផ្នែកច្បាប់ជនជាតិបរទេសគួរតែកំណត់ឲ្យច្បាស់ថា អ្វីដែលហៅថា ក្រុមជាតិពន្ធ ឬជនជាតិដែរ ។ ទុកបញ្ហានេះឲ្យតុលាការជម្រះក្តីអំពីប្រល័យពូជសាសន៍ជាអ្នកសម្រេចទៅចុះ ។ ហេតុផលនេះបញ្ជាក់ថា លោក វ៉ាត់ន័រ និងលោក អាប្រាហាម យល់ត្រឹមត្រូវនៅក្នុងរបាយការណ៍របស់គណៈ-កម្មាធិការស៊ើបអង្កេតរឿងក្តីរបស់អង្គការសហប្រជាជាតិដែលមានប្រសាសន៍ថាទុកនាទីនេះឲ្យតុលាការជាអ្នកដោះស្រាយ ។ លោក ស្កាបាស់ ក៏យល់ខុសដែរ ដោយនិយាយថា «ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ»នៅតែតម្រូវឲ្យមានសម្ព័ន្ធជម្លោះប្រដាប់អាវុធអន្តរជាតិនៅត្រឹមឆ្នាំ១៩៧៩ ។ តុលាការនៅនូរិមប៊ឺក ហើយក្រោយមកទៀត សេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិដែលចែងពីគោលការណ៍របស់ខ្លួនបានកំណត់ច្បាស់អំពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ក៏ប៉ុន្តែនៅត្រឹមឆ្នាំ១៩៧៧ ពិធីសារទី២នៃអនុសញ្ញាទីក្រុងហ្សឺណែវបានពង្រីកដែនអនុវត្តន៍នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឲ្យមានរហូតដល់ករណីជម្លោះជាលក្ខណៈស៊ីវិលដែរ ហើយដើម្បីធ្វើយ៉ាងនេះ អ្នកបង្កើតគំនិតនេះអះអាងថាខ្លួនបាននិយាយបញ្ជាក់នូវច្បាប់ទម្លាប់ជាអន្តរជាតិសាជាថ្មី ។ ដូចនេះការប៉ុនប៉ងបដិសេធថា មិនមានអំពើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្នុងអំឡុងឆ្នាំ១៩៤៥ ដល់១៩៩៤ (ពេលដែលតម្រូវការសម្ព័ន្ធជម្លោះប្រដាប់អាវុធអន្តរជាតិលែងតម្រូវឲ្យមាននៅក្នុងលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិនៅប្រទេសរ៉្វាន់ដា) ឬសូម្បីតែមកដល់ឆ្នាំ១៩៩៨សន្និសញ្ញាតុលាការអន្តរជាតិនៅទីក្រុងរ៉ូម) ក៏មិនត្រឹមត្រូវតាមច្បាប់ដែរ ។ ឃាតកម្មក្នុងស្រុកក្នុងទ្រង់ទ្រាយធំនិងឧក្រិដ្ឋកម្មជាច្រើនផ្សេងទៀតដែលប្រព្រឹត្តឡើងដោយខ្មែរក្រហមបានចូលក្នុងបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចាប់តាំងពីនៅក្នុងរបបខ្លួនកាន់កាប់អំណាចមកម្ល៉េះ ។

ការប្រានចោលតាមរយៈការឲ្យនិយមន័យរបស់លោក វីលៀម ស្កាបាស់ ថាខ្មែរក្រហម និងកងទ័ពយូហ្គោស្លាវីនៅកូសូវ៉ូមិនបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ទេនោះពិតជាមានផលប៉ះពាល់យ៉ាងខ្លាំង ។ តាមពិតលោកស្កាបាស់មានបំណងល្អទេ ។ គាត់ចង់កម្រិតការប្រើពាក្យ«ប្រល័យពូជសាសន៍»ឲ្យបានច្បាស់ដើម្បីឲ្យរដ្ឋាភិបាលនានាអាចធ្វើការងារនេះក្នុងករណីមានអំពើប្រល័យពូជសាសន៍កើតឡើងមែន ។ ហើយលោកគិតថារដ្ឋាភិបាលទាំងឡាយមិនសូវជាចាត់ការញឹកញាប់ប៉ុន្មានទេ ។ ដូច្នេះមានន័យថាពាក្យ «ប្រល័យពូជសាសន៍» នេះត្រូវតែកំណត់ឲ្យបានជាក់លាក់បំផុត ។ គំនិតរបស់លោកស្កាបាស់ ចំពោះដំណើរការនយោបាយ គឺមិនល្អទេ ។ រដ្ឋាភិបាលនានានឹងមិនចាត់ការទេ ទោះបីជាអង្គហេតុមានគ្រប់គ្រាន់ដែលបង្ហាញថាអំពើទាំងនេះចូលជាបទប្រល័យពូជសាសន៍យ៉ាងណាក៏ដោយ ។ ការដកខ្លួនថយរបស់អង្គការសហប្រជាជាតិពីប្រទេសរ៉្វាន់ដានៅឆ្នាំ១៩៩៤ តាមការទទូចហើយទទូចទៀតរបស់អ្នកច្បាប់មកពីក្រសួងការបរទេសសហរដ្ឋអាមេរិកដែលបដិសេធថាមិនមានអំពើប្រល័យពូជសាសន៍នោះគឺជាករណីដ៏ជាក់ស្តែងមួយដែលមានការចាប់អារម្មណ៍យ៉ាងខ្លាំង ។ តាមការពិត នេះជាឧទាហរណ៍ដ៏ល្អមួយបង្ហាញធាតុពិតដែលថាតើនិយមន័យដែលលោក ស្កាបាស់ គាំទ្រមានលក្ខណៈយ៉ាងដូចម្តេចដែលអាចធ្វើឲ្យនយោបាយគាំងស្ទូកក្នុងខណៈដែលអ្នកច្បាប់មួយចំនួនមិនយល់ស្របគ្នាលើបញ្ហាថាតើវាត្រឹមត្រូវតាមនិយមន័យច្បាប់នៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ដែរឬយ៉ាងណា ។ របាយការណ៍របស់អង្គការឃ្លាំមើលសិទ្ធិមនុស្សស្តីពីប្រទេស រ៉្វាន់ដានៅនិទាឃរដូវ ឆ្នាំ១៩៩៤ មុនពេលមានអំពើប្រល័យពូជសាសន៍ដែលលោក ស្កាបាស់ ជួយសរសេរក៏មិនព្រមធ្វើការព្រមានក្រែងលោមានការប្រើពាក្យ «ប្រល័យពូជសាសន៍»នេះខុសដែរ ។

ឥឡូវនេះលោក វីលៀម ស្កាបាស់ ត្រូវបានគេយោងសម្តីនៅក្នុងសេចក្តីសម្រេចចិត្តមួយប្រកាសថា ការសម្លាប់រង្គាលនៅកូសូវ៉ូមិនមែនជាអំពើប្រល័យពូជសាសន៍ទេ ។សៀវភៅរបស់

លោកដែលមានចំណេះដឹងថា«អំពើប្រល័យពូជសាសន៍ក្នុងច្បាប់អន្តរជាតិ» គឺជាមូលដ្ឋាននៃការរកឃើញអង្គហេតុនេះដោយលោកអះអាងថាការធ្វើវិសុទ្ធកម្ម ឬបោសសម្អាតជនជាតិភាគតិច និងអំពើប្រល័យពូជសាសន៍ គឺមិនដូចគ្នាទេ ពីព្រោះចេតនាក្នុងការបោសសម្អាតជនជាតិភាគតិច គឺការដេញក្រុមមួយចេញចំណែកឯចេតនានៃអំពើប្រល័យពូជសាសន៍ គឺការកម្ទេចក្រុមទាំងមូល ។ នៅក្នុងការបែងចែកទង្វើសង្គមយ៉ាងច្បាស់នោះលោក ស្កាបាស់ ធ្វើជាមិនដឹងមិនឮចំពោះអង្គហេតុជាក់ស្តែងដែលបង្ហាញថាអំពើមនុស្សឃាតទ្រង់ទ្រាយធំ(រួមទាំងអំពើប្រល័យពូជសាសន៍ផង ដែលធ្វើឡើងក្នុងចេតនាកម្ទេចមួយផ្នែកនៃក្រុមជនជាតិ ជាតិពន្ធ និងសាសនាជាដើម) ពិតជាបានប្រព្រឹត្តឡើងនៅកូសូវ៉ូដើម្បីជាការបង្ភើលឲ្យប្រជាជនទាំងអស់ចាកចេញ ។ និយាយម្យ៉ាងវិញទៀត ទាំងអំពើប្រល័យពូជសាសន៍ និងការបោសសម្អាតក្រុមជាតិពន្ធ ត្រូវបានប្រព្រឹត្តឡើងនៅកូសូវ៉ូ ។ ការបដិសេធរបស់លោក ស្កាបាស់ កើតឡើងដោយសារកំហុសរបស់គាត់ដែលភ័ន្តច្រឡំរវាងមូលហេតុនិងចេតនាតាមផ្លូវច្បាប់ ។ មូលហេតុរបស់យូហ្គោស្លាវីអាចនិយាយបានថាមកពីចង់បណ្តេញជនជាតិកូសូវ៉ូចេញ ប៉ុន្តែការសម្លាប់ទ្រង់ទ្រាយធំបែបនេះផ្តុកទៅដោយចេតនាតាមផ្លូវច្បាប់គ្រប់គ្រាន់បាត់ទៅហើយក្នុងការកម្ទេចក្រុមជនជាតិកូសូវ៉ា ។ លោក ស្កាបាស់ ភ្លេចគិតថាឧក្រិដ្ឋកម្មច្រើន ក៏អាចត្រូវបានប្រព្រឹត្តឡើងនៅក្នុងកម្មវិធីជាប្រព័ន្ធតែមួយបានដែរដូចជាករណីនៅកូសូវ៉ូដែលមានទាំងអំពើប្រល័យពូជសាសន៍និងអំពើបោសសម្អាតក្រុមជាតិពន្ធ ។

ការបដិសេធរបស់លោក ស្កាបាស់ ថាមិនមានអំពើប្រល័យពូជសាសន៍ ទោះបីជាគាត់មានជំនាញច្បាស់លាស់របស់គាត់ក៏ដោយបានធ្វើឲ្យមានការប្រែប្រួលនៅក្នុប្រវត្តិសាស្ត្របាត់ទៅហើយ ។ លោក ស្កាបាស់ ចាំបាច់ត្រូវតែពិនិត្យអង្គហេតុរបស់ខ្មែរក្រហមដែលបានប្រព្រឹត្តទាំងអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនិងការវិវត្តន៍ថ្មីៗនៃច្បាប់ចាប់តាំងពីមានតុលាការនៅនូរិមប៊ឺកមក ។ លោកក៏គួរតែទទួលស្គាល់ថាអំពើប្រល័យពូជសាសន៍និងការបោសសម្អាតជាតិពន្ធមិនមែនខុសគ្នាទេ ហើយអំពើទាំងពីរនេះត្រូវបានប្រព្រឹត្តរួចហើយនៅក្នុងប្រទេសកម្ពុជានិងកូសូវ៉ូ ។

**គ្រីហ្គោរី ស្តែនតុន**



# តម្លៃនៃភស្តុតាង

**(តពីលេខមុន)** **៦) ឯកសារអ្នកទោស សៀង ផុន**

របាយការណ៍ចម្លើយសារភាពរបស់ សៀង ផុន (ហៅ ផា) រួមមានឈ្មោះ «កម្លាំងដែលពាក់ព័ន្ធក្នុងប្រវត្តិរបស់វា» ចំនួន៣៨នាក់ ។ នៅជិតឈ្មោះ ផន មានកំណត់សម្គាល់មួយដាក់ថា «កម្ទេចចោល» ។ ឯកសារនេះត្រូវបានផ្ញើជូន នួន ជា ហើយប្រហែលត្រូវបានផ្ញើទៅភូមិភាគកណ្តាល (ដែលមាន កែ ពក ជាប្រធាន) ដែរ ។ កំណត់សម្គាល់នេះអាចជួយបង្ហាញថា នួន ជា (និងប្រហែលជា កែ ពក) មានការទទួលខុសត្រូវលើបញ្ញើពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ឯកសារនេះបង្ហាញអំពីបំណងឧក្រិដ្ឋ (ឧបមាម្តងទៀតគ្មានវិធានការដាក់ទណ្ឌកម្ម) ហើយអំពើពិរុទ្ធអាចត្រូវបានបង្ហាញថាពិតតាមរយៈភស្តុតាងដែលបញ្ជាក់ថា ក្រោយមក ផន ត្រូវបានសម្លាប់មែននោះ ។ កំណត់សម្គាល់សរសេរដោយដៃក៏ផ្តល់ជាភស្តុតាងមួយកម្រិតស្តីអំពីផែនការ«កម្ទេច»បុគ្គលិកដែលត្រូវបានចាត់ទុកថាជាខ្មាំងនយោបាយ ។

**៧) របាយការណ៍**

របាយការណ៍សួរចម្លើយរបស់ ញឹម ស៊ុម (ហៅ សូត) មានសម្តីរបស់អ្នកសួរចម្លើយថា «បន្ទាប់មកខ្ញុំធ្វើទារុណកម្មទើបវាឆ្លើយ»ជាគិញនិងភ្នាក់ងារសេ.អ៊ី.អា ។ របាយការណ៍នេះត្រូវបានផ្ញើជូន នួន ជា និងភូមិភាគកណ្តាល (ដែលមាន កែ ពក ជាប្រធាន) ។ ភាសានេះបង្ហាញច្បាស់ថា ញឹម ស៊ីម ត្រូវបានធ្វើទារុណកម្មដើម្បីជម្រិតយកចម្លើយសារភាព ហើយបើសន្មតថា ទាំង នួន ជា និង កែ ពក មិនបានចាត់វិធានការដាក់ទណ្ឌកម្មទៅលើអ្នកសួរចម្លើយនោះ នឹងចូលធាតុផ្សំនៃការទទួលខុសត្រូវលើការបញ្ជាពីបទទារុណកម្ម ។

**៨) កំណត់ហេតុស្តីអំពីទស្សនកិច្ចអចិន្ត្រៃយ៍ នៅភូមិភាគពាយ័ព្យ ថ្ងៃទី២០-២៤ ខែសីហា ឆ្នាំ១៩៧៥**

ក) កំណត់ហេតុមានសរសេរថា «ប៉ុន្តែដោយឡែកសង្កេតឃើញថា នៅកន្លែងណាមានកម្មាភិបាលល្អ ស្នូលដឹកនាំ និងប្រជាជននឹងន កន្លែងណាគ្មានកម្មាភិបាល ឬស្នូលមិននឹងន អាក់រអួលច្រើនដែរ ។ ប្រជាជនរហេតរហូត» ។ សមាជិកគ្រប់រូបនៃគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលនៅក្នុងខណៈនោះរួមមាន នួន ជា អៀង សារី ម៉ុក និងប្រហែល កែ ពក នោះអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវយ៉ាងសមហេតុផលថាបានដឹងពួអំពីមាតិកាក្នុងកំណត់ហេតុនេះ ។ សេចក្តីថ្លែងនេះចង្អុលបង្ហាញថាប្រជាជនមិនត្រូវបានអនុញ្ញាតឲ្យដើរទៅណាមកណាសេរីឡើយ នេះជាសញ្ញាណបញ្ជាក់អំពីការបង្ខំឲ្យធ្វើពលកម្មជាទម្ងន់ ឬការអនុវត្តដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងអំពើទាសភាព ។ មិនតែប៉ុណ្ណោះសេចក្តីថ្លែងនេះក៏បង្ហាញថា មជ្ឈិមបក្សនៃបក្សកុម្មុយនិស្តកម្ពុជាបានជំរុញឲ្យអនុវត្តបែបនេះ ។ ដូច្នេះឯកសារនេះផ្តល់ជាជំនួយដល់ទស្សីករណ៍មួយថា គណៈអចិន្ត្រៃយ៍អាចត្រូវបានដាក់ឲ្យទទួលខុសត្រូវពីបទបង្ខំឲ្យធ្វើការងារពលកម្មជាទម្ងន់ ឬអំពើទាសភាព ។

ខ) កំណត់ហេតុនេះក៏មានសេចក្តីថ្លែងមួយទៀតថា «នៅខាងលើផ្លូវរថភ្លើង ពួកថៃវាបន្ទំចូលមកធ្វើស្រែក្នុងដីយើងចម្ងាយពាក់ឡូម៉ែត្រ ។ យើងកំពុងដេញកម្ចាត់វា ។ ពួកវាធ្វើវិទ្ធង្សនា បាចខិត្តប័ណ្ណនៅភ្នំម៉ាឡៃបន្តិចបន្តួចទេ ។ ខ្សែវាគឺអាមេរិកចិញ្ចឹម» ។ យោងតាមអង្គហេតុនេះសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍បង្ហាញពីបំណងឧក្រិដ្ឋនៃបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដោយសារខ្លួនបានស្តែងចេញឲ្យឃើញនូវចេតនាក្នុងការ«កម្ទេច»ជនជាតិថៃ ដោយសារមូលហេតុសកម្មភាពនយោបាយឬជនជាតិ ។ ប្រសិនបើអាចមានការបង្ហាញថាក្រោយមកជនជាតិថៃត្រូវបានសម្លាប់មែននោះនឹងចូលជាអំពើពិរុទ្ធ ហើយសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍អាចត្រូវបានដាក់ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌអំពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។

ឧទាហរណ៍ខាងលើនេះបង្ហាញត្រឹមតែអំពីចំណែកឯកសារតូចមួយដែលភ្ជាប់ នួន ជា ទៅនឹងអំពើព្រហ្មទណ្ឌមួយចំនួន ។ ឧទាហរណ៍បន្ថែមទៀតមាននៅក្នុងសំណេររបស់ អេលីហ្សាប៊ែត មូឌី មានចំណងជើងថាៈ អនុស្សរណៈ-ការវាយតម្លៃដំបូងទៅ

លើភ័ស្តុតាងតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា(១៩៩៨) ។ ជាការសំខាន់ណាស់ក្នុងការកត់សម្គាល់ថា អនុស្សរណៈដែលរៀបរៀងឡើងដោយ មូធី មិនគួរយកមកធ្វើជាមូលដ្ឋាននៃការវាយតម្លៃពេញលេញទៅលើឯកសារនៅមជ្ឈមណ្ឌលឯកសារទេ ។ មិនខុសគ្នាទៅនឹងរបាយការណ៍ផ្នែកច្បាប់នេះទេ អនុស្សរណៈនោះ គ្រាន់តែបង្ហាញនូវឧទាហរណ៍មួយចំនួនស្រង់ចេញមកពីការពិនិត្យឯកសារទាក់ទងនឹងប្រភេទផ្សេងៗនៃឯកសារដែលអាចមានសារប្រយោជន៍សម្រាប់កាត់សេចក្តីដែលនឹងកើតឡើងនៅពេលខាងមុខតែប៉ុណ្ណោះ ។

### ខ) អៀង សារី ហៅ វ៉ាន់

ភ័ស្តុតាងឯកសារប្រឆាំងនឹងករណី អៀង សារី មិនសូវជាមានទម្ងន់ប៉ុន្មានទេ ទោះជាតម្លៃជាក់លាក់នៃឯកសារបានមកពីតុលាការឆ្នាំ១៩៧៩ ដែលមានភាពមិនច្បាស់លាស់ ហើយអាចបន្ថែមទម្ងន់ទៅលើភ័ស្តុតាងប្រឆាំងនឹងបុគ្គលនេះក៏ដោយ ។ អំណាចបញ្ជាតាមច្បាប់របស់ អៀង សារី បានបង្ហាញច្បាស់តាមរយៈឯកសាររបស់បក្សកុម្មុយនិស្តកម្ពុជា ហើយ អៀង សារី ខ្លួនឯងជាអ្នកបានទទួលអនុស្សរណៈឆ្លើយឆ្លងគ្នាជាច្រើនដែលជាការបញ្ជាក់ថាខ្មាំងរបស់បក្សបាន"កម្ទេចចោល" និង/ឬធ្វើទារុណកម្ម ។ ការឆ្លើយឆ្លងគ្នាដែលដាក់ថា របាយការណ៍អំពីការរីកចម្រើន បង្ហាញឲ្យឃើញពីការបញ្ជា ឬការចូលដៃរបស់ អៀង សារី ហើយមិនមានភ័ស្តុតាងណាបង្ហាញថា អៀង សារី បានចាត់វិធានការក្នុងការទប់ស្កាត់ឬដាក់ទណ្ឌកម្មប្រឆាំងនឹងបទល្មើសដែលមានចរិតប្រហាក់ប្រហែលគ្នានេះទេ ។ អៀង សារី គឺជាសមាជិកនៃគណៈកម្មាធិការជាន់ខ្ពស់ដែលពិភាក្សានិងឲ្យជាយោបល់ជាសមូហភាព(តាមពាក្យមិនសូវច្បាស់លាស់)ឲ្យបន្តវិសុទ្ធកម្មប្រឆាំងនឹងអ្នកជិតស់ ។ អៀង សារី ក៏ជាអ្នកដែលបានទទួលរបាយការណ៍មួយចំនួនផ្ញើមកពីមន្ទីរស-២១ ដែលធ្វើឲ្យ អៀង សារី ពាក់ព័ន្ធពីបទ "ទារុណកម្ម" ។ ដូច្នេះភ័ស្តុតាងប្រយោលប្រឆាំងនឹង អៀង សារី គួបផ្សំជាមួយរបាយការណ៍ដែនទីកំណត់ហេតុកិច្ចសម្ភាសន៍ និងឯកសារផ្សេងៗទៀត គឺមានទម្ងន់ ទោះបីជាភ័ស្តុតាងចំពោះមុខមិនសូវសំបូរក៏ដោយ ។

សរុបមក ឯកសារផ្តល់ជាសំណុំរឿងយ៉ាងមានទម្ងន់ប្រឆាំងនឹង អៀង សារី ពីបទទារុណកម្មនិងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ភ័ស្តុតាងប្រយោលក៏ធ្វើឲ្យ អៀង សារី ពាក់ព័ន្ធក្នុងឧក្រិដ្ឋកម្មសង្គ្រាម អំពើប្រល័យពូជសាសន៍ និងការបន្ទុំឲ្យធ្វើការផាររជាទម្ងន់ដែរ ។

ឧទាហរណ៍មួយចំនួនមកពីឯកសារទាក់ទងនឹង អៀង សារី មានដូចខាងក្រោមដែលមានអមដោយការពិភាក្សាយ៉ាងសង្ខេបទៅលើវិធីក្នុងការយកឯកសារមកប្រើប្រាស់ជាភ័ស្តុតាងនៅក្នុងអង្គជំនុំជម្រះក្តី ហើយប្រសិនបើមានតើភ័ស្តុតាងអ្វីដែលអាចផ្តល់ជាសារប្រយោជន៍បំផុតនៅក្នុងការដំណើរការកាត់សេចក្តី÷

១) "សេចក្តីសម្រេចរបស់គណៈកម្មាធិការមជ្ឈិមទៅលើបញ្ហាមួយចំនួន" ៣០ មីនា ១៩៧៦ (ប្រែសម្រួលនិងបោះពុម្ពសាជាថ្មីនៅក្នុងសៀវភៅ "ផែនការអនាគត"ដែលនិពន្ធដោយលោក ដាវីដ ឆេនដល័រ) ។

ក) ចំណុចទី១ចែងថា "អំណាចក្នុងការកម្ទេច(ប្រជាជន)នៅក្នុងនិងក្រៅជួរ" ។ ការអនុវត្តចំពោះផ្លូវច្បាប់ប្រឆាំងនឹង អៀង សារី មានលក្ខណៈប្រហាក់ប្រហែលនឹងករណី នួន ជា ដែរ (មើលចំណុច ក ខាងលើ) ។

ខ) ចំណុចទី៦ ប្រកាសថាកងកម្លាំងប្រដាប់អាវុធ "វាយកម្ទេច" មហាវិហារគ្រិស្ត ។ ការអនុវត្តចំពោះផ្លូវច្បាប់ប្រឆាំងនឹង អៀង សារី មានលក្ខណៈប្រហាក់ប្រហែលនឹងករណី នួន ជា ដែរ (មើលចំណុច ក ខាងលើ) ។

គ) តួនាទី អៀង សារី ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស គឺជាភ័ស្តុតាងបង្ហាញថា នួន ជា បានកាន់កាប់មុខតំណែងដឹកនាំជាន់ខ្ពស់ ហើយមានលក្ខណៈបង្ហាញផ្លូវបញ្ជាក់អំពីអាជ្ញាបញ្ជាស៊ីវិល"តាមច្បាប់" និង"ព្រឹត្តិន័យ" ។

២) ឯកសារៈ "គោរពជូន គណៈ៨៧០ ជាទីស្នេហា" ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៨ (មើលការពិភាក្សាដែលទាក់ទងនឹង នួន ជា និង អៀង សារី នៅចំណុច ក ខាងដើម) ។

៣) ឯកសារ កំណត់ហេតុ សរសេរដោយដៃ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៨ (មើលការពិភាក្សាដែលទាក់ទងនឹង នួន ជា និង អៀង សារី នៅចំណុច ក ខាងលើ) ។

៤) កំណត់ហេតុអំពីទស្សនកិច្ចរបស់គណៈកម្មាធិការ

អចិន្ត្រៃយ៍ នៅភូមិភាគពាយ័ព្យ ថ្ងៃ២០-២៤ សីហា ឆ្នាំ១៩៧៥ (មើលការពិភាក្សានៅចំណុច ក ខាងលើ) ។ អៀង សារី គឺជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍និងមានការទទួលខុសត្រូវចំពោះមាតិកាកំណត់ហេតុនេះ ។

មូធី និងអ្នកដទៃទៀតផ្តល់នូវឧទាហរណ៍ពីឯកសារបន្ថែមទៀតដែលអាចយកមកប្រើនៅក្នុងការជម្រះក្តីករណី អៀង សារី ។

### ក) ឈិត ជឿន ហៅ ម៉ុក

មិនខុសពី អៀង សារី ទេ ម៉ុក ស្ថិតក្នុងតំណែងអំណាចបញ្ជាដូចដែលបង្ហាញឲ្យឃើញស្រាប់តាមរយៈឯកសារកំណត់ហេតុគណៈកម្មាធិការ និងការទាក់ទងគ្នានៅក្នុងជួរបក្ស ។ ម៉ុក ក៏ជាអ្នកដែលបានទទួលរបាយការណ៍ចម្លើយសារភាពជាច្រើនដែលក្នុងឯកសារទាំងនោះអ្នកសួរចម្លើយបានរាយការណ៍អំពីការធ្វើទារុណកម្មនិង"ការកម្ទេច" ។ ម៉ុក គឺជាគណៈភូមិភាគនិរតីរបស់បក្សកុម្មុយនិស្តកម្ពុជា ហើយរបាយការណ៍ដែនទីនិងពត៌មានបានមកពីកំណត់ហេតុកិច្ចសម្ភាសន៍ផ្តល់នូវភ័ស្តុតាងប្រយោលដែលបញ្ជាក់ថា ម៉ុក បានដឹងឮអំពីការសម្លាប់មនុស្សជាច្រើនកើតឡើងនៅក្នុងតំបន់ដែលខ្លួនកាន់កាប់ ។ ប្រភពនៃភ័ស្តុតាងដែលនេះចង្អុលបង្ហាញថា ម៉ុក បានជំរុញនិងបណ្តោយឲ្យមានសកម្មភាពឧក្រិដ្ឋកើតឡើងនៅពីក្រោមខ្លួន ។ និយាយដោយខ្លី មានករណីដែលមានទម្ងន់មួយប្រឆាំងនឹង ម៉ុក ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនិងទារុណកម្ម ។ ភ័ស្តុតាងជាប្រយោល ភ្ជាប់មក ម៉ុក ពីបទបង្ខំឲ្យធ្វើការជាទម្ងន់ និងអំពើប្រល័យពូជសាសន៍ ។

ឧទាហរណ៍ឯកសារមួយចំនួនដែលទាក់ទងនឹង ម៉ុក មានដូចខាងក្រោមដែលមានអមដោយការពិភាក្សាយ៉ាងសង្ខេបទៅលើវិធីក្នុងការយកឯកសារមកប្រើប្រាស់ជាភ័ស្តុតាងនៅក្នុងអង្គជំនុំជម្រះក្តី ហើយប្រសិនជាមាន តើភ័ស្តុតាងអ្វីដែលអាចផ្តល់ជាសារប្រយោជន៍បំផុតនៅក្នុងការដំណើរការកាត់សេចក្តី ៖

១) "សេចក្តីសម្រេចរបស់គណៈកម្មាធិការមជ្ឈិមទៅលើបញ្ហាជាច្រើន" ៣០ មីនា ១៩៧៦ (ប្រែសម្រួលនិងបោះពុម្ពសាជាថ្មីនៅក្នុងសៀវភៅៈ ផែនការអនាគតដែលនិពន្ធដោយលោក ដេវីដ ឆេនដល័រ និងអ្នកផ្សេងទៀត) ។

ក) ចំណុចទី១ ចែងថា "អំណាចក្នុងការកម្ទេច (ប្រជាជន) នៅក្នុងនិងក្រៅជួរ" ។ ការអនុវត្តចំពោះជួរច្បាប់ប្រឆាំងនឹងម៉ុក មានលក្ខណៈប្រហាក់ប្រហែលនឹងករណី នួន ជា ដែរ (មើលចំណុច ក ខាងលើ) ។

ខ) ចំណុចទី៦ ប្រកាសថា កងកម្លាំងប្រដាប់អាវុធ "វាយកម្ទេច" មហាវិហារគ្រិស្ត ។ ការអនុវត្តចំពោះជួរច្បាប់ប្រឆាំងនឹង ម៉ុក មានលក្ខណៈប្រហាក់ប្រហែលនឹងករណី នួន ជា ដែរ (មើលចំណុច ក ខាងលើ) ។

គ) ម៉ុក ជាអនុប្រធានរដ្ឋសភាដែលជាអង្គការតំណាងឲ្យរដ្ឋាភិបាលមជ្ឈិម ។ តួនាទីរបស់ ម៉ុក ជាអនុប្រធានរដ្ឋសភា ភ័ស្តុតាងបង្ហាញថា ម៉ុក បានកាន់កាប់មុខតំណែងដឹកនាំខ្ពស់ ហើយមានលក្ខណៈបង្ហាញផ្លូវ បញ្ជាក់អំពីអាជ្ញាបញ្ជាស៊ីវិល "តាមច្បាប់" និង "ព្រឹត្តិន័យ" ។

២) កំណត់ហេតុអំពីទស្សនកិច្ចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ នៅភូមិភាគពាយ័ព្យ ថ្ងៃ ២០-២៤ សីហា ឆ្នាំ ១៩៧៥ (មើលការពិភាក្សានៅក្នុងចំណុច ក ខាងលើ) ។ ប្រសិនបើមានការបង្ហាញថា ម៉ុក ជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ នៅក្នុងខណៈពេលដែលឯកសារនេះត្រូវបានរៀបចំឡើងនោះ ម៉ុក មានការទទួលខុសត្រូវចំពោះមាតិកាដែលមាននៅក្នុងកំណត់ហេតុ ។

៣) របាយការណ៍ដែនទី (១៩៩៧ និង១៩៩៨)

របាយការណ៍ដែនទីដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្តល់ជាពត៌មានច្រើនអនេកពីសាក្សីដែលឃើញការអនុវត្តអំពើប្រល័យពូជសាសន៍អំពើទារុណកម្មនិងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផ្ទាល់ភ្នែក ។ គ្មានសាក្សីឃើញហេតុការណ៍ផ្ទាល់ភ្នែកណាម្នាក់បានទាក់ទងជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់ខ្មែរក្រហមទេ ។ ភាគច្រើននៃថ្នាក់ដឹកនាំជាន់ខ្ពស់ទាំងនេះហាក់ដូចជាធ្វើឲ្យខ្លួនឯងឃ្លាតឆ្ងាយពីអំពើឃោរឃៅដែលប្រព្រឹត្តឡើងដោយកូនចៅនៅក្រោមបង្គាប់បញ្ជារបស់ខ្លួន ។ ក៏ប៉ុន្តែភ័ស្តុតាងជាក់ស្តែងដ៏ច្រើនលើសលប់បង្ហាញពីអំពើឃោរឃៅប្រព្រឹត្តឡើងដោយខ្មែរក្រហមក្នុងទម្រង់ជាគុកនិងវាលកប់ខ្មោចរួមនៅ

ក្នុងភូមិភាគសំខាន់ៗរបស់កម្ពុជាប្រជាធិបតេយ្យអាចនាំតុលាការ ឬសាលាក្តីចោទថាគណៈភូមិភាគរបស់បក្សស្ថិតនៅក្រោមការគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យនិងប្រហែលជាអ្នកនៅពីលើពោលគឺមជ្ឈិមបក្សមានការដឹងឮអំពីទង្វើទាំងនេះ ។

នៅក្នុងវគ្គនេះខ្ញុំនឹងធ្វើការពិភាក្សាអំពីរបាយការណ៍ដែនទីទាក់ទងត្រឹមតែតាម៉ុក និង កែ ពក ប៉ុណ្ណោះ ។ ក៏ប៉ុន្តែគួរកត់សម្គាល់ដែរថារបាយការណ៍ដែនទី(ទោះបីជាមិនទាន់លើសលប់យ៉ាងណាក៏ដោយ) ផ្តល់ជាភស្តុតាងដ៏មានទម្ងន់ប្រឆាំងនឹងមន្ត្រីបក្សកុម្មុយនិស្តកម្ពុជាដូចជា នួន ជា អៀង សារី និង ខៀវ សំផន ។

ម៉ុក ដែលធ្វើជាគណៈភូមិភាគនិរតី និង កែ ពក ជាគណៈភូមិភាគឧត្តរ(ក្រោយមកជាភូមិភាគកណ្តាល) គឺជាគណៈភូមិភាគនៃរបបកម្ពុជាប្រជាធិបតេយ្យដែលនៅរស់ដល់សព្វថ្ងៃ ។ តារាងខាងក្រោមនេះបង្ហាញនូវលទ្ធផលមួយចំនួនបានមកពីការសិក្សាដែនទីឆ្នាំ១៩៩៧និង១៩៩៨ដោយមជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងតំបន់ដែល ម៉ុក និង កែ ពក បានកាន់កាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ដូចដែលបានបង្ហាញជូននៅខាងក្រោមនេះ ភូមិភាគនីមួយៗមានគុកនិងរណ្តៅសាកសពរួមអណ្តូង ឬទីតាំងផ្សេងទៀតជាច្រើនដែលត្រូវបានប្រើសម្រាប់ចោលសាកសព ។ គួរកត់សម្គាល់ថា ខេត្តខ្លះដែលមានរាយឈ្មោះនៅទីនេះមិនត្រូវពិតប្រាកដជាមួយនឹងភូមិភាគដែលចាត់តាំងដោយរបបកម្ពុជាប្រជាធិបតេយ្យទេ ហើយគួរតែចាត់ទុកជាការប៉ាន់ប្រមាណបានហើយ ។ ជាងនេះទៅទៀតស្ថិតិនៅខាងក្រោមនេះគ្រាន់តែបង្ហាញពីរបកគំហើញថ្មីៗរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងឆ្នាំ១៩៩៧និង១៩៩៨តែប៉ុណ្ណោះ ។ ដូច្នេះវាបង្ហាញត្រឹមតែមួយផ្នែកតូចនៃចំនួនគុករណ្តៅសាកសពរួមទីវាលកប់សាកសព និងជនរងគ្រោះតែប៉ុណ្ណោះ ។

ក) ភូមិភាគនិរតី (គ្រប់គ្រងដោយ ម៉ុក)

ក្នុងខេត្តកំពង់ស្ពឺ មានគុក៤ រណ្តៅរួមប៉ាន់ស្មាន ១.៥៤៣ ប្រភេទរណ្តៅផ្សេងៗ១ ជនរងគ្រោះប៉ាន់ស្មាន ២៣.៩៣២ ។ ក្នុងខេត្តកំពង់ឆ្នាំង មានគុក ៤ រណ្តៅរួមប៉ាន់ស្មាន ១.៧៣៣ ប្រភេទរណ្តៅផ្សេងៗ១ ជនរងគ្រោះប៉ាន់ស្មាន២៤៩.៩៥៤ ។ ក្នុងខេត្តកោះកុង មានគុក១ រណ្តៅរួមប៉ាន់ស្មាន១ ប្រភេទរណ្តៅផ្សេងៗ ០ ជនរងគ្រោះប៉ាន់ស្មាន ១៧.៣៤៩ ។ សរុបខេត្តទាំងបីនេះមានគុក ៩ រណ្តៅរួមប៉ាន់ស្មាន ៣.២៧៧ ប្រភេទរណ្តៅផ្សេងៗ ២ ជនរងគ្រោះប៉ាន់ស្មាន២៩១.២៣៥ ។

ខ) ភូមិភាគឧត្តរ (ក្រោយមកភូមិភាគកណ្តាល) គ្រប់គ្រងដោយ កែ ពក ៖

ក្នុងខេត្តកំពង់ធំ មានគុក ៦ រណ្តៅរួមប៉ាន់ស្មាន ១.៤២៧ ប្រភេទរណ្តៅផ្សេងៗ៥ ជនរងគ្រោះប៉ាន់ស្មាន ១២៣.៨០៨ ។ ក្នុងខេត្តកំពង់ចាម មានគុក៥ រណ្តៅរួមប៉ាន់ស្មាន ១៤៨៥ ប្រភេទរណ្តៅផ្សេងៗ៤ ជនរងគ្រោះប៉ាន់ស្មាន ៩៧.៥៧៣ ។ សរុបខេត្តទាំងពីរនេះមានគុក១១ រណ្តៅរួមប៉ាន់ស្មាន២.៩១២ ប្រភេទរណ្តៅផ្សេងៗ១៤ ជនរងគ្រោះប៉ាន់ស្មាន២២១.៣៨១ ។

ទោះបីជាស្ថិតិនេះជាការប៉ាន់ស្មានហើយបង្ហាញត្រឹមតែរបកគំហើញរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងការចុះស្រាវជ្រាវរយៈពេល២ឆ្នាំក៏ដោយ ក៏ចំនួនដ៏គួរឲ្យភ្ញាក់ផ្អើលនៃរណ្តៅកប់ខ្មោចដែលត្រូវបានជីកនិងប្រជាជនដែលត្រូវបានសម្លាប់ធ្វើឲ្យពិបាកជឿណាស់ថា ម៉ុក និង កែ ពក មិនមែនមិនដឹងពីការសម្លាប់ដែលកើតឡើងនៅក្នុងតំបន់ដែលខ្លួនគ្រប់គ្រងផ្ទាល់ទេ ។ គ្មានភស្តុតាងឯកសារណាមួយដែលត្រូវបានពិនិត្យរួចហើយបង្ហាញថាថ្នាក់ដឹកនាំភូមិភាគបានចាត់វិធានការដ៏មានសារសំខាន់និងមានលក្ខណៈជាទណ្ឌកម្មដល់កូនចៅនៅក្រោមបង្គាប់បញ្ជារបស់ខ្លួនដែលបានធ្វើការកាប់សម្លាប់មនុស្សបែបនេះទេ ។ ដូច្នេះភស្តុតាងជាក់ស្តែងដ៏ច្រើនហូរហៀរបានក្លាយជាសន្ទឹកដ៏ធំមួយបញ្ជាក់ច្បាស់ថា ម៉ុក និង កែ ពក ក) បានដឹងអំពីការកាប់សម្លាប់ក្នុងចំនួនច្រើន និង ខ) ចូលរួមប្រព្រឹត្តតាមរយៈការខកខានមិនបានផ្តន្ទាទោសអ្នកដែលប្រព្រឹត្តអំពើទាំងនេះ ទោះជាមិនបានបញ្ជាឲ្យសម្លាប់ក៏ដោយ ។

ទោះជា ម៉ុក និង កែ ពក អះអាងថា ខ្លួនមិនបានដឹងថាមានរណ្តៅសាកសពរួមរាប់ពាន់ និងការកាប់សម្លាប់មនុស្សរាប់សែននៅក្នុងភូមិភាគដែលខ្លួនកាន់កាប់ក៏ដោយ ក៏គ្មានអ្វីគួរឲ្យសង្ស័យទេថា ម៉ុក និង កែ ពក គួរតែបានដឹងនិងមានករណីយកិច្ចក្នុងការស៊ើបអង្កេតតាមដានស្ថានការណ៍នេះ ។ ក្នុងករណីមានការស៊ើបអង្កេតសមហេតុផលមួយនៅភូមិភាគនិរតី ឬភូមិភាគ

ខត្តរ ក្រោមការដឹកនាំរបស់របបកម្ពុជាប្រជាធិបតេយ្យអាចនឹងរកឃើញការកាប់សម្លាប់នេះហើយ ។ ក៏ប៉ុន្តែទោះជាយ៉ាងនេះក្តី ដើម្បីចោទប្រកាន់ ម៉ុក និង កែ ពក ពីបទប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ លុះត្រាតែបង្ហាញឲ្យឃើញថា បុគ្គលទាំងនោះត្រូវបានសម្លាប់ដោយ ក) ចេតនាកម្ទេចទាំងស្រុង ឬដោយផ្នែកនូវក្រុមជនជាតិ ជាតិពន្ធុ ជាតិសាសន៍ ឬសាសនា(នៅក្នុងករណីអំពើប្រល័យពូជសាសន៍) ឬ ខ) ដោយឈរលើហេតុផលនយោបាយជាតិសាសន៍ ឬវប្បធម៌ ។ អត្ថិភាពនៃរណ្តៅសាកសពរួមមិនបានបង្ហាញឲ្យហួសពីហេតុផលថាការសម្លាប់ត្រូវបានផ្អែកមូលហេតុដែលរៀបរាប់នេះទេ ។ ដើម្បីស៊ើបអង្កេតអំពីករណីនេះចាំបាច់ត្រូវតែមានឯកសារយោងភ័ស្តុតាងផ្សេងទៀត ។

មូធី និងអ្នកផ្សេងទៀតផ្តល់នូវការពិភាក្សាយ៉ាងសង្ខេបចំពោះឯកសារបន្ថែមដែលអាចយកមកប្រើប្រាស់ជាភ័ស្តុតាងប្រឆាំងនឹង ម៉ុក នៅក្នុងការជំនុំជម្រះផ្នែកព្រហ្មទណ្ឌមួយ ។ ប៉ុន្តែអ្នកទាំងនោះលើកយកតែឧទាហរណ៍ចេញពីកំណត់ហេតុសរសេរដោយដៃដែលកម្មាភិបាលបក្សកម្មុយនិស្តកម្ពុជាផ្ញើជូន ម៉ុក តែប៉ុណ្ណោះ ។

***ឃ) កែ ពក***

ភ័ស្តុតាងប្រឆាំងនឹង កែ ពក គឺមានទំហំប្រដូចប្រសងគ្នាទៅនឹងភ័ស្តុតាងប្រឆាំងនឹង ម៉ុក ដែរ ។ ក្នុងតួនាទីជាគណៈភូមិភាគខត្តរនិងជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស ភ័ស្តុតាងបញ្ជាក់អំពីអាជ្ញាបញ្ញា"តាមច្បាប់"របស់ កែ ពក គឺមានបង្ហាញច្បាស់នៅក្នុងឯកសារមួយចំនួន ។ ឯកសារជាច្រើនដែលរៀបរាប់លម្អិតអំពីទារុណកម្មឬឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក៏ត្រូវបានចម្លងជូន"ភូមិភាគមជ្ឈិម"ដែរ ដែលមាន កែ ពក ជាគណៈដឹកនាំផ្ទាល់ ។ ឈ្មោះ កែ ពក ត្រូវបានសរសេរនៅក្នុងចម្លើយសារភាពនិងរបាយការណ៍មួយចំនួនផ្សេងទៀតដែលមិនបានផ្ញើឲ្យសាមីខ្លួន ។ ភ័ស្តុតាងប្រយោលប្រឆាំងនឹងខ្លួន ម៉ុក មានទម្ងន់ណាស់ ហើយសំណុំរឿងមានលក្ខណៈដូចគ្នានេះ ក៏មានដែរដែលប្រឆាំងនឹង ម៉ុក ពីបទទារុណកម្មនិងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។

ឧទាហរណ៍ឯកសារមួយចំនួនដែលទាក់ទងនឹង កែ ពក មានដូចខាងក្រោម ដែលមានអមដោយការពិភាក្សាយ៉ាងសង្ខេបទៅលើវិធីក្នុងការយកឯកសារមកប្រើប្រាស់ជាភ័ស្តុតាងនៅក្នុងអង្គជំនុំជម្រះក្តី ហើយប្រសិនបើមានតើភ័ស្តុតាងអ្វីដែលអាចផ្តល់ជាសារប្រយោជន៍បំផុតនៅក្នុងដំណើរការកាត់សេចក្តី ÷

**១)** *"សេចក្តីសម្រេចរបស់គណៈកម្មាធិការមជ្ឈិមទៅលើបញ្ហាជាច្រើន" ៣០ មីនា ១៩៧៦ (ប្រែសម្រួលនិងបោះពុម្ពសាជាថ្មីនៅក្នុងសៀវភៅ "ផែនការអនាគត"ដែលនិពន្ធដោយលោក ដេវីដ ឆេនដល័រ)÷*

ក) ចំណុចទី១ចែងថា "អំណាចក្នុងការកម្ទេច(ប្រជាជន)នៅក្នុងនិងក្រៅជួរ" ។ ការអនុវត្តចំពោះផ្លូវច្បាប់ប្រឆាំងនឹង កែ ពក មានលក្ខណៈប្រហាក់ប្រហែលនឹងករណី នួន ជា ដែរ (មើលចំណុច ក ខាងលើ) ។

ខ) ចំណុចទី៦ប្រកាសថា កងកម្លាំងប្រដាប់អាវុធ "វាយកម្ទេច" មហាវិហារគ្រិស្ត ។ ការអនុវត្តចំពោះផ្លូវច្បាប់ប្រឆាំងនឹង កែ ពក មានលក្ខណៈប្រហាក់ប្រហែលនឹងករណី នួន ជា ដែរ (មើលចំណុច ក ខាងលើ) ។

**២)** *របាយការណ៍*

មើលការពិភាក្សាលើរបាយការណ៍ចម្លើយសារភាពរបស់ញឹម ស៊ីម (ហៅ សូត្រ) នៅចំណុច ក ខាងលើ ។ របាយការណ៍នេះត្រូវបានផ្ញើជូន កែ ពក ហើយបង្កើតបានជាការទទួលខុសត្រូវលើការបញ្ជាពីបទធ្វើទារុណកម្ម ក្នុងករណីដែលអ្នកប្រព្រឹត្តមិនត្រូវបានដាក់ទណ្ឌកម្មចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត ។

**៣)** *ឯកសារ*

ទុយ ដែលជាអ្នកសួរចម្លើយ គាំ ចាន់ ហៅ ចន បានសរសេរនៅក្នុងរបាយការណ៍ចម្លើយសារភាពរបស់ខ្លួនថា "ខ្ញុំធ្វើទារុណកម្មវាកន្លះថ្ងៃហើយវ៉ៃវាជាច្រើនលើកទៀតឲ្យវាឆ្លើយ" ។ ដូច្នេះរបាយការណ៍នេះបង្ហាញយ៉ាងច្បាស់អំពីការធ្វើទារុណកម្មនិងការវាយដំម្តងហើយម្តងទៀត ។ របាយការណ៍នេះដូចជាត្រូវបានផ្ញើជូន កែ ពក ។ ប្រសិនបើមានអង្គហេតុបែបនេះមែនហើយ កែ ពក មិនបានដាក់ទណ្ឌកម្មឈ្មោះ ទុយ នោះ កែ ពក មានការទទួលខុសត្រូវលើការបញ្ជាពីបទទារុណកម្ម ។ ***(នៅមានត)***

**ចន ឆរតីអារី**

# ប្រយុទ្ធដើម្បីការពិតនិងយុត្តិធម៌

## កិច្ចសម្ភាសន៍របស់កាសែតភ្នំពេញប៉ុស្តិ៍ជាមួយអ្នកនាំមុខលើការបញ្ចេញគំនិតនៅក្នុងប្រទេសកម្ពុជា: លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

ដោយ រ៉ូបឹត ខារ៉ៃម៉េយើល

***តើមូលហេតុអ្វី បានជាលោកជ្រើសរើសការងារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា?***

*មូលហេតុទីមួយ គឺខ្ញុំធ្លាប់រស់នៅក្នុងរបបខ្មែរក្រហម ហើយក្រោយមកក៏បានទៅរស់នៅសហរដ្ឋអាមេរិក ។ នៅពេលខ្ញុំទៅសហរដ្ឋអាមេរិក ខ្ញុំចង់ប្រាប់ប្រជាពលរដ្ឋនៅទីនោះនូវអ្វីដែលខ្ញុំបានជួបប្រទះក្រោមរបបខ្មែរក្រហម ប៉ុន្តែគេហាក់ដូចជាមិនសូវជឿសោះ ។ ខ្ញុំពិបាករកពាក្យពេចន៍យកមកនិយាយរៀបរាប់អំពីអ្វីដែលខ្ញុំបានទទួលរងនៅក្នុងរបបខ្មែរក្រហមណាស់ ។*

*ខ្ញុំសូមលើកឧទាហរណ៍ជាក់ស្តែងមួយមកជម្រាបជូន ។ បងស្រីខ្ញុំដែលមានកូនស្រីតូចពីរនាក់ត្រូវបានចោទប្រកាន់ថាគាត់បានលួចបាយសមូហភាពហូប ។ ទោះបីជាបងស្រីខ្ញុំខំប្រកែកយ៉ាងណាក៏ដោយ ក៏កម្មាភិបាលខ្មែរក្រហមមិនព្រមជឿគាត់ដែរ ។ ភ្លាមនោះកម្មាភិបាលម្នាក់បានដកកាំបិតមកវះពោះបងស្រីខ្ញុំ ដើម្បីបង្ហាញថាការចោទប្រកាន់របស់ខ្លួនពិត ឬមិនពិត ។ នៅពេលវះពោះ ហើយក៏គ្មានឃើញបាយនៅក្នុងពោះរបស់បងស្រីខ្ញុំទេ ។ បងស្រីខ្ញុំក៏ដាច់ខ្យល់ស្លាប់ទៅ ។*


ឆាំង យុ

*លោកសាកនឹកគិតស្រមៃទៅមើលថារឿងនេះវាទៅជាយ៉ាងណាប្រសិនបើកើតឡើងចំពោះគ្រួសារលោក ហើយប្រហែលជាប្រជាពលរដ្ឋទូទៅមិនជឿថាមានអំពើបែបនេះអាចកើតឡើងផងក៏មិនដឹង ។*

*ដំបូងខ្ញុំខឹងណាស់ពីព្រោះហេតុការណ៍បែបនេះកើតឡើងមកលើប្រជាជនខ្មែរយើងគ្រប់ៗគ្នា ។ ខ្ញុំចង់ឲ្យអ្នកផងទាំងពួងទទួលយកការពិតនេះ ប៉ុន្តែពិតជាពិបាកណាស់ ។ ខ្ញុំចាប់ផ្តើមយល់ថាចាំបាច់ត្រូវតែធ្វើការសិក្សាស្រាវជ្រាវជាលក្ខណៈវិទ្យាសាស្ត្រដើម្បីឲ្យសាធារណជនទទួលស្គាល់បាននូវការពិត ។*

*មូលហេតុទីពីរ គឺដោយសារម្តាយរបស់ខ្ញុំ ។ ខ្ញុំគឺជាកូនពៅ ។ នៅក្នុងសង្គមខ្មែរ ឪពុកម្តាយតែងតែងបីបមថ្នាក់ថ្នមនិងទម្រើសកូនពៅណាស់ ។ ប៉ុន្តែករណីរូបខ្ញុំផ្ទាល់ គឺមិនដូច្នេះទេ ។ ពីព្រោះខ្ញុំធំឡើងដឹងក្តីនៅក្នុងពេលសង្គ្រាម ហើយឪពុកម្តាយខ្ញុំគិតតែអំពីបងៗរបស់ខ្ញុំតែប៉ុណ្ណោះ ។ ខ្ញុំមានអាយុ១៤ឆ្នាំនៅពេលដែលខ្មែរក្រហមចូលមកកាន់អំណាច ។ ខ្ញុំនៅផ្ទះតែម្នាក់ឯងគត់ ហើយពេលនោះក៏ត្រូវបានយោធាខ្មែរក្រហមដេញជម្លៀសទៅជាមួយមនុស្សទូទាំងទីក្រុងភ្នំពេញ ។ ខ្ញុំធ្វើដំណើរដោយដើរទទេអស់រយៈពេលជាងពីរអាទិត្យស្វែងរកម្តាយខ្ញុំនៅភូមិកំណើតរបស់គាត់ក្នុងខេត្តតាកែវ ។*

*៤ខែក្រោយមកគ្រួសារខ្ញុំក៏បានជួបជុំគ្នាវិញ ប៉ុន្តែត្រូវព្រាត់ប្រាសគ្នាម្តងទៀតដោយសារខ្មែរក្រហមបានជម្លៀសបន្តទៅខេត្តបាត់ដំបង ។ ការចងចាំដែលដក់ជាប់ក្នុងចិត្តខ្ញុំរហូតមក គឺថាបងស្រីខ្ញុំម្នាក់ទៀតមានផ្ទៃពោះ ហើយអត់អាហារហូបអស់រយៈពេលជាច្រើនខែ ។ ដូច្នេះ ខ្ញុំក៏ចុះ*

ទៅក្នុងស្រែរកបោចត្រកួននិងស្រូវមកឲ្យគាត់ហូប ។ នៅក្នុងរបបខ្មែរក្រហម ការធ្វើបែបនេះ គឺជាបទល្មើសមួយដោយហេតុថា សូម្បីតែត្រកួនហ្នឹងក៏ជាកម្មសិទ្ធរបស់អង្គការដែរ ។ ប្រសិនបើយើងបេះបោចដោយគ្មានការអនុញ្ញាត យើងច្បាស់ជាត្រូវចោទថាខ្មាំងរបស់បដិវត្តន៍ ហើយប្រាកដជាត្រូវផ្ដន្ទាទោសជាក់ជាមិនខាន ។

កម្មាភិបាលខ្មែរក្រហមប្រទះឃើញខ្ញុំនៅក្នុងស្រែបោចត្រកួន បោចស្រូវ រួចហើយក៏ចាប់ខ្ញុំតែម្ដង ។ ខ្មែរក្រហមវាយខ្ញុំនឹងពូថៅដៃ ហើយយកខ្ញុំទៅដាក់គុក ។ ខ្ញុំមិនដែលភ្លេចហេតុការណ៍ដ៏អាក្រក់នេះទេ ។ ខ្មែរក្រហមបានធ្វើទារុណកម្មខ្ញុំនៅចំពោះមុខម្ដាយខ្ញុំ ។ ម្ដាយខ្ញុំមិនហ៊ានស្រែកយំ ព្រោះនៅក្នុងរបបខ្មែរក្រហម ការស្រែកយំក៏ជាបទឧក្រិដ្ឋដែរ ។ គាត់ខំទប់ចិត្តមិនហ៊ានបង្ហូរទឹកភ្នែកនៅចំពោះមុខកម្មាភិបាលខ្មែរក្រហមដែលកំពុងតែវាយដំប្រំធាក់ខ្ញុំឥតត្រាប្រណីឡើយ ។

មូលហេតុចុងក្រោយខ្ញុំចង់បង្ហាញខ្មែរក្រហមឲ្យឃើញថាមនុស្សអាចរស់នៅនិងតស៊ូ ហើយមិនងាយស្លាប់ទេ ទោះជាស្ថិតក្នុងកាលៈទេសៈបែបណាក៏ដោយ ។ ខ្ញុំចង់ប្រាប់ទៅខ្មែរក្រហមថាខ្ញុំវិលត្រឡប់មកវិញហើយ ។ ខ្មែរក្រហមអាចវាយដំប្រំធាក់ខ្ញុំ ខ្មែរក្រហមអាចសម្លាប់បងស្រីខ្ញុំ ខ្មែរក្រហមអាចសម្លាប់ក្រុមគ្រួសារខ្ញុំ ប៉ុន្តែខ្មែរក្រហមមិនអាចបំផ្លាញឧត្ដមគតិនិងស្មារតីរបស់ខ្ញុំបានទេ ។ ខ្ញុំមិនមែនត្រឡប់មកដើម្បីសងសឹកខ្មែរក្រហមនោះឡើយ ប៉ុន្តែខ្ញុំត្រឡប់មកប្រាប់ខ្មែរក្រហមថា ក្នុងនាមជាមនុស្សជាតិ ខ្មែរក្រហមមិនអាចប្រាប់មនុស្សកុំឲ្យបញ្ចេញអារម្មណ៍មិនឲ្យស្រឡាញ់និងមិនឲ្យនៅជាមួយក្រុមគ្រួសារខ្លួនបានឡើយ ។

ដោយសារមូលហេតុទាំងនេះហើយបានជាខ្ញុំវិលត្រឡប់មកស្រុកខ្មែរដើម្បីធ្វើកិច្ចការនេះ ។ ខ្ញុំក៏ចង់ប្រាប់ទៅម្ដាយខ្ញុំថាឥឡូវនេះខ្ញុំរៀនចេះដឹង ខ្ញុំមាំទាំ ខ្ញុំសុខសប្បាយ ហើយខ្ញុំកំពុងតែធ្វើកិច្ចការនេះសម្រាប់គាត់ ហើយគាត់មិនគួរព្រួយបារម្ភអំពីខ្ញុំទៀតទេ ។ តាមការសិក្សាស្រាវជ្រាវរបស់ខ្ញុំកន្លងមក ខ្ញុំយល់ថាមិនមែនមានតែម្ដាយខ្ញុំទេដែលរងទុក្ខលំបាកវេទនា គឺនៅមានម្ដាយរាប់ម៉ឺននាក់ទៀតដែលមានកូនប្រុសដូចរូបខ្ញុំ ហើយជួបវាសនាប្រហាក់ប្រហែលនឹងខ្ញុំនេះដែរ ។

នៅឆ្នាំ១៩៧៨ កាលនោះខ្ញុំរស់នៅសហរដ្ឋអាមេរិក ខ្ញុំក៏ចាប់ផ្ដើមទាក់ទងជាមួយអ្នកសិក្សាជាន់ខ្ពស់អំពីបញ្ហាកម្ពុជា ។ ខ្ញុំសរសេរសំបុត្រទាក់ទងធម្មតាសួរអ្នកទាំងអស់នោះថាតើខ្ញុំអាចជួយធ្វើអ្វីបានខ្លះដល់ការស្រាវជ្រាវ? តើឲ្យខ្ញុំជួយយ៉ាងម៉េចខ្លះ? សូមឲ្យខ្ញុំដឹងផង ។ ខ្ញុំចេះនិយាយភាសាខ្មែរនិងភាសាអង់គ្លេស ហើយស្គាល់មនុស្សមួយចំនួននៅក្នុងសង្គមខ្មែរបច្ចុប្បន្ន ។ ការងារខ្ញុំចាប់ផ្ដើមដំបូង គឺយ៉ាងដូច្នេះ ។

***លោកបានរស់នៅសហរដ្ឋអាមេរិកអស់រយៈពេលជាច្រើនឆ្នាំ ។ តើនៅទីនោះ មានអ្វីខ្លះដែលធ្វើឲ្យលោកមានចំណាប់អារម្មណ៍?***

ខ្ញុំមានបងប្អូនម្នាក់ជាអតីតរដ្ឋមន្ត្រីក្រសួងពត៌មាននៅក្នុងរបបសាធារណរដ្ឋខ្មែរ(១៩៧០-៧៥) ។ កាលនោះផ្ទះខ្ញុំតែងតែមានអ្នកកាសែត(បរទេស)ចេញចូល ។ អ្នកកាសែតទាំងអស់ទាំងប្រុសទាំងស្រីសុទ្ធតែមានមាឌខ្ពស់ៗ និងមានសក់ពណ៌ទង់ដែង ។ ខ្ញុំមានបំណងចង់ក្លាយទៅជាអ្នកកាសែតណាស់ ហើយខ្ញុំចង់ចេះនិយាយភាសាអង់គ្លេសទៀតផង ។ ខ្ញុំធ្លាប់បានឮរឿងរ៉ាវលោកប្រធានាធិបតី កេណ្ណឺឌី ហើយឮអំពីសហរដ្ឋអាមេរិកនិងអ៊ីស្រាអែលក្នុងអំឡុងពេលសង្គ្រាម ។ ខ្ញុំឮថាអ៊ីស្រាអែលខ្លាំង ហើយក្លៀវក្លា ចំណែកអាមេរិកវិញមានអត្តចរិតឯករាជ្យមានចិត្តដាច់ខាតនិងក្លាហានណាស់ ។

ទាំងអស់នេះធ្វើឲ្យខ្ញុំមានសេចក្ដីប៉ងប្រាថ្នាមួយ ។ ខ្ញុំប៉ងប្រាថ្នាថា ថ្ងៃណាមួយខ្ញុំនឹងបានទៅរស់នៅសហរដ្ឋអាមេរិក ហើយអាចនិយាយភាសាអង់គ្លេសនិងទទួលបាននូវការអប់រំខ្ពស់ រួចហើយត្រឡប់មកស្រុកខ្មែរវិញ ។ នេះជាក្ដីប៉ងប្រាថ្នារបស់ក្មេងប្រុសម្នាក់តែប៉ុណ្ណោះ ប៉ុន្តែវាបានក្លាយទៅជាការពិត ។ មុខជំនាញរបស់ខ្ញុំដំបូង គឺរៀនផ្នែកសារពត៌មាន ប៉ុន្តែខ្ញុំបានផ្លាស់ប្ដូរមុខវិជ្ជាសិក្សានេះទៅសិក្សា“វិទ្យាសាស្ត្រនយោបាយ” វិញ ។ ខ្ញុំទៅនៅរដ្ឋតិចសាស់ ។ ខ្ញុំធ្វើការនៅសាលាក្រុងដាឡាស់ (កម្មវិធីការពារបទឧក្រិដ្ឋកម្ម) គឺមានចម្ងាយប្រមាណជា២ ឬ៣ ប្លុកតែប៉ុណ្ណោះពីកន្លែងដែលលោកប្រធានាធិបតី ចន កេណ្ណឺឌី ត្រូវបានធ្វើឃាត ។ លោកសាកគិតមើលតើគួរឲ្យជឿដែរឬទេ? ខ្ញុំទៅហាងលក់សៀវភៅ(កន្លែងធ្វើឃាតលោកកេណ្ណឌី) រៀង

រាល់ថ្ងៃទី២២ ខែវិច្ឆិកា ជាថ្ងៃដែលលោកប្រធានាធិបតី កេណ្ណឌី ទទួលមរណភាព ដើម្បីសរសេរអំពីការគិតរបស់ខ្ញុំចំពោះការធ្វើឃាតនេះ ។

***តើមជ្ឈមណ្ឌលឯកសារកម្ពុជាចាប់បដិសន្ធិប៉ុន្មានឆ្នាំមកហើយសូមលោករៀបរាប់អំពីសមិទ្ធផលដែលលោកសម្រេចបានកន្លងមក?***

យើងចាប់ផ្តើមការងារនេះតាំងពីឆ្នាំ១៩៩៥ ។ សមិទ្ធផលមួយដែលលេចធ្លោជាងគេនោះ គឺថាយើងបានធ្វើដំណើរទៅដល់ទីលំនៅជនរងគ្រោះនៅគ្រប់ខេត្តទូទាំងព្រះរាជាណាចក្រកម្ពុជា ទោះបីជាមិនបានគ្រប់ៗគ្នាក៏ដោយ ។ គ្រាន់តែបានទៅដល់ផ្ទះគាត់ជួបនិយាយជាមួយគាត់ នេះហើយជាសមិទ្ធផលដ៏ពិសិដ្ឋរបស់យើង ។

***តើលោកប្រមែប្រមូលបានឯកសារអ្វីខ្លះ?***

តាមតួលេខត្រួសៗ យើងមានឯកសារប្រហែលជា៦សែនសន្លឹក ព្រមទាំងរូបថតចំនួនជាង៣ម៉ឺននិងឯកសារហ្វីលកុនជាច្រើនទៀត ។ ប៉ុន្តែយើងមិនបានធ្វើវិភាគអ្វីទាំងអស់ គឺយើងរក្សាទិន្នន័យដើមរបស់ឯកសារសម្រាប់សាធារណជនទូទៅប្រើប្រាស់ ។ ខ្ញុំជាអ្នកសិក្សាស្រាវជ្រាវធម្មតា ហើយគ្រប់អ្វីៗដែលយើងមាន គឺទិន្នន័យដើមសម្រាប់មនុស្សគ្រប់រូបប្រើប្រាស់ ។ យើងចេញទៅតាមខេត្តយ៉ាងហោចណាស់៣ដងក្នុងមួយខែដើម្បីទៅស្តាប់អ្នកស្រុកអ្នកភូមិនិយាយអំពីរឿងរ៉ាវរបស់គាត់នៅក្នុងសម័យខ្មែរក្រហម ហើយរឿងរ៉ាវទាំងអស់នេះក៏ជាឯកសារដែរ ។ យើងឲ្យនិយមន័យទូលំទូលាយណាស់ទៅលើពាក្យថា “ឯកសារ” ពោលឯកសារគឺចាប់តាំងពីចំនួនមនុស្សស្លាប់ រណ្តៅសាកសព វត្ថុសម្ភារផ្សេងៗជាដើម ។

ទាំងអស់នេះមានន័យថាជាការព្យាយាមថែរក្សាប្រវត្តិ-សាស្ត្រឲ្យនៅរស់ជានិច្ច ដើម្បីឲ្យកូនខ្មែរជំនាន់ក្រោយស្វែងយល់ ។ ការងារនេះធ្វើឡើង ដើម្បីផ្តល់ជាការបង្ហាញផ្លូវ ឬទិសដៅសម្រាប់ក្មេងៗជំនាន់ក្រោយៗធ្វើការស្រាវជ្រាវបន្តទៅទៀត ។

***តើឯកសារទាំងអស់នេះមានចម្លងចេញទៅខាងក្រៅទេ? ហើយបើមាននៅខាងក្រៅតើនៅទីណាអាចរកបាន?***

បាទ, មាន ។ យើងមានផ្សព្វផ្សាយឯកសារទាំងនេះនៅកន្លែងជាច្រើននៅលើពិភពលោក ប៉ុន្តែយើងធ្វើគ្រប់យ៉ាងដើម្បីរក្សាឯកសារដើមឲ្យបាននៅក្នុងស្រុករបស់យើង ។ យើងដាក់ឯកសារនៅក្នុងទូដែកការពារអគ្គីភ័យនិងប្រកបដោយសុវត្ថិភាពនិងនៅកន្លែងផ្សេងៗពីគ្នា...។ យើងមានឯកសារនៅក្នុងថាសផ្ទុកឯកសារនៅជុំវិញពិភពលោក មានតាំងពីសហរដ្ឋអាមេរិក អឺរ៉ុប និងស្ថានទូតជាច្រើនផ្សេងទៀត ។

***ឃើញថាលោកមានការរៀបចំទុកដាក់ត្រឹមត្រូវខ្លាចមានបញ្ហាសន្តិសុខចំពោះរូបលោកផ្ទាល់ ក៏ដូចជាបុគ្គលិកទាំងអស់ព្រមទាំងឯកសារតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ តើកន្លងមកលោកធ្លាប់បានទទួលការគំរាមកំហែងដែរឬទេ? បើធ្លាប់ តើការគំរាមកំហែងមានលក្ខណៈបែបណាដែរ?***

ខ្ញុំមិនជឿក្រុមហ៊ុនធានារ៉ាប់រងជីវិតទេ ។ ខ្ញុំជឿលើព្រះ ។ មានតែព្រះទេដែលអាចការពារយើងបាន ។ ក៏ប៉ុន្តែខ្ញុំសម្រេចចិត្តថាប្រសិនបើខ្ញុំក្លាយជាមុខសញ្ញារបស់ខ្មែរក្រហមខ្ញុំសុខចិត្តលះបង់គ្រប់បែបយ៉ាងដើម្បីការពិតនិងយុត្តិធម៌ ទោះបីជាត្រូវយកជីវិតខ្ញុំទៅប្តូរក៏ដោយ ។

ប៉ុន្តែមិនចាំបាច់មានអ្នកណាភ័យខ្លាចអំពីការស្រាវជ្រាវនៅទីនេះទេ ។ គម្រោងការនេះ គឺសម្រាប់មនុស្សជាតិទូទៅនិងប្រជាជនកម្ពុជា ។ យើងមិនមានបំណងដាក់ទោសដល់អ្នកណាម្នាក់ឡើយ ។ ប៉ុន្តែប្រសិនបើយើងមានអារម្មណ៍ថាមិនមានសន្តិសុខចំពោះការស្រាវជ្រាវ យើងនឹងទូរស័ព្ទទៅក្រសួងមហាផ្ទៃ ឬក៏តាមវិធីម្យ៉ាងទៀត យើងជួលសន្តិសុខឯកជនឲ្យមើលការខុសត្រូវក៏បានដែរ ។ ប៉ុន្តែរូបខ្ញុំផ្ទាល់ ខ្ញុំទុកឲ្យព្រះជាអ្នកថែរក្សាទៅចុះ ។

***មកដល់សព្វថ្ងៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលជំនួយផ្នែកហិរញ្ញវត្ថុប៉ុន្មាន ហើយអ្នកណាជាអ្នកផ្តល់ជំនួយធំជាងគេ?***

ឲ្យតែអ្នកគាំទ្រយើងមិនថាឲ្យអ្វីជាអ្វីទេ គឺសុទ្ធតែមានតម្លៃស្មើៗគ្នា ។ ប្រទេសសំខាន់ៗដែលគាំទ្រដល់យើងមានសហរដ្ឋអាមេរិក ហូឡង់ ស៊ុយអែដ ចក្រភពអង់គ្លេស ន័រវេ ដាណឺម៉ាក ញ៉ូសេឡែន ជប៉ុន និងកាណាដា ។

ក្នុងចំណោមប្រទេសអាស៊ី មានតែប្រទេសតែមួយគត់

ដែលផ្តល់ជំនួយជាសម្ភារ គឺប្រទេសជប៉ុន ។ ខ្ញុំហាក់ដូចជាស្ងួតចិត្តបន្តិចដែរ... ។ នេះមិនមែនជារឿងរបស់អាស៊ី អឺរ៉ុប ឬអាមេរិកអ្វីទេ ប៉ុន្តែវាជារឿងរបស់មនុស្សគ្រប់ៗគ្នា ។ ការរំលោភសិទ្ធិមនុស្សប្រហែលជាកំពុងតែកើតឡើងនៅប្រទេសភាគច្រើនដែលមានបញ្ហា ហើយយើងគួរតែចាប់អារម្មណ៍ឲ្យបានខ្លាំងបន្តិចក្នុងរឿងនេះ ។ នេះជារឿងយុត្តិធម៌ ជារឿងអនាគត ជារឿងត្រូវតាំងចិត្តដើម្បីធ្វើឲ្យប្រសើរឡើងនូវសិទ្ធិមនុស្ស និងសង្គមមនុស្ស ។

***តើកិច្ចខិតខំប្រឹងប្រែងរបស់លោកមានធ្លាប់មានបញ្ហារឿងខ្វះថវិកាទេ ហើយប្រសិនជាខ្វះមែន ហើយលោកស្រាប់តែទទួលបានមកទៀតតើលោកនឹងយកទៅធ្វើកិច្ចការអ្វីផ្សេងទៀតទេ?***

កិច្ចការរបស់យើង គឺផ្អែកសំខាន់លើការងារស្ម័គ្រចិត្ត និងការតាំងចិត្ត ។ បុគ្គលិកទាំងអស់ រួមទាំងរូបខ្ញុំផង គឺចាប់ផ្តើមធ្វើកិច្ចការនេះដំបូងជាអ្នកស្ម័គ្រចិត្តដោយគ្មានប្រាក់ខែទេ ។ ប៉ុន្តែជាការពិតណាស់ យើងត្រូវការថវិកាដើម្បីដំណើរការគម្រោងការផ្សេងៗរបស់យើង ។ ដូច្នេះយើងបានស្នើថវិកាដល់បណ្តាប្រទេសមួយចំនួន ប៉ុន្តែមិនមែនលន់តួ ឬបិណ្ឌបាត្រសុំលុយនោះទេ ។ យើងស្នើឲ្យមានការតាំងចិត្តជាកិច្ចសហប្រតិបត្តិការ យើងមិនមែនសម្របតាមទង្វើដែលមិនយុត្តិធម៌នោះទេ ។ យើងមិនធ្វើឲ្យខូចដល់ការសិក្សាស្រាវជ្រាវរកយុត្តិធម៌ ។ យើងមិនធ្វើអាជីវកម្មទេ ពីព្រោះនេះមិនមែនជាទីផ្សារ ប៉ុន្តែនេះជាសេរីភាព ។ យើងត្រូវការថវិកា ប៉ុន្តែថវិកាមិនអាចទិញអ្វីគ្រប់យ៉ាងបានទេ ។

ចំណុចមួយទៀតថា ថវិកាដែលយើងទទួល គឺបានមកពីថវិការបស់អ្នកបង់ពន្ធប្រាក់ជូនរដ្ឋ ហើយយើងមានកិត្តិយសណាស់ដែលបានទទួលថវិកាបែបនេះ ។ យើងមានការទទួលខុសត្រូវ សន្សំកាក់ល្អិត និងចាយត្បិតត្បៀតបំផុត ។ ប្រសិនបើយើងមានថវិកាថែមទៀតនឹងមានន័យថាយើងនឹងទទួលយកអ្នកមានអាជីពច្បាស់លាស់មួយចំនួនទៀតដែលអាចធ្វើឲ្យការងារចម្បងរបស់យើងដែលអាចទៅមុខបានកាន់តែឆាប់រហ័ស ។ យើងក៏ចង់សាងសង់សារមន្ទីរមួយ ចង់ទទួលថវិកាបន្ថែមទៀតដើម្បីចងក្រងជាសៀវភៅសិក្សានៅតាមសាលា (រៀបរាប់ពីប្រវត្តិសាស្ត្រក្នុងសម័យខ្មែរក្រហម) ។ យើងចង់និយាយទៅកាន់អតីតជនដែលគ្រប់ៗរូប ឬស្តាប់អ្វីដែលគេនិយាយ ។ យើងក៏ចង់ថតកិច្ចសម្ភាសន៍របស់យើងដាក់ក្នុងម៉ាស៊ីនថតវីដេអូដែរ ។

គំនិតខ្ញុំចង់និយាយថា ប្រសិនបើហេតុការណ៍សម្លាប់រង្គាលទាំងនេះបានកើតឡើងមែន វាច្បាស់ជាអាចកើតឡើងនៅកន្លែងផ្សេងៗទៀតនៅលើពិភពលោកយើងនេះ ។ កាលពីខ្ញុំនៅក្មេង ខ្ញុំមិនដែលបានឮថាមានការសម្លាប់រង្គាលជនជាតិជ្វីហ្វទេ ។ នឹកគិតមើលថា កាលនោះខ្ញុំមានអាយុ៩ឆ្នាំមុនពេលខ្មែរក្រហមឡើងមកកាន់អំណាចហើយប្រសិនបើខ្ញុំបានរៀនសូត្រអំពីហាយនភាពនៅសាលារៀនប្រហែលជាយើងអាចជួយទប់ស្កាត់ (អំពើឃោរឃៅ) បានខ្លះជាមិនខាន ។ ចំណេះវិជ្ជា គឺជាអាវុធដ៏ខ្លាំងក្លាហើយប្រជាជនគួរតែជ្រួតជ្រាបអ្វីដែលបានកើតឡើងរួចមកហើយ ។

***មានការប្រមើលមើលជាច្រើនឆ្នាំមកហើយថា ក្រោយពីវៀតណាមចូលមកភ្នំពេញនៅឆ្នាំ១៩៧៩ វៀតណាមបានយកឯកសារត្រឡប់ទៅទីក្រុងហាណូយវិញអស់ហើយ ។ តើមជ្ឈ-មណ្ឌលឯកសារកម្ពុជាមានបានទទួលកិច្ចសហប្រតិបត្តិការពីសំណាក់រដ្ឋាភិបាលវៀតណាមដែរ ឬទេ?***

ខ្ញុំមិនដឹងថាតើនៅហាណូយមានឯកសារច្រើនប៉ុណ្ណាទេ ។ យើងមានឯកសារមួយចំនួនតូចប៉ុណ្ណោះនៅក្នុងដៃដែលខ្ញុំគិតថាមានការទាក់ទងនឹងតុលាការឆ្នាំ១៩៧៩ ហើយអ្នកជំនាញការវៀតណាមក៏ធ្លាប់បានប្រមែប្រមូលឯកសារទាំងនោះដែរ ។ ប្រហែល ជាឯកសារនោះត្រូវបានប្រមូលយកទៅហាណូយនៅឆ្នាំ ១៩៧៩ ។ ប៉ុន្តែនៅមិនទាន់ច្បាស់នៅឡើយថាតើខាងហាណូយមាននៅសល់ឯកសារប៉ុន្មានទេ ។ ថ្មីៗនេះវៀតណាមប្រកាសថានឹងបើកចំហបណ្ណសាររបស់ខ្លួនសម្រាប់តុលាការខ្មែរក្រហម ។

***តាមគំនិតលោកផ្ទាល់តើលោកចង់ឃើញអ្វីចេញពីការកាត់ក្តីដែលត្រូវបានស្នើឡើងនេះ?***

ចង់បានការពិតនិងឲ្យផ្តល់ចម្លើយដល់សំណួរដែលជនរងគ្រោះបានចោទឡើងអស់រយៈពេលជាង២០ឆ្នាំមកហើយ ។ ខ្ញុំក៏នៅសង្ឃឹមទៀតថាយើងគ្រប់ៗរូបត្រូវអនុញ្ញាតឲ្យចូលរួមបាន

ពេញលេញដូចៗគ្នាដើម្បីកុំឲ្យឃើញថាមានតែអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាជាអ្នកចូលរួម ។ ប្រជាជនកម្ពុជាខ្លួនឯងផ្ទាល់ក៏គួរមានតួនាទីស្មើៗគ្នាដែរនៅក្នុងដំណើរការកាត់ក្តីនេះ ។ ទោះបីជាយើងមិនមានសិទ្ធិផ្នែកច្បាប់ក៏ពិតមែន តែយើងមានសិទ្ធិស៊ីវិលក្នុងការមើលនូវអ្វីដែលយើងចង់ដឹងហេតុអ្វីបានជាខ្មែរក្រហមសម្លាប់ក្រុមគ្រួសាររបស់យើង? ហេតុអ្វីបានជាបងស្រីខ្ញុំត្រូវខ្មែរក្រហមសម្លាប់? ហេតុអ្វីបានជាខ្មែរក្រហមធ្វើទារុណកម្មខ្ញុំដែលជាកូនក្មេងដែលគ្រាន់តែទៅបោចត្រកួនពីស្រែ? តើអ្នកណាជាអ្នកចេញបញ្ជាឲ្យប្រព្រឹត្តអំពើយ៉ាងដូច្នេះ? ដឹងរាល់បញ្ហាទាំងអស់នេះពិតជាសំខាន់ដូចជាដឹងអ្វីដែលបានកើតឡើង ហើយខ្ញុំគិតថាការដឹងដំណើរដើមទងទាំងនេះនឹងធ្វើឲ្យយើងមានអារម្មណ៍ធូរស្បើយមិនខាន ។

នៅតាមដងផ្លូវនៅទូទាំងប្រទេសកម្ពុជាសំណួរបែបនេះ គឺមិនចេះខ្វះទេ ទៅដល់ណាក៏មានលេចឮដែរ ។ ប៉ុន្តែតុលាការនឹងគ្មានន័យអ្វីទាំងអស់ប្រសិនបើគ្មានកម្មវិធីគាំទ្រដែលមានប្រជាជនចូលរួមផងនោះ ។ ខ្ញុំបានលើកបញ្ហានេះទៅពិភាក្សាជាមួយព្រះមហាក្សត្រថាប្រជាជនគួរតែមានតួនាទីចូលរួមក្នុងដំណើរតុលាការនេះ ហើយខ្ញុំគិត ព្រះអង្គក៏ប្រទានសារនេះទៅកាន់សម្តេចក្រុមព្រះនរោត្តមរណឫទ្ធិ ដើម្បីទុកជាព្រះរាជតម្រិះ ។

**តើលោកគិតយ៉ាងដូចម្តេចចំពោះលទ្ធផលដែលចេញពីការជំនុំជម្រះក្តីនេះ?**

វាអាស្រ័យទៅនឹងកម្មវិធីទ្រទ្រង់តុលាការ ។ ប្រសិនបើឲ្យតុលាការធ្វើដំណើរទៅម្នាក់ឯងដោយគ្មានកម្មវិធីមួយគាំទ្រលទ្ធផលនឹងពិបាកទទួលយកបានណាស់ ។ ចំនួនមនុស្សដែលត្រូវកាត់ទោសមិនមែនជាបញ្ហាប៉ុន្មានទេតែដែលសំខាន់បំផុតគឺដំណើរការតុលាការខ្លួនឯង និងអ្វីដែលតុលាការលាតត្រដាងចេញមក ទើបជាការសំខាន់ ។

តុលាការក៏ត្រូវធានាឲ្យបានថា ការជំនុំជម្រះនេះពិតជាការជំនុំជម្រះដ៏យុត្តិធម៌មួយ ។ មនុស្សដូចជា អៀង សារី និង នួន ជា គួរតែមានមេធាវីខ្លាំងៗ ។ លទ្ធផលនៃតុលាការអាស្រ័យទៅនឹងការចូលរួមពីសំណាក់សាធារណជន ហើយកម្មវិធីនេះផ្ទាល់គួរតែចាប់ផ្តើមដំណើរការពីឥឡូវនេះ ។

**ខបមាថាដំណើរការជំនុំជម្រះក្តីកំពុងតែចាប់ផ្តើមហើយ តាមលោកគិតតើមជ្ឈមណ្ឌលមានទំនាក់ទំនងបែបណាជាមួយនឹងព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តី?**

យើងនឹងបម្រើប្រយោជន៍ឲ្យទាំងសងខាង ទាំងមេធាវីការពារក្តីនិងព្រះរាជអាជ្ញា ។ អ្នកទាំងពីរអាចប្រើប្រាស់ឯកសាររបស់យើង ពីព្រោះឯកសារដែលយើងមានមិនទាន់វិភាគនៅឡើយទេ ពោលគឺជាទិន្នន័យដើមផ្នែកប្រវត្តិសាស្ត្រ ។ យើងសង្ឃឹមថាប្រទេសមួយចំនួននឹងជួយផ្តល់ផ្តល់ជាថវិកាសម្រាប់ពង្រីកការប្រមូលទិន្នន័យយើងឲ្យបានកាន់តែច្រើនថែមទៀត ។

**មានពុទ្ធិយាយទាក់ទងនឹងពាក្យ«ភ័ស្តុតាងជាក់ស្តែងដែលមិនអាចប្រកែកបាន» ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាប្រមែប្រមូលបាន ។ តើលោកជឿជាក់ថាឯកសារទាំងអស់នេះអាចប្រើប្រាស់សម្រាប់ចោទប្រកាន់ខ្មែរក្រហមបានទេ? ប្រសិនបើបាន តើឯកសារនោះមានអ្វីខ្លះ?**

ចំណុចទី១ យើងមិនដែលប្រើពាក្យថា«ភ័ស្តុតាង»ទេ យើងប្រើពាក្យថា«ពត៌មាន» ហើយយើងទទួលបានពត៌មានទាំងអស់នេះចាប់តាំងពីប្រធានភូមិរហូតដល់ ប៉ុល ពត ។ ព្រះរាជអាជ្ញា និងមេធាវីការពារចុងចោទគ្រាន់តែសម្រេចថា អ្វីជាភ័ស្តុតាងអ្វីមិនមែនជាភ័ស្តុតាងប៉ុណ្ណោះជាការស្រេច ។ បានន័យថាព្រះរាជអាជ្ញានិងចុងចោទមិនចាំបាច់ចាប់ផ្តើមធ្វើការលើក្រដាសសស្អាតមួយសន្លឹកនោះទេ ។ ផ្ទុយទៅវិញមេធាវីអាចចាប់ផ្តើមធ្វើការងាររបស់ខ្លួនជាមួយនឹងឯកសារដែលមានសព្វថ្ងៃរហូតដល់៦សែនសន្លឹក រួចទៅពិនិត្យរណ្តៅសាកសពចំនួន១៩៤៤០ មន្ទីរសន្តិសុខ ១៦៧ និងបូជនីយដ្ឋាន ៧៧កន្លែង ។

**តើលោកយល់ថាការជំនុំជម្រះក្តីនេះអាចមានសារសំខាន់ដូចជាការរៀបរាប់អំពីអ្វីដែលបានកើតឡើងនៅអាហ្វ្រិកខាងត្បូង ពោលគឺគណៈកម្មការស្វែងរកការពិតនិងផ្សះផ្សាដែរឬទេ?**

ខ្ញុំហាក់មានបញ្ហាបន្តិចនៅពេលនិយាយដល់ពាក្យថា«គណៈកម្មការស្វែងរកការពិត» «បង្រួបបង្រួម» និង «ផ្សះផ្សា» ។ ប្រហែលជាខ្ញុំសិក្សាមិនបានជ្រៅជ្រះលើបញ្ហានេះក៏ថាបាន ។ ខ្ញុំមិនហ៊ានរហូតដល់ប្រើពាក្យនេះទេ ។ ប៉ុន្តែចូលក្រឡេកមើលអ្វី

ដែលប្រជាជនបានធ្វើតាំងពីឆ្នាំ១៩៧៩មក ។ ប្រជាជនបានសង់ជាស្តូប សង់បូជនីយដ្ឋាន សរសេរចម្រៀង...។ ជនរងគ្រោះសម័យខ្មែរក្រហមគ្រប់ៗរូបសុទ្ធតែមានរឿងផ្ទាល់ៗខ្លួន ។ មានប្រជាជនជាងមួយលាននាក់បានចុះហត្ថលេខាញត្តិមួយដែលរៀបរាប់ប្រាប់រដ្ឋាភិបាល និងសាលកលោកនូវអ្វីដែលបានកើតឡើងចំពោះខ្លួនក្រោមរបបខ្មែរក្រហម ។

ខ្ញុំច្បាស់ក្នុងចិត្តណាស់ថាប្រជាជន អ្នកស្រុកអ្នកភូមិបានលៃលកដោះស្រាយបញ្ហាប៉ះទង្គិចខាងអារម្មណ៍របស់គាត់តាមរយៈការលើកគណៈកម្មការស្វែងរកការពិតនៅក្នុងប្រទេសកម្ពុជាមកនិយាយ ។ នៅពេលប្រជាជននិយាយអំពីអ្វីដែលខ្លួនបានទទួលរងកាលពីអតីតកាល មានន័យថាគាត់កំពុងតែធ្វើជាគណៈកម្មការស្វែងរកការពិតស្រេចបាត់ទៅហើយ ។ កិច្ចប្រឹងប្រែងបែបនេះមានលក្ខណៈគ្រប់គ្រាន់សម្រាប់ដំណើរការផ្សះផ្សាជាតិ ។ មនុស្សម្នានាំគ្នាយកចង្ហាន់ឧទ្ទិសដល់បុព្វការីជនបួងសួងសំពះហើយនិយាយជជែកគ្នាអំពីរឿងនេះ គឺពិតជាគណៈកម្មការស្វែងរកការពិតជាស្រេច ។ ប្រជាជនដែលសរសេររឿងខ្លួនឯងចំពោះខ្ញុំយល់ថា នេះជាគណៈកម្មការស្វែងរកការពិត ។

ប្រហែលជាអាចឲ្យមានវេទិកាសាធារណៈទូទាំងប្រទេសឲ្យប្រជាជនឡើងមកជួបជុំគ្នាជារៀងរាល់ខែនៅគ្រប់ភូមិ ហើយនិយាយពីរឿងនេះ ។ ប្រជាជនអាចមើលទូរទស្សន៍ដែលចាក់ផ្សាយពីដំណើរការប្រព្រឹត្តទៅរបស់អង្គតុលាការ ឬមើលខ្សែភាពយន្តឯកសារអំពីរឿងខ្មែរក្រហម ។ ពីមុនយើងមិនអាចធ្វើដូច្នេះបាន ប៉ុន្តែឥឡូវកម្ពុជាជាប្រទេសសេរី ។ ដូច្នេះតាមការជាក់ស្តែងចំពោះខ្ញុំយល់ថា គណៈកម្មការស្វែងរកការពិតកំពុងតែប្រព្រឹត្តទៅហើយនៅក្នុងប្រទេសកម្ពុជា ។

***ហេតុអ្វីបានជាមជ្ឈមណ្ឌលឯកសារកម្ពុជាមានសារសំខាន់សម្រាប់ប្រទេសកម្ពុជា ហើយអ្វីទៅជាគម្រោងការយូរអង្វែងសម្រាប់អង្គការនេះ?***

យើងកំពុងតែសហការធ្វើការងារជាមួយសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងនៅទីក្រុងភ្នំពេញ ។ យើងមានដីមួយឡូតិ៍ដែលប្រគល់ឲ្យដោយរាជរដ្ឋាភិបាលកម្ពុជា យើងសង្ឃឹមថានឹងសាងសង់មជ្ឈមណ្ឌលជាអចិន្ត្រៃយ៍មួយដោយចូលរួមជាមួយសារមន្ទីរទួលស្លែងដើម្បីបង្កើតជាការតាំងពិព័រណ៍មានចរិតអប់រំ មិនមែនជាការឃោសនា ប៉ុន្តែជាប្រវត្តិសាស្ត្រផ្លូវការទាក់ទងនឹងអំពើប្រល័យពូជសាសន៍ ។

ខ្ញុំគិតថាកូនខ្មែរជំនាន់ក្រោយមានសិទ្ធិដឹងអំពីប្រវត្តិសាស្ត្ររបស់ខ្លួន ហើយទន្ទឹមនេះរដ្ឋាភិបាលមានកាតព្វកិច្ចផ្តល់ការពិតទាំងស្រុងដល់សិស្សានុសិស្សទាំងអស់ ។ ឧទាហរណ៍ជាក់ស្តែងសៀវភៅប្រវត្តិសាស្ត្រថ្នាក់ទី៩ (សម្រាប់សិស្សានុសិស្ស អាយុពី១៦ - ១៧ឆ្នាំ) មាននិយាយរឿងខ្មែរក្រហមតែ១កថាខណ្ឌប៉ុណ្ណោះ ។

មជ្ឈមណ្ឌលដែលបានលើកស្នើឡើងនេះក៏នឹងក្លាយជាមជ្ឈមណ្ឌលឯកសារកម្ពុជាអចិន្ត្រៃយ៍ដែលមនុស្សម្នាមកពីគ្រប់មជ្ឈដ្ឋានអាចចូលមកធ្វើការសិក្សាស្រាវជ្រាវនិងសរសេរជានិក្ខេបបទ ឬសៀវភៅផ្សេងៗ ។ មិនតែប៉ុណ្ណោះយើងក៏ចង់ធ្វើការងារយ៉ាងជិតស្និទ្ធជាមួយមហាវិទ្យាល័យប្រវត្តិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញប្រយោជន៍ដើម្បីជំរុញឲ្យនិស្សិតសិក្សាពីប្រធានបទនេះ ។ យើងប្រមើលមើលថា១៥ឆ្នាំខាងមុខទៀតមជ្ឈមណ្ឌលឯកសារកម្ពុជានឹងក្លាយជាផ្នែកមួយនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញមិនមែនសម្រាប់តែប្រមែប្រមូលព័ត៌មានទេ ប៉ុន្តែយើងនឹងផលិតជាសៀវភៅដើម្បីផ្តល់ជាព័ត៌មានដល់ប្រជាជននៅលើពិភពលោកថែមទៀតផង ។

## ពាក្យស្លោកខ្មែរក្រហម

◆ បុគ្គលម្នាក់ៗ អង្គភាពនីមួយៗ ប្រទេសទាំងមូលត្រូវរៀនសូត្រឱ្យបានល្អតាមគំរូវីរភាពបដិវត្តដ៏ខ្ពង់ខ្ពស់របស់សមរភូមិមុខ។

◆ សមរភូមិមុខ ជាកំពែងថែបការពារឯករាជ្យ អធិបតេយ្យភាព បូរណភាពដែនដី កិត្តិយសជាតិ និងពូជសាសន៍កម្ពុជា។

◆ សមរភូមិមុខ ជាតំណាងដ៏ឆ្នើមនៃមោទកភាពបដិវត្តរបស់ប្រជាជាតិ និងប្រជាជនកម្ពុជាទាំងមូល។

(ឯកសារ TSL៥៦៨០)



# ◆ការពិភាក្សារវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ: តើកិច្ចព្រមព្រៀងនៅលើការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម កើតឡើងដោយរបៀបណា?





**(តចប់)** នៅទីបញ្ចប់ នៅពេលដែលច្បាប់ត្រូវបានអនុម័តដោយសភាជាតិកាលពីថ្ងៃទី២ ខែមករា ឆ្នាំ២០០១ ច្បាប់នេះមានការខុសប្លែកមួយចំនួនពីអ្វីដែលបានពិភាក្សានៅក្នុងអំឡុងពេលនៃបេសកកម្មរបស់លោក ហេន កូរ៉េល កាលពីខែកក្កដា ។ ចំណុចសំខាន់គឺថាច្បាប់នេះមិនបានបញ្ជាក់ថា ការលើកលែងទោសកាលពីមុននឹងត្រូវបំភ្លេចចោលចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាមនិងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ជាថ្មីម្តងទៀតបញ្ហានេះ គឺថាតើ អៀង សារី គួរនឹងត្រូវយកមកកាត់ទោសឬទេ? ។ អៀង សារី គឺជាមនុស្សតែម្នាក់គត់ ដែលបានទទួលការលើកលែងទោសដែលឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រ ។ ជាការច្បាស់ណាស់ថា គ្មានការគិតឲ្យមានលើកលែងទោសក្រៅពីនេះទៀតទេ ប៉ុន្តែចុះអំពីករណី អៀង សារី?

លោក ហេន កូរ៉េល បានស្នើឡើងកាលពីខែកក្កដាថា ប្រយោគមួយគួរតែត្រូវបន្ថែមនៅក្នុងមាត្រាដែលពាក់ព័ន្ធពោលគឺមាត្រាទី៤០ នៅក្នុងច្បាប់តុលាការនេះ៖ «ការលើកលែងទោសដែលត្រូវបានផ្តល់ឲ្យទណ្ឌិតណាមួយដែលស្ថិតនៅក្នុងដែនយុត្តាធិការរបស់អង្គជំនុំជម្រះនេះនឹងមិនរារាំងដល់ការកាត់សេចក្តីឡើយ» ។ សេចក្តីស្នើនេះដាក់ច្បាស់ណាស់គឺនិយាយយោងដល់ករណី អៀង សារី ។ នៅក្នុងកំណត់សេចក្តីដោយឡែកមួយ លោក ហេន កូរ៉េល បានសរសេរថាអង្គការសហប្រជាជាតិបាន «រៀបចំពិភាក្សាបញ្ហានេះនៅពេលដែលយើងសម្រេចអនុស្សរណៈនៃការយោគយល់គ្នារួចស្រេចបាច់សិន» ។ ការនេះត្រូវបានអ្នកចរចាខាងកម្ពុជាហៅថាជាការបើកឲ្យមានការពិភាក្សាដេញដោលគ្នាក្រោយពីច្បាប់ត្រូវបានអនុម័តរួចហើយ ហើយប្រយោគដែលស្នើដោយលោក ហេន កូរ៉េល មិនត្រូវបានបញ្ចូលនៅក្នុងច្បាប់ដែលអនុម័តដោយសភាជាតិឡើយ ។

មានសំបុត្រមួយច្បាប់ពីលោក ហេន កូរ៉េល នៅថ្ងៃទី៩ ខែមករា ផ្ញើទៅកាន់ឯកឧត្តម សុខ អាន សម្តែងការមិនពេញចិត្តចំពោះការវិវត្តមួយចំនួន ។ សេចក្តីព្រាងនៃអនុស្សរណៈនៃការយោគយល់គ្នាបានបញ្ជាក់ច្បាស់ថា ការលើកលែងទោសចំពោះបុគ្គលណាក៏ដោយគឺមិនអាចរារាំងដល់ការកាត់សេចក្តីទេ ។ លោក កូរ៉េល ក៏បានសង្កត់ធ្ងន់ថានេះគឺជាបញ្ហាចម្បងនៅក្នុងការពិភាក្សានៅក្នុងខែកក្កដា ។ យោបល់របស់ឯកឧត្តម សុខ អាន ចំពោះប្រព័ន្ធឃោសនាគឺថានេះជាបញ្ហាដែលនឹងត្រូវបញ្ជាក់ច្បាស់នៅក្នុងកិច្ចប្រជុំនាពេលខាងមុខជាមួយនឹងលោក ហេន កូរ៉េល ។

សភាជាតិ និងបន្ទាប់មកព្រឹទ្ធសភាបានយល់ព្រមឲ្យមានសាលាជំនុំជម្រះពិសេសនៅក្នុងប្រព័ន្ធតុលាការកម្ពុជាដែលមានស្រាប់ដោយមានការចូលរួមពីសំណាក់ចៅក្រមនិងសហព្រះរាជអាជ្ញាដែលជ្រើសតាំងដោយអង្គការសហប្រជាជាតិ ។ ភាគច្រើននៃអង្គចៅក្រម គឺជាជនជាតិកម្ពុជា និងជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ហើយលោកអគ្គលេខាធិការអង្គការសហ-ប្រជាជាតិផ្តល់យោបល់ថា ចៅក្រមនិងព្រះរាជអាជ្ញាបរទេសក៏នឹងត្រូវជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានេះដែរ ។

ឯកឧត្តម សុខ អាន មន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជាបានធ្វើវិភាគទៅលើការសម្របសម្រួលនានាដែលត្រូវបានធ្វើឡើងជាមួយអង្គការសហប្រជាជាតិ នៅពេលដែលឯកឧត្តមដាក់សេចក្តីព្រាងច្បាប់ចុងក្រោយជូនសភាជាតិនាថ្ងៃទី២៩ ខែធ្នូ ឆ្នាំ

២០០០ ។ ការសម្របសម្រួលទីមួយ គឺថាចៅក្រមបរទេសអាចចូលរួមនៅក្នុងតុលាការជាតិ ប៉ុន្តែវិសាមញ្ញ ។ ការសម្របសម្រួលទីពីរទាក់ទងនឹងបញ្ហាថាតើគួរឲ្យមានចៅក្រមភាគច្រើនជាជនជាតិខ្មែរ ឬជនបរទេស ។ ដំណោះស្រាយ គឺថាភាគច្រើនជាជនជាតិខ្មែរ ប៉ុន្តែថានឹងមាន"មតិភាគតិចដែលអាចរារាំងដល់ក្តីសម្រេច" ។ ការសម្របសម្រួលទីបីគឺស្តីអំពីការកាត់សេចក្តីៈ នឹងមានសហព្រះរាជអាជ្ញាពីររូប មួយរូបជាជនជាតិខ្មែរនិងមួយរូបទៀតជាបរទេស ។ ការសម្របសម្រួលមួយទៀត គឺទាក់ទងនឹងបញ្ហាថាតើត្រូវដោះស្រាយការខ្វែងគំនិតរវាងសហព្រះរាជអាជ្ញា ឬចៅក្រមស៊ើបអង្កេតយ៉ាងណាៈ អង្គជំនុំជម្រះនឹងត្រូវបង្កើតឡើងដើម្បីដោះស្រាយជម្លោះដែលមានចរិតបៀបនេះ ។ ការសម្របសម្រួលចុងក្រោយមួយទៀត ច្បាប់នេះចែងថា រដ្ឋាភិបាលនឹងមិនដាក់ជូនព្រះមហាក្សត្រនូវសេចក្តីស្នើណាមួយស្តីអំពីការលើកលែងទោស ឬបន្ធូរបន្ថយទោសនៅក្នុងករណីទាំងនេះឡើយ ដោយហេតុនោះ វាមិនប៉ះពាល់ដល់អំណាចតាមរដ្ឋធម្មនុញ្ញរបស់ព្រះមហាក្សត្រក្នុងការប្រទានការលើកលែងទោសទេ ។

តើនេះមានន័យដូចម្តេច ទាក់ទងនឹងការព្រួយបារម្ភទាំងបួនចំណុចដែលលើកឡើងដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិនៅក្នុងលិខិតចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០០ ។ ចំណុចទីមួយដែលថា ជនដែលត្រូវបានចោទប្រកាន់នឹងត្រូវបានចាប់ខ្លួនឲ្យបាននោះគ្មានការជំទាស់ជាផ្លូវការពីសំណាក់ភាគីកម្ពុជា ។ ចំណុចទីពីរដែលថាគ្មានការលើកលែងទោស ឬការអនុគ្រោះទោសនោះហាក់ដូចជាត្រូវបានគ្រសោបដោយរូបមន្តមួយដែលចម្លែកបន្តិចនៅក្នុងច្បាប់ ដែលថារដ្ឋាភិបាលនឹងមិនសុំឲ្យព្រះមហាក្សត្រទទួលយកសេចក្តីសម្រេចចិត្តបែបនេះឡើយ ដោយសន្និដ្ឋានថា ព្រះអង្គនឹងផ្តួចផ្តើមគំនិតនេះផ្ទាល់ព្រះអង្គដែរ ។ ចំណុចទីបីដែលថាព្រះរាជអាជ្ញាជាជនបរទេសនោះមិនត្រូវបានទទួលយកឡើយ ទោះបីជារូបមន្តដែលលើកឡើងទុកឱកាសឲ្យសហព្រះរាជអាជ្ញាបញ្ចេញការផ្តួចផ្តើមគំនិតឯករាជ្យយ៉ាងណាក៏ដោយ ។ យន្តការពិសេសសម្រាប់ដោះស្រាយទំនាស់រវាងសហព្រះរាជអាជ្ញាតម្រូវឲ្យមានមតិភាគច្រើនលើសលប់ដើម្បីជំទាស់រាល់ជំហានណាមួយដែលនឹងមានន័យថា ក្រុមនេះនឹងមិនត្រូវប្រើក្រៅពីនៅក្នុងស្ថានភាពវិសាមញ្ញទេ ។

ចំណុចទីបួនរបស់លោកអគ្គលេខាធិការដែលថា ភាគច្រើននៃអង្គចៅក្រមគួរតែជាជនបរទេសនិងជ្រើសតាំងដោយអគ្គលេខាខ្លួនឯងផ្ទាល់នោះមិនត្រូវបានយល់ស្របទេ ។ ជនជាតិកម្ពុជានឹងមានចំនួនភាគច្រើនទាំងបីថ្នាក់ ។ ក្រុមអង្គចៅក្រមទាំងពីរនឹងត្រូវបានជ្រើសតាំងតាមរយៈនីតិវិធីផ្សេងគ្នា ហើយអង្គចៅក្រមទាំងអស់ចុងក្រោយនឹងត្រូវអនុម័តយល់ព្រមដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ ដើម្បីពង្រឹងសមាសភាពបរទេសនៅក្នុងការធ្វើសេចក្តីសម្រេចតម្រូវការឲ្យមានមតិភាគច្រើនលើសលប់ត្រូវបានដាក់ចេញ ។ នេះគឺជាដំណោះស្រាយមួយនៅក្នុងចំណោមដំណោះស្រាយនានាដែលក្រុមអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាបានលើកជំទាស់ ។

## ការអង្កេតផ្ទាល់ខ្លួន

### បញ្ហាចម្បង

គំរូដ៏ល្អមួយគួរតែជាតុលាការអន្តរជាតិពិសេសបង្កើតឡើងនៅកម្ពុជាដោយមានចៅក្រមនិងព្រះរាជអាជ្ញាកម្ពុជា និងបុគ្គលិកផ្សេងទៀតដែលត្រូវបានជ្រើសតាំងឡើងដោយយន្តការអន្តរជាតិដែលគួរឲ្យទុកចិត្តបាន ។ បញ្ហានេះគួរតែត្រូវបានចាត់ចែងឡើងតាមរយៈច្បាប់ដែលមានធាតុជំរុញនៅក្នុងសភាជាតិកម្ពុជាដែលនឹងស្នើឲ្យអង្គការសហប្រជាជាតិចូលមកដើម្បីសម្រេចគោលបំណងនេះ ។ គួរតែមានលទ្ធភាពក្នុងការបញ្ចូលអ្នកច្បាប់កម្ពុជាមួយចំនួននៅក្នុងដំណើរការជម្រះក្តីនេះក្នុងឋានៈជាចៅក្រម ឬព្រះរាជអាជ្ញា ប៉ុន្តែអ្នកទាំងនេះនឹងត្រូវជ្រើសតាំងតាមសមត្ថភាពនិងដើរតួនាទីជាបុគ្គលដែលត្រូវបានជ្រើសតាំងដោយអន្តរជាតិ ។ កិច្ចព្រមព្រៀងរបៀបនេះនឹងមានគុណសម្បត្តិជាច្រើនដែលត្រូវបានសង្ឃឹមទុកថានឹងកើតមាននៅក្នុងដំណោះស្រាយតុលាការ "ចម្រុះ" ។ នៅចុងបញ្ចប់គំរូនេះមិនត្រូវមានលទ្ធភាពទៅរួចខាងផ្នែកនយោបាយឡើយ ។ ប៉ុន្តែដើម្បីឲ្យអង្គការសហប្រជាជាតិ

យល់ព្រមចូលរួមនៅក្នុងតុលាការ"ចម្រុះ"នេះត្រូវមានការធានាចំពោះសុចរិតភាពនៃដំណើរការនេះ ។ នេះជាគ្រឹះសំខាន់ដែលការពិភាក្សានានាបានផ្តោតទៅលើ ។

ការធានាថានឹងធ្វើតាមបទដ្ឋានអន្តរជាតិតម្រូវឲ្យមានការការពារហ្មត់ចត់ល្អ មិនឲ្យមានសម្ពាធនយោបាយ ដោយប្រយោល និងដោយផ្ទាល់ ។ ជាការពិត អ្នកចូលរួមជាជនជាតិកម្ពុជាងាយនឹងមានផលប៉ះពាល់ជាងអ្នកដែលនឹងត្រូវបានជ្រើសតាំងដោយអន្តរជាតិ ។ នេះក៏ជាបញ្ហានៃការបង្ហាញជូនសាធារណជនកម្ពុជាថា ដំណើរការយុត្តិធម៌ពិតប្រាកដគឺកំពុងតែត្រូវស្វែងរកហើយ ។ ទាក់ទងនឹងទុទ្ធិភាពនៃប្រព័ន្ធតុលាការនៅកម្ពុជា សញ្ញាណច្បាស់លាស់មួយចំនួននៃការផ្លាស់ប្តូរគឺជាការសំខាន់ ។

ដោយសារមូលហេតុនេះហើយបានជាតម្រូវឲ្យមានការយល់ព្រមទៅលើការជ្រើសរើសអង្គចៅក្រមកម្ពុជាតាមរយៈយន្តការអន្តរជាតិ ហើយការស្នើថា មិនគួររឹតត្បិតមិនឲ្យជ្រើសរើសចៅក្រមក្រៅពីបញ្ជីអង្គចៅក្រមដែលកំពុងតែបម្រើការងារសព្វថ្ងៃនេះទេ ។ ក្រុមបេក្ខជនដែលមានលទ្ធភាពចាំបាច់ត្រូវការពង្រីកដោយគិតថា ជនជាតិកម្ពុជាជាច្រើនរូបមានការជាប់ជំពាក់ក្នុងដំណើរការជម្រះក្តីខ្មែរក្រហម ។

គំនិត "មតិភាគច្រើនលើសលប់" គឺពិតជាការសម្របសម្រួលមួយ ហើយមិនមានបញ្ហា ។ វាមានគំនិតទាំងស្រុងទៅលើការបែងចែកអង្គចៅក្រមជាពីរជំពូកដែលជាសញ្ញាខណ្ឌគួរឲ្យសោកស្តាយ សូម្បីតែនៅក្នុងកាលៈទេសៈធម្មតាក៏ដោយ ។ គំនិតពីរ"ខាង" របៀបនេះហាក់ដូចជាត្រូវបានផ្អែកទៅលើមូលដ្ឋានដែលខ្វះទំនុកចិត្តដែលគួរតែដោះស្រាយឲ្យបានជិតដិតជាងនេះទើបបាន ។ ហើយមួយទៀត គំរូនេះនៅក្នុងស្ថានការណ៍ជាក់ស្តែងអាចនាំដល់ភាពទាល់ច្រកមួយដែលក្នុងនោះ អាចមានមតិភាគច្រើន ប៉ុន្តែមិនច្រើនគ្រប់គ្រាន់សម្រាប់ឲ្យមានការសម្រេចចិត្តមួយឡើយ ។

ប្រសិនជាបទដ្ឋានអន្តរជាតិពិតជានឹងត្រូវបានបំពេញបានត្រឹមត្រូវមែននោះ ទាំងសម្តេចនាយករដ្ឋមន្ត្រីនិងអ្នកនយោបាយនានានៅកម្ពុជាមិនអាចមានឥទ្ធិពលទៅលើអង្គជំនុំជម្រះឡើយ ឬមិនអាចនរណាមើលឃើញថាបានធ្វើដូចនេះឡើយ ។ តុលាការមិនគួរជាឧបករណ៍សម្រាប់បម្រើផ្នែកនយោបាយនោះទេ ។ បញ្ហាចម្បងដែលមានការសម្របសម្រួលចុងក្រោយគឺថាវាមិនផ្តល់ឲ្យមានការធានាពេញលេញនៅលើបញ្ហាសំខាន់នេះ ។ ការព្រួយបារម្ភកាន់តែខ្លាំងនៅក្នុងប្រទេសកម្ពុជាដែលថាសម្តេចនាយករដ្ឋមន្ត្រីនឹងអាចមានឥទ្ធិពលយ៉ាងខ្លាំងទៅលើដំណើរការជំនុំជម្រះក្តីនេះ ។

សម្តេច ហ៊ុន សែន បានធ្លាប់មានប្រសាសន៍ដោយមោទកភាពថា សម្តេចបានធ្វើឲ្យខ្មែរក្រហមបរាជ័យមុនដំបូង គឺផ្នែកយោធារួចមកនយោបាយ ហើយឥឡូវនេះសូមបញ្ជាក់អំពីសមិទ្ធិផលទាំងអស់នេះតាមរយៈការជំនុំជម្រះក្តី ។ នៅក្នុងឱកាសផ្សេងៗទៀតសម្តេចមានប្រសាសន៍ថា តុលាការជាមធ្យោបាយសម្រាប់កម្ទេចចលនានេះ ។ ប៉ុន្តែនៅពេលមានករណីនេះកើតឡើងបែរជាថាមិនចាំបាច់ឲ្យមានការកាត់ទោសទេ លើកលែងតែ តាម៉ុក ដែលមិនព្រមចុះចាញ់ ។

ប្រតិកម្មរបស់សម្តេច ហ៊ុន សែន ប្រឆាំងនឹងសំណើបង្កើតតុលាការក្រៅប្រទេសហាក់ដូចជាមានឫសគល់ជាច្រើន ។ ឫសគល់ទីមួយ គឺថា វាអាចធ្វើឲ្យមានចំណាប់អារម្មណ៍ថារដ្ឋាភិបាលគ្មានលទ្ធភាព ឬមិនមានឆន្ទៈចង់មានតុលាការនៅក្នុងស្រុក ។ ទោះជានៅក្នុងសំបុត្រក្នុងខែមិថុនា ឆ្នាំ១៩៩៧ សម្តេចសារភាពអំពីភាពមិនគ្រប់ជ្រុងជ្រោយនៃប្រព័ន្ធតុលាការកម្ពុជាយ៉ាងណាក៏ដោយ ក៏សម្តេចនៅតែមិនងាយទទួលស្គាល់ចំពោះករណីនេះដែរ ។ ហើយប្រសិនបើមានតុលាការសម្តេចនឹងពិតជាចង់បានកេរ្តិ៍ឈ្មោះជាមិនខាន ។

ចំណុចនេះនាំឲ្យមានបញ្ហាស្តីអំពីព្រំដែនរវាងអំណាចនីតិប្រតិបត្តិនិងអំណាចតុលាការ ។ អង្គជំនុំជម្រះឯករាជ្យពិតប្រាកដនៅក្នុងករណីដ៏សំខាន់នេះគឺជាជំហានដ៏ធំទៅលើទឹកដីដែលមិនទាន់ឃ្លាតឆ្ងាយពីគំនិតចាស់ៗ ឬយុត្តិធម៌រាជានិយម ឬ"យុត្តិធម៌បែបសង្គមនិយម"ឈានទៅរកតុលាការដែលមានឯករាជ្យពិតៗ ។ ការពិភាក្សាដែលអូសបន្លាយពេលជាមួយរដ្ឋាភិបាលដែលជាអង្គការ

នីតិប្រតិបត្តិស្តីអំពីវិធីបង្កើតតុលាការនេះអាចបានធ្វើឲ្យមានចំណាប់អារម្មណ៍នៅក្នុងប្រទេសកម្ពុជាថាមានព្រំដែនមិនច្បាស់លាស់រវាងអំណាចតុលាការនិងអំណាចនយោបាយ ។ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ខ្លួនឯងផ្ទាល់ជួនកាលមានប្រសាសន៍ថា សម្តេចស្ថិតនៅពីក្រៅដំណើរការនេះ ប៉ុន្តែតាមធាតុពិតសម្តេចបានគ្រប់ដណ្តប់គ្រប់ផ្នែកនៃដំណើរការនេះ ហើយជាញឹកញយ សម្តេចតែងតែនិយាយដោយមិនលាក់បាំងទៀតផង ។ សេចក្តីថ្លែងការណ៍ម្តងហើយម្តងទៀតនិងមានភាពផ្ទុយគ្នាទៅលើបញ្ហាថាតើ អៀង សារី គួរនឹងត្រូវនាំយកមកកាត់ទោសដែរ ឬយ៉ាងណានោះ គឺជាឧទាហរណ៍មួយយ៉ាងច្បាស់ ។

នេះអាចសបញ្ជាក់ថាមានគំនិតប្រឆាំងគ្នារវាងបទដ្ឋានអន្តរជាតិសម្រាប់តុលាការយុត្តិធម៌ និង«អធិបតេយ្យភាព» ។ សេចក្តីថ្លែងការណ៍មួយក្នុងចំណោមសេចក្តីថ្លែងការណ៍ដ៏សំខាន់បំផុតនៅក្នុងការពិភាក្សាទាំងមូលនេះគឺកំណត់សម្គាល់របស់សម្តេច សីហនុ នៅក្នុងទិនានុប្បវត្តិប្រចាំខែរបស់ព្រះអង្គដែលថាគ្មានការប្រឆាំងគ្នាបែបនេះទេ ។

## ការពិចារណាទៅលើយុទ្ធសាស្ត្រ

យុទ្ធសាស្ត្ររបស់សម្តេចនាយករដ្ឋមន្ត្រីហាក់ដូចជាផ្អែកលើជម្រើសបីយ៉ាង÷ ក) កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិទៅលើតុលាការ«ចម្រុះ»មួយ ខ) អញ្ជើញរដ្ឋាភិបាលមួយចំនួន (ដូចជាសហរដ្ឋអាមេរិក បារាំង រុស្ស៊ី ជប៉ុន និង ឬប្រទេសឥណ្ឌា) ឲ្យសហការគ្នាដោយផ្ទាល់តាមរយៈការបញ្ជូនចៅក្រមរបស់ខ្លួនមកកម្ពុជា ឬ គ) អញ្ជើញមេធាវី (ដូចជាមេធាវីអាមេរិកកាំង រ៉ាមស៊ី ក្លាក ជាដើម) ឲ្យចូលរួមនៅក្នុងដំណើរការនេះ ។

សម្តេចបញ្ចេញនូវអារម្មណ៍លាយឡំគ្នាមិនច្បាស់លាស់អំពីជម្រើសរបស់អង្គការសហប្រជាជាតិដែលមួយផ្នែកផ្អែកលើគំនុំចំពោះអង្គការនេះ ។ ដូច្នេះសម្តេចចង់ដាក់កម្រិតថាតើខ្លួននឹងរៀបចំឲ្យមានការសម្រុះសម្រួលប៉ុនណាជាមួយនឹងអង្គការសហប្រជាជាតិ ហើយបង្ខំឲ្យអង្គការនេះនិយាយថាយល់ព្រមឬមិនយល់ព្រម ។ បើចម្លើយថា «ទេ» សម្តេចអាចបន្ទោសអង្គការសហប្រជាជាតិ ហើយនៅពេលទន្ទឹមគ្នានោះ អាចជ្រើសរើសយកជម្រើស«ខ» ឬ «គ» ។

សម្តេច ហ៊ុន សែន ត្រូវបានដាក់ឲ្យប្រឈមមុខជាមួយនឹងអ្នកជំនាញការច្បាប់អង្គការសហប្រជាជាតិដែលថ្លែងថា អង្គការសហប្រជាជាតិអាចត្រឹមតែចូលរួមនៅក្នុងដំណើការនេះ ប្រសិនបើមានការធានាឲ្យបានច្បាស់លាស់ថានឹងឆ្លើយតបទៅនឹងយុត្តិធម៌ដែលមានបទដ្ឋានអន្តរជាតិ គ្មានលម្អៀង និងត្រឹមត្រូវតាមនីតិវិធី ។ ចំណុចសំខាន់ គឺថារដ្ឋជាសមាជិក នៅទីបញ្ចប់សម្រេចថានឹងចៀសវាងទៅតែម្នាក់ឯង ហើយក៏សម្រេចចិត្តគាំទ្រការពិភាក្សារបស់អង្គការសហប្រជាជាតិ ។ ការនេះបានរាំងស្ទះដល់ជម្រើស«ខ»យ៉ាងមានប្រសិទ្ធភាព ។ ខ្ញុំជឿជាក់ថារដ្ឋាភិបាលដឹងច្បាស់ថា ជម្រើស«គ» នឹងមិនមានភាពគួរឲ្យជឿទុកចិត្តបានទេ ជាពិសេសក្រោយពេលបរាជ័យនៃកិច្ចចរចាជាមួយនឹងអង្គការសហប្រជាជាតិ ។

ហេតុដូចនេះជម្រើសពិតប្រាកដសម្រាប់រដ្ឋាភិបាលប្រែក្លាយទៅជាកិច្ចព្រមព្រៀងមួយជាមួយអង្គការសហប្រជាជាតិ(ដែលនឹងតម្រូវឲ្យមានដំណើរការមានភាពឯករាជ្យ) បើមិនដូចនេះទេមានតែកាត់ទោសតាម៉ុក និង ឌុច ហើយប្រហែលជាអ្នកផ្សេងៗទៀតនៅក្នុងតុលាការក្នុងស្រុកដែលមានស្រាប់ដោយគ្មានការចូលរួមពីសំណាក់អង្គការសហប្រជាជាតិ ។ ជម្រើសក្រោយនេះនឹងជួបបញ្ហាទាំងអស់ដែលត្រូវបានរកឃើញនៅក្នុងការពិភាក្សាមកដល់ពេលនេះ ។ ហើយការជំនុំជម្រះបែបនេះក៏នឹងត្រូវបានត្រួតពិនិត្យយ៉ាងហ្មត់ចត់ដោយប្រព័ន្ធឃោសនាកម្ពុជានិងអង្គការនានាក៏ដូចជាសហគមន៍អន្តរជាតិពេលនោះចំណុចខ្វះខាតពិតជានឹងត្រូវលេចឮច្បាស់ជាពុំខាន ។

មានការទាញហេតុផលថាការសម្របសម្រួលដែលល្អជិត១០០%រវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាទៅលើបញ្ហាតុលាការអាចត្រូវបានកែតម្រូវដោយកម្លាំងជំរុញនៃដំណើរការជម្រះក្តីខ្លួនឯងផ្ទាល់នៅពេលដែលដំណើរការនេះចាប់ផ្តើម ។ កត្តាមួយ គឺអាចជាឥទ្ធិពលរបស់បុគ្គលជនបរទេសដែលចូលរួមមានឯករាជ្យនិងសមត្ថភាព(តាមការសង្ឃឹម) ទោះបី

ជាបុគ្គលទាំងនេះជាមតិភាគតិចក៏ដោយចុះ ។ បុគ្គលទាំងនេះក៏អាចចុះចេញពីដំណើរការជម្រះក្តីនេះដែរ ប្រសិនបើខ្លួនមិនពេញចិត្ត ហើយការដឹងពីអំពីគ្រោះថ្នាក់ភាព អាចនឹងកើតមានឡើង ហើយក៏អាចការពារការរំលោភផ្សេងៗដែរ ។ ការពិនិត្យពិច័យរបស់ប្រព័ន្ធឃោសនានិងអង្គការមិនមែនរដ្ឋាភិបាលនានាក៏អាចមានឥទ្ធិពលវិជ្ជមានដែរ ។ ហេតុដូចនេះត្រូវឲ្យរដ្ឋាភិបាលដាក់សម្ពាធទៅលើតុលាការឲ្យមានការផ្លាស់ប្តូរខុសពីភាពដើម តាមពិតអាចមិនមែនជាការងាយនោះទេ ។

អាចមានធាតុពិតនៅក្នុងការទស្សន៍ទាយនេះ ប៉ុន្តែនេះមិនមែនជាហេតុផលល្អទេ ក្នុងការទទួលយកគំរូមួយដែលមិនត្រូវតាមចិត្តដែលអាចបង្កជាបញ្ហាជម្លោះនៅក្នុងដំណើការនីតិវិធីតុលាការនិងអាចធ្វើឲ្យជំហរសីលធម៌ចុះខ្សោយ ។ ប្រការសំខាន់ដែរក្នុងការដឹងថាតុលាការកម្ពុជាអាចជាឧទាហរណ៍យ៉ាងសំខាន់សម្រាប់ស្ថានការណ៍នានាដែលកើតឡើងនៅពេលអនាគត ។ ដោយសារហេតុផលនេះហើយបានជាការកសាងតុលាការផ្អែកលើគោលការណ៍វាសំខាន់ជាងផ្អែកលើការសម្របសម្រួលផ្នែកនយោបាយ ។

---

**ចិនបរិយាយៈ**

# ហេតុអ្វីបានជាអាជ្ញាធរវៀតណាមបង្កជម្លោះព្រំដែនវៀតណាម-កម្ពុជា?

**(ថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៧៨)**

**(តចប់)** យកល្អអាជ្ញាធរវៀតណាមដែលវាយប្រហារចិនដែលគាំទ្រកម្ពុជា និងចោទកម្ពុជាថាជាអ្នក“បង្ក”ជម្លោះព្រំដែនតាមការញុះញង់របស់ចិននោះ គួរតែនិយាយឲ្យបានច្រើនអំពីការធ្វើទុក្ខទោសមកលើជនជាតិចិនដែលរស់នៅលើទឹកដីរបស់ខ្លួន ។ ធ្វើយ៉ាងដូច្នេះមានន័យថាដាក់ទោសលើខ្លួនឯងឬ? យោងតាមហេតុផលរបស់អាជ្ញាធរវៀតណាម កម្ពុជាបានធ្វើឡើងតាមការញុះញង់របស់ចិន ប៉ុន្តែវាជួយនឹងរឿងជនជាតិចិននៅវៀត-ណាម ។ តើរឿងនេះវាអាចកើតឡើងបានទេ! អាជ្ញាធរវៀត-ណាម ខំដើរឃោសនាថា ខ្លួនមិនខ្វាចនឹងចេញសេចក្តីប្រកាសពោរពេញទៅដោយទំនាស់ដែលមិនអាចពន្យល់បាននោះទេ ។

នយោបាយរដ្ឋាភិបាលកម្ពុជា គឺយកចិត្តទុកដាក់ទៅលើជនជាតិចិននិងពលរដ្ឋកម្ពុជាស្មើគ្នា និងផ្តល់សិទ្ធិដល់ជនជាតិចិនក្នុងការជ្រើសរើសដោយសេរីលើបញ្ហាសញ្ជាតិរបស់ខ្លួន ។ អាជ្ញាធរវៀតណាមចង់ស្តីបន្ទោសចិនថា ជាអ្នក“បង្ក”ជម្លោះព្រំដែនវៀតណាម-កម្ពុជា ហើយខំប្រឹងលាក់បាំងការធ្វើទុក្ខបុកម្នេញរបស់ខ្លួនមកលើជនជាតិចិនដោយធ្វើឲ្យមានការឈ្លោះទាស់ទែងគ្នារវាងចិននិងកម្ពុជា ។ គោលបំណងពីរនេះ គឺត្រូវបរាជ័យ ហើយការទាញហេតុផលរបស់ខ្លួនក៏មិនអាចការពារខ្លួនបានដែរ ។

គ្មានអ្នកណាក្រៅពីអាជ្ញាធរវៀតណាមទេ ហើយក៏មិនមែនចិនដែរ ដែលប្រាថ្នាចង់ពង្រីកការគ្រប់គ្រងនិងលេបទឹកដីកម្ពុជា ព្រមទាំងចង់ធ្វើម្ចាស់លើភូមិភាគអាស៊ី-អាគ្នេយ៍នោះ ។ ការមួលបង្កាច់របស់អាជ្ញាធរវៀតណាមមិនខុសអ្វីនឹងចោរស្រែកឲ្យ“ចាប់ចោរ”នោះទេ ។

មនុស្សម្នាទូទៅមើលឃើញថាអាជ្ញាធរវៀតណាមត្រូវប្រឈមមុខនឹងការងារដ៏ធ្ងន់ធ្ងរនិងលំបាកលំបិនក្នុងការព្យាបាលរបួសបណ្តាលមកពីសង្គ្រាម ការកសាងនិងអភិវឌ្ឍន៍សេដ្ឋកិច្ចក្រោយពីជ័យជម្នះលើចក្រពត្តិអាមេរិកមក ។ ប៉ុន្តែអាជ្ញាធរវៀតណាមមិនបានអើពើជាមួយនឹងតម្រូវការទាំងនេះឡើយ តែបែរជាមកបង្កើនកម្លាំងមនុស្ស មធ្យោបាយ សម្ភារ និងហិរញ្ញវត្ថុព្រមទាំងប្រើប្រាស់ជំនួយយោធាយ៉ាងច្រើនដែលខ្លួនបានទទួលនៅពេលមានកលិយុគ និងអាវុធយុទ្ធភណ្ឌដែលមានតម្លៃគិតជាទឹកប្រាក់ចំនួនរាប់កោដិដុល្លារដែលសហរដ្ឋអាមេរិកបោះបង់ចោល ដើម្បីពង្រីងខាងវិស័យយោធាទៅវិញ ។ មានសំណួរសួរ

ថា «ហេតុអ្វីបានជាវៀតណាមធ្វើយ៉ាងដូច្នេះ?» ។ សកម្មភាព របស់អាជ្ញាធរវៀតណាមគឺពិតជាចម្លើយដ៏ល្អបំផុត ។

ជ័យជម្នះរបស់វៀតណាមលើចក្រពត្តិអាមេរិកនិងចំនួន អាវុធដ៏ច្រើនសន្ធឹកសន្ធាប់ដែលមានសព្វថ្ងៃនេះ បានធ្វើឲ្យក្បាល អាជ្ញាធរវៀតណាមកាន់តែរីកធំឡើង ហើយដៃចេះតែចង់បាន ថែមទៀត ។ វៀតណាមលើកជើងខ្លួនឯងថាជា«មហាអំណាច» នៅភូមិភាគអាស៊ី-អាគ្នេយ៍ ដោយអួតថាសព្វថ្ងៃនេះវៀតណាម គឺជាមហាអំណាចយោធាធំមួយក្នុងចំណោមមហាអំណាចយោធា ធំៗនៅលើពិភពលោក ។ ជាការច្បាស់ណាស់ថា តាមរយៈ «ដើមទុន»ដែលខ្លួនមាននេះ វៀតណាមស្រមើស្រមៃថានឹងក្លាយ ជាម្ចាស់គ្រប់គ្រងទឹកដីនៅភូមិភាគអាស៊ី-អាគ្នេយ៍ ហើយចាត់ទុក ការទាញយកផលប្រយោជន៍ពី«សហព័ន្ធឥណ្ឌូចិន»ជាជំហានទី១ ។ ចាប់តាំងពីកម្ពុជាប្រឆាំងជំទាស់ដាច់អហង្ការចំពោះមហិច្ឆតា របស់វៀតណាមក្នុងការសម្រេចអនុត្តរភាពនៅក្នុងតំបន់ អាជ្ញាធរ វៀតណាមបានដាក់ការគាបសង្កត់កម្ពុជាតាមរយៈការឈ្លានពាន និងវិទ្ធង្សនាប្រដាប់អាវុធដោយមិនគិតកោតក្រែងអ្វីឡើយ ។

ការប៉ុនប៉ងពង្រីកទឹកដីរបស់អាជ្ញាធរវៀតណាមគឺលើសពី «សហព័ន្ធឥណ្ឌូចិន»ទៅទៀត ។ មហិច្ឆតារបស់អាជ្ញាធរវៀត-ណាមគឺលើសពីអ្វីដែលយើងមើលឃើញទៅទៀតតាមរយៈ ឥរិយាបថរបស់វៀតណាមចំពោះសមាគមប្រជាជាតិអាស៊ីភាគ អគ្នេយ៍ (អាស៊ាន) ។ អាជ្ញាធរវៀតណាមដែលពីមុនបានជំទាស់ ព្រមទាំងវាយប្រហារអាស៊ានថាជា«ឧបករណ៍របស់ចក្រពត្តិ» នោះបានផ្លាស់ប្តូរឥរិយាបថចំពោះអាស៊ានមួយរំពេចចាប់តាំង ពីជម្លោះព្រំដែនជាមួយកម្ពុជារីករាលដាលកាន់តែខ្លាំងឡើងនៅ ចុងឆ្នាំមុន ។ អាជ្ញាធរវៀតណាមបានជំរុញឲ្យអាស៊ានធ្វើការកែ ទម្រង់រចនាសម្ព័ន្ធក្នុងគោលបំណង«ធ្វើឲ្យសមទៅនឹងសភាព ការណ៍» និង «នាំមកនូវកិច្ចសហប្រតិបត្តិការក្នុងតំបន់» ដោយប្តូរ ឈ្មោះអាស៊ានទៅជា«អង្គការសហប្រតិបត្តិការតំបន់អាស៊ី-អាគ្នេយ៍» ដែលជាអង្គការមួយមានលក្ខណៈដូចគ្នាបេះបិទទៅនឹង «ប្រព័ន្ធសន្តិសុខរួមនៅអាស៊ី»ដែលគាំទ្រនិងទំនុកបម្រុងដោយ ចក្រពត្តិសូវៀត ។ អាជ្ញាធរវៀតណាមលើកឡើងបែបនេះដោយ មានសម្លែងទទង់មានន័យថា «សន្តិភាព ឯករាជ្យ និងអព្យាក្រឹត ពិតៗនៅអាស៊ី-អាគ្នេយ៍» ។ អាជ្ញាធរវៀតណាមនិយាយថា ការណ៍នេះនឹងជួយឲ្យប្រជាជាតិអាស៊ីភាគអគ្នេយ៍ផ្សេងៗទៀត ទទួលបាននូវ«ឯករាជ្យពិតប្រាកដ» ។ ម្យ៉ាងទៀត អាជ្ញាធរ វៀតណាមគិតថា ប្រជាជាតិអាស៊ី-អាគ្នេយ៍មិនទាន់ទទួលបាន «ឯករាជ្យពិតប្រាកដ»នៅឡើយទេ ហើយពិតជាត្រូវការវៀតណាម ដែលមានឯករាជ្យមកធ្វើសហប្រតិបត្តិការជាមួយ និងដឹកនាំខ្លួន ផង ។ តើចាំបាច់ពន្យល់ទៀតទេថាតើអាជ្ញាធរវៀតណាមនឹង គិតចង់ដើរតួជាអ្វីនៅក្នុងប្រជាជាតិអាស៊ី-អាគ្នេយ៍? សូវៀតបាន យល់ព្រមចំពោះការឈ្លានពានទឹកដីកម្ពុជារបស់អាជ្ញាធរ វៀតណាមក្នុងបំណងទាញយកផលប្រយោជន៍ពីការគ្រប់គ្រង «សហព័ន្ធឥណ្ឌូចិន»និងពីការធ្វើសកម្មភាពនៅក្នុងភូមិភាគ អាស៊ី-អាគ្នេយ៍ ។ សូវៀតបានសរសើរអាជ្ញាធរវៀតណាមថា «ធ្វើវិភាគទានយ៉ាងមានប្រយោជន៍ដល់ការពង្រីកទំនាក់ទំនងនៅ ភូមិភាគអាស៊ី-អាគ្នេយ៍»និងដើម្បី«បើកចំហទស្សនវិស័យថ្មីៗ សម្រាប់ការបន្ធូរភាពតានតឹង» ។ សហភាពសូវៀតហៅវៀត-ណាមថាជា«ប៉ុស្តិ៍សង្គមនិយមជួរមុខនៅអាស៊ី-អាគ្នេយ៍» ហើយ ថ្មីៗនេះ បានឲ្យវៀតណាមចូលរួមក្នុង«ក្រុមប្រឹក្សាជំនួយសេដ្ឋកិច្ច ទៅវិញទៅមក»ដែលហៅកាត់ថា(COMECON) ។ នេះកាន់តែស បញ្ជាក់ឲ្យឃើញថា សហភាពសូវៀត គឺជាអ្នកជួយទំនុកបម្រុង អាជ្ញាធរវៀតណាមជាសម្ងាត់ក្នុងការស្វែងរកអនុត្តរភាពនៅ ក្នុងតំបន់ ។

មកដល់ពេលនេះរឹតតែច្បាស់ណាស់ថា ជម្លោះព្រំដែន រវាងវៀតណាមនិងកម្ពុជាគឺមិនមែនជារឿងចៃដន្យទេ ។ ដោយ រួមជាមួយសកម្មភាពរបស់អាជ្ញាធរវៀតណាមប្រឆាំងនឹងចិន ដូចជាការធ្វើទុក្ខបុកម្នេញនិងការបណ្តេញជនជាតិចិនចេញពី វៀតណាម ព្រមទាំងការប្រើបញ្ហាជនជាតិចិននៅក្រៅប្រទេស មកបន្ទុចបង្អាក់ទំនាក់ទំនងរវាងចិននិងប្រជាជាតិអាស៊ី-អគ្នេយ៍ ផងនោះ ជម្លោះនេះគឺពិតជាកើតឡើងដោយមានផែនការរួម មួយ ។ នៅក្នុងផែនការនេះមហាអំណាចសូវៀតមានគោលបំណង អនុត្តរភាពជួយលាក់និងទំនុកបម្រុងអនុត្តរភាពរបស់វៀតណាម ក្នុងតំបន់ ក្នុងខណៈដែលវៀតណាមជាដៃគូថ្នាក់ទាបរបស់សហ-ភាពសូវៀត ។ នេះគឺជារបៀបប្រតិបត្តិការថ្មីមួយនៅក្នុង

ស្ថានការណ៍អន្តរជាតិបច្ចុប្បន្ននិងជាប្រតិបត្តិការថ្មីនៃការវាតទីរបស់សហភាពសូវៀត ។ មនុស្សម្នាបានឃើញវិធីនេះធ្លាប់ធ្វើឡើងនៅក្នុងប្រទេសកម្ពុជា ហើយឥឡូវនេះឃើញមួយទៀតនៅក្នុងប្រទេសវៀតណាម ។ នេះជាបាតុភូតមួយដែលទាមទារឲ្យមានការប្រុងប្រយ័ត្នទូទាំងពិភពលោក ។

អាជ្ញាធរវៀតណាមមិនអាចបោកប្រាស់អ្នកណាម្នាក់បានឡើយតាមរយៈការមួលបង្កាច់ប្រទេសចិននោះ ។ ប្រទេសចិនប្រកាសម្តងហើយម្តងទៀតនិងជាឱឡារិកថា ចិននឹងមិនធ្វើជាមហាអំណាចផ្តាច់មុខនិងរិះរកអនុត្តរភាពនោះទេ ។ ប្រទេសចិនមិនគាំទ្រមហាអំណាចអនុត្តរភាពនិយមនិងវាតទីនិយមក្នុងតំបន់ស៊ីគេនោះទេ ។ ទោះជាអាជ្ញាធរវៀតណាមមួលបង្កាច់បង្ខូចចិនយ៉ាងណាក៏ដោយ ក៏ចិននៅតែបន្តគាំទ្រយ៉ាងពេញទំហឹងដល់ការតស៊ូប្រឆាំងនឹងចក្រពត្តិអាណានិគម និងអនុត្តរភាព-និយមដែលកំពុងតែធ្វើឡើងដោយប្រជាជននៅទូទាំងពិភពលោកជានិច្ចក្នុងនោះរួមមានប្រជាជនកម្ពុជាផង ។ កលល្បិចរបស់អាជ្ញាធរវៀតណាមក្នុងការដើរឃោសនាដើម្បីបំភ្លៃបោកប្រាស់មហាជន អាចបោកប្រាស់បានតែអ្នកដែលមិនដឹងអំពីការពិតប៉ុណ្ណោះ ។ នៅពេលការពិតត្រូវបានលាតត្រដាងអស់ ពេលនោះមហិច្ឆតារបស់អាជ្ញាធរវៀតណាមក្នុងការត្រួតត្រាក្នុងតំបន់នឹងប្រែទៅជាពណ៌ពិតជាមិនខាន ។

សូមសរសេរលិខិត
ឬអត្ថបទពិភាក្សាជុំវិញបញ្ហាខ្មែរក្រហមមកកាន់
**ទស្សនាវដ្តី«ស្វែងរកការពិត»**
ប្រអប់សំបុត្រលេខ ១១១០ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ឬតាមទូរសារលេខៈ (៨៥៥)(២៣)២១០៣៥៨
ឬ Email: dccam@bigpond.com.kh

# រឿងពិត

មីងមានចិត្តរំភើបស្ទើរតែស្រក់ទឹកភ្នែក និងមានការសោកសង្រេងយ៉ាងខ្លាំងនៅពេលអានអត្ថបទក្មួយសរសេរអំពីប្រវត្តិរបស់លោកប៉ា និងប្រវត្តិខ្លះៗរបស់បងប្រុសមីងឈ្មោះ ចិន ស៊ីឌិន ដែលក្មួយនិងក្រុមការងារព្រមទាំងលោកនាយកទស្សនាវដ្តីបានព្យាយាមយ៉ាងយកចិត្តទុកដាក់ស្វែងរកឯកសារយ៉ាងលំបាកគ្រប់ទីកន្លែង និងខំស្រាវជ្រាវរកឃើញឯកសារមួយចំនួនដែលមានឈ្មោះនិងអក្សររបស់បងប្រុសមីងយ៉ាងពិតប្រាកដ តែពាក្យមួយចំនួនដែលគាត់សរសេរនោះមិនមែនជាការពិតទាំងស្រុងទេ «អត្ថបទខាងក្រោម» ដើម្បីជៀសវាងនូវការធ្វើទារុណកម្មយ៉ាងសាហាវឃោរឃៅនោះ ។ តែការស្លាប់របស់គាត់នៅតែមានដដែល ។

មីង និងក្រុមគ្រួសារដែលរស់រានមានជីវិតក៏ដូចជាបងប្អូនពលរដ្ឋកម្ពុជាយើងទាំងអស់ដែរ នៅតែចងចាំជានិច្ចនូវអំពើព្រៃផ្សៃនៃរបបប្រល័យពូជសាសន៍ខ្មែរក្រហមដែលបន្សល់ទុកនៅក្នុងអារម្មណ៍មិនអាចបំភ្លេចបាន ។

មីងសូមថ្លែងអំណរគុណដល់ក្មួយស្រី កែវកន្និដ្ឋា ដែលបានខឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធលោកប៉ា និងបងប្រុសរបស់មីងក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ ។

នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរចំពោះលោកនាយកព្រមទាំងក្រុមការងារ ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការស្រាវជ្រាវនូវឯកសារប្រល័យពូជសាសន៍ ព្រមទាំងបានចេញផ្សាយនូវប្រវត្តិរបស់លោកប៉ា និងបងប្រុសរបស់នាងខ្ញុំ ។ សូមឲ្យលោកនាយក និងក្រុមការងារទទួលបាននូវជោគជ័យគ្រប់ភារកិច្ច ។

**ចាន់ ស្រីធូច**

**(តពីទំព័រ២៩)** បដិវត្តជាច្រើន ដូចជាបទយុទ្ធជនក្លាហាន បទភូមិឃុំស្រុកយើង បទពុកម៉ែយើង...សុទ្ធតែជាបទដែល សុខា ធ្លាប់បានច្រៀងនិងសម្តែងយ៉ាងស្ទាត់បំផុត ។ ក្រោយមក សុខា បានក្លាយជាប្រធានគ្រប់គ្រងខាងសិល្បៈ ។ រហូតមកដល់ថ្ងៃបញ្ចប់វគ្គសន្និបាតលើកទី២២របស់ភូមិភាគ សុខា បានផ្លាស់ប្តូរការងារពីអ្នកសិល្បៈមកជាអ្នកដើរឃោសនាអប់រំប្រជាជនខ្មែរអ៊ីស្លាមឲ្យយល់អំពីការដឹកនាំរបស់បដិវត្តន៍សង្គមនិយមនៅតាមមូលដ្ឋានវិញ ។ ឯ រកី វិញត្រូវបានចាត់តាំងឲ្យដើរឃោសនានៅតាមគ្រប់តំបន់ក្នុងភូមិភាគបូព៌ា ។ អ្នកទាំងពីរបានបែកគ្នានៅឆ្នាំ១៩៧៤ បន្ទាប់ពី សុខា មានគូរដណ្តឹងជិតរៀបការ ។ ពេល សុខា រៀបការជាមួយ ណុះ លាស់ មិត្តសម្លាញ់ប្តូរផ្តាច់ឈ្មោះ រកី មិនបានចូលរួមជាកិត្តិយសទេ ព្រោះជាប់រវល់ឃោសនាប្រជាជននៅតំបន់២នៃភូមិភាគបូព៌ា ។

នៅឆ្នាំ១៩៧៥ សុខា បានត្រូវជម្លៀសទៅកាន់ខេត្តក្រចេះ រហូតដល់បែកឆ្នាំ១៩៧៩ ។ ការទំនាក់ទំនងគ្នាជាមួយ រកី ត្រូវបានកាត់ផ្តាច់ ។ សុខា បាន រៀបរាប់ថា មុននឹងបែកគ្នា ខោអាវរបស់គាត់ដែលស្លៀកថតត្រូវគាត់ប្រគល់ទៅឲ្យ រកី ទុកជាវត្ថុអនុស្សាវរីយ៍ ។ ចំណែក រកី វិញបានផ្តល់រូបថតមួយសន្លឹកនេះទុកឲ្យគាត់ដែរដើម្បីមើលម្តងម្កាលនៅពេលនឹកគ្នា ។ រកី ត្រូវបានខ្មែរក្រហមសម្លាប់នៅឆ្នាំ១៩៧៨ បន្ទាប់ពីមានការបះបោរពីខាងបក្សពួក សោ ភឹម ថាក្បត់នឹងបដិវត្តន៍ ។ កម្មាភិបាលខាងភូមិភាគបូព៌ាជាច្រើននាក់ត្រូវបានសម្លាប់ ។

ដំណឹងទាំងឡាយដែលទាក់ទងរឿង រកី ត្រូវបាត់ឈឹងរហូតដល់ក្រោយឆ្នាំ១៩៧៩ ។ សុខា បាននិយាយប្រាប់ថា គាត់មិនដឹងរឿង រកី ស្លាប់ទាល់តែសោះ តាំងពីបែកគ្នាមករហូតដល់ឆ្នាំ១៩៨៤ គឺនៅពេលដែលគាត់មានផ្ទៃពោះកូនទី២របស់គាត់ ទើបគាត់ដឹងច្បាស់ ថាមិត្តសម្លាញ់របស់គាត់ឈ្មោះ រកី បានស្លាប់បាត់ទៅហើយ ។ សុខា និយាយបន្តថា កូនស្រីទី២របស់គាត់មានមុខមាត់ដូចគ្នាបេះបិទនឹង រកី ហើយព្រមទាំងបានសង្ស័យថា កូនរបស់គាត់នេះជា រកី ទៀតផង ។ សុខា តែងតែយល់សប្តិឃើញ រកី មកលេងនិងមានប្រគល់នូវក្រវិលចិញ្ចៀន និងនាឡិកាដល់គាត់ពេលដែលគាត់មានផ្ទៃពោះ ។ សព្វថ្ងៃ សុខា នៅតែនឹកឃើញនូវរឿងរ៉ាវដែលបានកើតឡើងកន្លងមករវាងគាត់ និង រកី ។ មុនពេលមួយថ្ងៃដែលខ្ញុំបានទៅជួបគាត់ សុខា បានយករូបថតមួយសន្លឹកនេះមកមើល ។ គាត់និយាយប្រាប់ខ្ញុំពីចិត្តរបស់គាត់ថា“ខ្ញុំ និង រកី មិនគួរបែកគ្នាទាល់តែសោះ” ។

**ផេង ពង្សរ៉ាស៊ី**



សុខានិងកូន (រូបឆ្វេង) និង រ៉ាស៊ី (រូបស្តាំ)



មូសា សុខា ម៉ាត់ រកីយ៉ាស់

***កំណាព្យខ្មែរក្រហម៖***

(បទពាក្យ៧) **យុវជន យុវនារីបដិវត្តន៍ ប្ដេជ្ញាខាយសំរុកការពារ និងកសាងប្រទេសឱ្យលឿនលោតផ្លោះ**

***(យុវជន យុវនារីបដិវត្ត លេខ១២ ខែធ្នូ ១៩៧៦)***

មាតុភូមិកម្ពុជារំដោះហើយ ឥឡូវបោះពួយលឿនលោតផ្លោះ
ចេញពីសង្គ្រាមមួយឆ្នាំសោះ ទិដ្ឋភាពក្រៀមក្រោះប្រែប្រិមប្រិយ ។
វាលរាបព្រៃភ្នំកោះសមុទ្រ ទីក្រុងជនបទគ្រប់ទិសទី
ត្រូវបានយុវជនយុវនារី រួមប្រែឲ្យថ្មីល្អអនេក ។
គយគន់ប្រព័ន្ធភ្លឺប្រឡាយ ខ្វាត់ខ្វែងវែងឆ្ងាយទិដ្ឋភាពប្លែក
ទឹកដក់ចាំងថ្ងៃភ្លឺផ្លេកៗ វិស័យបំណែកកម្ទេចប្រាក់ ។
ទឹកស្រែប្រឡាយបែករលក សុទ្ធតែចេញមកពីឆន្ទៈ
យុវជនយុវនារីដែលជឿជាក់ លើបក្សកុម្មុយនិស្តកម្ពុជា ។
ក្នុងសហករណ៍កងទ័ពនិងរោងចក្រ យុវប្រយុទ្ធយ៉ាងខ្លាំងក្លា
ក្នុងក្រសួង មន្ទីរផងនានា សំរុកការងារគ្មានស្រាកស្រាន្ត ។
យុវកសិករស្រួចស្រាវណាស់ គ្មានស្គាល់ភូមិផ្ទះ ជាប់ការដ្ឋាន
ធ្វើស្រែយកផលស្រូវឲ្យបាន មួយហិកតាបីតោនជាទូទៅ ។
ព្រលឹមព្រលប់គ្មានឈប់ឈរ ស្ទូងដករាស់ភ្លួរស្រែធ្វើស្រូវ
បាចបើកបិទទឹកបោចស្មៅព្រៅ ដាក់ជីត្រឹមត្រូវស្រូវផលច្រើន ។
យុវកម្មករខ្លាំងក្លាក្រៃ ទាំងយប់ទាំងថ្ងៃខំបង្កើន
ផលិតផលគ្រប់មុខឲ្យបានច្រើន ដើម្បីផ្ដល់ជូនទៅសហករណ៍ ។
កងដឹកជញ្ជូនរទេះភ្លើង ញាប់ដៃញាប់ជើងចិត្តស្មោះស
ដឹកជញ្ជូនស្បៀងនិងឧបករណ៍ ជាប់ជាបន្តរៀងរាល់ថ្ងៃ ។
ចំណែកឯយុទ្ធមិត្តបងទ័ព អាវុធកាន់ជាប់ក្ដាប់ក្នុងដៃ
ត្រៀមស្ងប់ស្ងាត់ស្ងៀមភ្នែករំពៃ ការពារទឹកដីប្រទេសជាតិ ។
មិត្តរួមបង្កើនភោគផល្លា ជាមួយប្រជាខ្លាំងក្លាទៀត
យកផលឲ្យច្រើនជាដាច់ខាត រួមកសាងជាតិឲ្យមនោរម្យ ។
យុវជនយុវនារីបដិវត្តន៍ ប្រឡូកដំដុតឲ្យក្ដៅរងំ
សម្រេចភារកិច្ចដ៏ឧត្តម បដិវត្តន៍សង្គមនិយមនៅកម្ពុជា ។
ប្ដេជ្ញាកសាងខ្លួនឲ្យល្អ រឹងប៉ឹងជំហរគ្រប់វេលា
ការពារបដិវត្តន៍ឲ្យធានា ឆ្អិនឆ្អៅយូរយាររៀងរហូត ។

*ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា*
*ទស្សនាវដ្ដីចំនួន១០០០ច្បាប់ជារៀងរាល់លេខនីងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល*

*មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្ដីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្ដីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!*

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.

A magazine of the Documentation Center of Cambodia: *Searching for the truth*. Number 23, November 2001.
Funded by the Royal Ministry of Foreign Affairs, Oslo, Norway, Section for the Human Rights and Humanitarian Assistance;
Canadian International Development Agency (CIDA) through the Civil Society Fund; the Royal Danish Government
and the Royal Netherlands Government, *The Hague*.